00486643

ឯកសារលេខ/No: D97/14/14

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៣៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១០

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 18 / 03 / 2010
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ សាធារណៈ / Public

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 03 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សារណាតបរបស់លោក អៀង សារី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹង បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ស្ដីពីសហឧក្រិដ្ឋកម្មរួម**

---

| <u>ដាក់ដោយ៖</u> | <u>ផ្ញើជូន៖</u> | <u>ផ្ញើជូន៖</u> |
|---|---|---|
| **សហមេធាវី:** | **អង្គបុរេជំនុំជម្រះ** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម ប្រាក់ គឹមសាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ន័យ ថុល | លោក Andrew CAYLEY |
| | ចៅក្រម ហួត វុទ្ធី | |
| | ចៅក្រម Catherine MARCHI-UHEL | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Rowan DOWNING | |

លោក អៀង សារី តាមរយៈសហមេធាវីការពារក្ដីរបស់គាត់ ("សហមេធាវីការពារក្ដី ឬ មេធាវីការពារក្ដី") សូមធ្វើការឆ្លើយតប[1] ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ និងខៀវ សំផន ស្ដីពីសហឧក្រិដ្ឋកម្មរួម (JCE) ("ចម្លើយតប")[2]។ សារណាតបនេះ នឹងលើកឡើងនូវបញ្ហានានាដែលបានបង្ហាញនៅក្នុងចម្លើយតប បន្ទាប់ពីមានដីកាបង្គាប់ ដែលក្នុងនោះបញ្ហាទាំងឡាយត្រូវបានលើកឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព")។ ជាសំខាន់ សហមេធាវីការពារក្ដីលើកឡើងថា នៅក្នុងចម្លើយតបរបស់ខ្លួន ក.ស.ព ខកខានមិនបានផ្ដល់នូវហេតុផលសមស្រប ឬសំអាងផ្លូវច្បាប់ដែលពាក់ព័ន្ធដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនថា ក.ស.ច.ស មិនបានចេញដីកាស្របតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ដែលថាបណ្ដឹងឧទ្ធរណ៍មិនអាចទទួលយកបាន អនុលោមតាមវិធាន ៥៥(១០), ៧៤(៣)(ក) ឬ ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង និងថា JCE ដែលជាទម្រង់នៃការទទួលខុសត្រូវអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក នោះឡើយ។

## I. សេចក្ដីផ្ដើម

១. កថាខណ្ឌទី១ ដល់ទី៣ នៃចម្លើយតបគ្រាន់តែបង្ហាញអំពីទឡ្ហីករណ៍នានាដែលបានលើកឡើងនៅក្នុងចម្លើយតបនៅពេលបន្ទាប់មកទៀតតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ទឡ្ហីករណ៍ទាំងនេះនឹងមិនត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នានៅទីនេះទេ។

## II. អញ្ញត្រកម្មបឋម

២. កថាខណ្ឌទី៤ គ្រាន់តែបង្ហាញអំពីទឡ្ហីករណ៍នានាដែលបានលើកឡើងនៅក្នុងអញ្ញត្រកម្មបឋមតែប៉ុណ្ណោះ។ ទឡ្ហីករណ៍ទាំងនេះនឹងត្រូវបានដោះស្រាយដាច់ដោយឡែកពីគ្នាដូចខាងក្រោម។

---

[1] *សូមមើល រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥), សេចក្ដីសម្រេចអំពីការកំណត់លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងសេចក្ដីបង្គាប់ឱ្យដាក់ការឆ្លើយតប, ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១០, ឯកសារ D97/14/11, ERN: 00482749-00482752។ *សូមមើលផងដែរ រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥), បណ្ដឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម, ERN 00429213-00429253, ឯកសារ D97/14/5, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ("បណ្ដឹងឧទ្ធរណ៍")។

[2] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៥, ៣៨ & ៣៩), ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី, អៀង ធីរិទ្ធ, និង ខៀវ សំផន ស្ដីអំពីសហឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០, ឯកសារ D97/14/10, ERN: 00463937-00463971។

*ដីកាស្ដីពី JCE គឺជាដីកាមួយ ហេតុនេះហើយអាចប្ដឹងឧទ្ធរណ៍បាន*

៣. នៅក្នុងកថាខណ្ឌទី៥ ក.ស.ព អះអាងថា មានតែដីកាប៉ុណ្ណោះដែលអាចត្រូវបានប្ដឹងឧទ្ធរណ៍។ សហមេធាវីការពារក្ដីបានឯកភាពថា ដីកានានាអាចត្រូវបានប្ដឹងឧទ្ធរណ៍។ ក.ស.ច.ស បានចេញដីកាមួយ ហេតុនេះហើយទើបមានបណ្ដឹងឧទ្ធរណ៍។ ក.ស.ច.ស បានលើកឡើងថា ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម ("ពាក្យស្នើសុំរបស់មេធាវីការពារក្ដី")[3] គឺជាសំណើសុំមួយដែលពាក្យស្នើសុំបានយោងជា "សំណើសុំ"[4]។ លើសពីនេះទៀត ក.ស.ច.ស បានពិចារណាលើពាក្យស្នើសុំរបស់មេធាវីការពារក្ដី ស្របតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន")[5]។ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចែងពាក់ព័ន្ធតែនឹងសំណើសុំទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ។ បន្ទាប់ពីមានសំណើសុំ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យ ក.ស.ច.ស ចេញដីកា ឬបំពេញកិច្ចស៊ើបសួរ[6]។ ជាការពិត ក.ស.ច.ស បានលើកឡើងថា "អាស្រ័យដោយភាគីនានាមានឆន្ទានុសិទ្ធិនៅក្នុងការធ្វើសំណើសុំ សហចៅក្រមស៊ើបអង្កេតក៏ត្រូវមានឆន្ទានុសិទ្ធិដូចគ្នាក្នុងការកំណត់ពីទម្រង់នៃការឆ្លើយតបដែរ"[7]។ នៅក្នុងដីកាស្ដីពី JCE សហចៅក្រមស៊ើបអង្កេតបានកំណត់ទម្រង់នៃការឆ្លើយតបថាជាដីកាមួយ។ ចំណងជើងសរសេរថា: *ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម*[8]។

---

[3] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តន៍នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE), ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨, ឯកសារ D97, ERN: 00208225-00208240 ។

[4] *រឿងក្ដី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានស្គាល់ថា សហកម្មឧក្រិដ្ឋកម្មរួម, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D97/13, ERN: 00411047-00411056, ទំព័រ២ ("ដីកាស្ដីពី JCE")។

[5] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៨។

[6] វិធាន៥៥(១០) នៃវិធានផ្ទៃក្នុងចែងដោយផ្នែកថា៖ "នៅគ្រប់ពេលវេលានៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ"។ (គូសបញ្ជាក់បន្ថែម)។

[7] ដីការស្ដីពី JCE, កថាខណ្ឌ៩។

[8] *ដូចជើងទំព័រខាងលើ*, ចំណងជើង (អក្សរទ្រេតនិងគូសបញ្ជាក់បន្ថែម)។

00486646



៤. នៅក្នុងកថាខណ្ឌទី៦ ក.ស.ព អះអាងថា ដីកាស្ដីពី JCE "ពិតជាមិនមែនដីកា" នោះទេ ប៉ុន្តែគឺជា "សេចក្ដីប្រកាស" ទៅវិញទេ។ ថ្វីបើមានចំណាងជើងនៃដីកាស្ដីពី JCE និងអង្គហេតុដែលថា ក.ស.ច.ស ដោះស្រាយលើសំណើសុំស្របតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងក៏ដោយ- ក.ស.ព មិនបានផ្ដល់នូវមូលហេតុសមស្រប ឬសំអាងផ្លូវច្បាប់ពាក់ព័ន្ធនឹងមូលហេតុដែលខ្លួនពិចារណាឃើញថា ដីកានេះគឺជា "សេចក្ដីប្រកាស" ជាជាងដីកាដែលបានចេញយ៉ាងត្រឹមត្រូវនោះឡើយ (ទោះបីជាគ្មានមូលហេតុសមស្រប និងគ្មានមូលដ្ឋានពិតប្រាកដក៏ដោយ) ។ នៅពេលដែលសហ-មេធាវីការពារក្ដីយល់ព្រមថា នៅក្នុងពាក្យស្នើសុំរបស់ខ្លួន សហមេធាវីការពារក្ដីបានស្នើសុំឱ្យ ក.ស.ច.ស ធ្វើការប្រកាសថា JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.កនោះ[9] វាជាការពិតជាក់ស្ដែងដែលថា សហមេធាវីការពារក្ដីបាននឹងកំពុងស្នើសុំឱ្យមានការយល់ឃើញផ្លូវច្បាប់ ដែលនឹងត្រូវចេញក្នុងទម្រង់ជាដីកាដូចដែលវិធានផ្ទៃក្នុងបានអនុញ្ញាត។ ជាការពិត ក.ស.ច.ស គ្រាន់តែបានលើកឡើងថា: នៅក្នុងការចេញដីកាស្ដីពី JCE ក.ស.ច.ស បានធ្វើការវែកញែកផ្លូវច្បាប់ ដោយបានពិចារណាទៅលើឧទ្ទីករណ៍ និងសេចក្ដី-សន្និដ្ឋានទាំងឡាយរបស់ភាគីនានា។ បន្ទាប់ពីសន្មតថាការចេញដីកានេះត្រូវបានអនុញ្ញាតស្របតាមវិធាន និងយុត្តិសាស្ត្រជាធរមាន ប្រសិនបើ ក.ស.ច.ស មានបំណងចេញ "សេចក្ដីប្រកាស" វានឹងមានការធ្វើឡើងយ៉ាងច្បាស់លាស់ និងគ្មានមន្ទិលសង្ស័យ។ តាមការសន្មត ដីកាស្ដីពី JCE នឹងត្រូវបានដាក់ចំណងជើងថា សេចក្ដីប្រកាស JCE ជាមួយខ្លឹមសារដែលមាននៅក្នុងនោះ ដែលយ៉ាងហោចណាស់ឆ្លុះបញ្ចាំងអំពីសញ្ញាណមួយចំនួនដែលថា ក.ស.ច.ស បាននឹងកំពុងចេញសេចក្ដីប្រកាសមួយ។

*ដីកាស្ដីពី JCE គឺជាបញ្ហាយុត្តាធិការរបស់ អ.វ.ត.ក ហេតុនេះហើយអាចប្ដឹងឧទ្ធរណ៍បាន*

៥. នៅក្នុងកថាខណ្ឌទី៧ ក.ស.ព បានអះអាងថា ទោះបីជាដីកាស្ដីពី JCE គឺជាដីកាមួយក៏ដោយ ក៏វាមិនអាចប្ដឹងឧទ្ធរណ៍បានដែរ យោងតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ ការអះអាងនេះគ្មានលក្ខណៈសមហេតុផល និងគ្មានមូលដ្ឋាននោះឡើយ។ វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ចែងថា ជនត្រូវចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដោយបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានកំណត់

[9] ពាក្យស្នើសុំរបស់មេធាវីការពារក្ដី, ទំព័រ១៥។

ដោយច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលចែងអំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អនុលោមតាមកិច្ចព្រមព្រៀង[10]។ ការទទួលខុសត្រូវ JCE មិនត្រូវបានរួមបញ្ចូលនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះទេ ហេតុដូច្នេះហើយតាមយុត្តាធិការ មិនអាចអនុវត្តបាននៅ អ.វ.ត.ក ឡើយ។ ក.ស.ព យល់ព្រមទទួលស្គាល់ការជំទាស់អំពីការអនុវត្ត JCE ដែលជាទម្រង់នៃការទទួលខុសត្រូវថាជា "ការជំទាស់ផ្នែកយុត្តាធិការ"[11]។ ដូចនេះ អនុលោមតាមវិធាន ៧៤(៣)(ក) សហមេធាវីការពារក្តីសមនឹងមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍លើការយល់ឃើញរបស់ ក.ស.ច.ស ដែលថា អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្ត JCE ដែលជាទម្រង់នៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋអន្តរជាតិនានានោះ។

៦. នៅក្នុងកថាខណ្ឌទី៨ ក.ស.ព អះអាងថា ដីកាស្តីពី JCE គ្រាន់តែជា "ការប្រកាសបទដ្ឋានដែលមានស្រាប់" តែប៉ុណ្ណោះ រីឯ ក.ស.ច.ស មិនកំពុងបំពេញកិច្ចស៊ើបសួរណាមួយពាក់ព័ន្ធនឹង JCE ឡើយ។ ដូចដែលបានបង្ហាញទឡ្ហីករណ៍នៅក្នុងសេចក្តីសន្និដ្ឋានទាំងអស់របស់ខ្លួនពាក់ព័ន្ធនឹង JCE សហមេធាវីការពារក្តីបានលើកឡើងថា ជាទម្រង់នៃការទទួលខុសត្រូវមួយ JCE មិនមែនជា "បទដ្ឋានដែលមានស្រាប់" នៅចំពោះមុខប្រព័ន្ធច្បាប់កម្ពុជា ឬនៅចំពោះមុខ អ.វ.ត.ក នោះទេ ហេតុនេះហើយ មិនអាចយកមកអនុវត្តបានទេ។ ដូចនេះ សហមេធាវីការពារក្តីបានលើកឡើងថែមទៀតថា នៅក្នុងដីកាស្តីពី JCE ក.ស.ច.ស មានការភ័ន្តច្រឡំដែលបានលើកឡើងថា JCE អាចអនុវត្តបាន។ (ដោយសារតែ ក.ស.ច.ស នៅតែបន្តចេញដីកាដំណោះស្រាយ) ខណៈពេលដែលគេនៅតែមើលឃើញអំពីសកម្មភាពនានាដែល ក.ស.ច.ស នឹងបំពេញពាក់ព័ន្ធនឹងការអនុវត្ត JCE សហមេធាវីការពារក្តីលើកឡើងថា គ្មានសកម្មភាពណាមួយត្រូវបំពេញនោះឡើយលុះត្រាតែ និងរហូតទាល់តែ បញ្ហាផ្នែកយុត្តាធិការនេះត្រូវបានដោះស្រាយរួចសិន។ ក្នុងករណីដែល JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមិនអាចយកមកអនុវត្តបានទេនោះ ជាក់ស្តែង វានឹងមានផលប៉ះពាល់ដល់លក្ខណៈដែលក្នុងនោះ ក.ស.ច.ស បានធ្វើការវិភាគ និងធ្វើសំយោគលើភស្តុតាងដែលខ្លួនប្រមូលបាន ដែលខ្លួនដោះស្រាយលើសំណើសុំបំពេញកិច្ចស៊ើបសួរនានា និងសំខាន់ជាងនេះទៀត ដែលធ្វើឲ្យ ក.ស.ច.ស ធ្វើការយល់ឃើញចុងក្រោយបំផុតអំពីអង្គហេតុ និងធ្វើការសន្និដ្ឋាន

---

[10] កិច្ចព្រមព្រៀង មាត្រា ២(១)។

[11] ចម្លើយតប, កថាខណ្ឌ ១៨។ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច",០០១/១៨-០៧-១០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ឯកសារ D99/3/3, ERN: 00221998-00222027។

អំពីច្បាប់។

៧. នៅក្នុងកថាខណ្ឌទី៩ ក.ស.ព មានគម្រោងកំណត់និយមន័យនៃយុត្តាធិការ យោងតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។ យុត្តាធិការមិនគ្រាន់តែត្រូវបានកំណត់ចំពោះជំហររបស់លោក អៀង សារី ប៉ុណ្ណោះទេ[12] ថែមទាំងបានលាតសន្ធឹងទៅលើច្បាប់ជាធរមាន រួមទាំងទម្រង់នៃការទទួលខុសត្រូវនៅចំពោះមុខ អ.វ.ត.ក ផងដែរ។ ចំណុចនេះត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") នៅក្នុងរឿងក្តី Tadic: "[យុត្តាធិការ] គឺជាអំណាចរបស់តុលាការក្នុងការសម្រេចលើបញ្ហាដែលបានលើកឡើង និងការសន្មតជាមុនអំពីអត្ថិភាពរបស់តុលាការមួយដែលត្រូវបានបង្កើតឡើងយ៉ាងត្រឹមត្រូវ ក្នុងការត្រួតពិនិត្យលើកម្មវត្ថុ និងភាគីទាំងឡាយ"[13]។ ការជំទាស់អំពី JCE នៅចំពោះមុខតុលាការមិនអចិន្ត្រៃយ៍ គឺជាការជំទាស់ផ្នែកយុត្តាធិការ[14]។ ក.ស.ព ក៏មិនបានផ្តល់នូវហេតុផលសមស្របពាក់ព័ន្ធនឹងមូលហេតុអ្វីដែលការជំទាស់អំពី JCE មិនបង្កើតបានជាការជំទាស់ផ្នែកយុត្តាធិការនៅចំពោះមុខ អ.វ.ត.ក នោះដែរ។

*ដីកាស្តីពី JCE អាចត្រូវបានប្តឹងឧទ្ធរណ៍ យោងតាមវិធាន ៧៤(៣)(ខ)នៃវិធានផ្ទៃក្នុង*

៨. នៅក្នុងកថាខណ្ឌទី១០ ដល់ទី១៣ ក.ស.ព អះអាងថា ពាក្យស្នើសុំរបស់សហមេធាវីការពារក្តីមិនមែនជាសំណើសុំបំពេញកិច្ចស៊ើបសួរ យោងតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងឡើយ ហេតុដូច្នេះ មិនអាចត្រូវបានប្តឹងឧទ្ធរណ៍ស្របតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងឡើយ។ JCE

---

[12] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៩ ផ្តល់នូវឧទាហរណ៍នៃ "អង្គបុរេជំនុំជម្រះបានពិចារណាលើបណ្តឹងឧទ្ធរណ៍តាមមាត្រា ៧៤(៣)(ក) នៅពេលដែលអៀង សារី បានជំទាស់ទៅនឹងដីកាឃុំខ្លួន ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ពេលដែលខ្លួនបានបង្ហាញជាវិជ្ជមាននូវយុត្តាធិការរបស់ អ.វ.ត.ក ដើម្បីចាប់ខ្លួន ឃុំខ្លួន និងធ្វើកិច្ចស៊ើបសួរតាមផ្លូវតុលាការទៅលើជនត្រូវចោទ បើទោះជាគាត់មានទស្សនៈថា ការកាត់ទោសគាត់ពីមុនព្រមទាំងការលើកលែងទោសគាត់ ពីសំណាក់ព្រះមហាក្សត្រនឹងបញ្ឈប់ដំណើរការក្តីប្រឆាំងគាត់ពីសំណាក់តុលាការនេះ។"

[13] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង*Tadić*, IT-94-1-AR72, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំធ្វើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំស្តីពីយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌទី១០ *សម្អាង* BLACK'S LAW DICTIONARY, 712 (បោះពុម្ពលើកទី 6 ឆ្នាំ1990).

[14] *សូមមើល ឧទាហរណ៍* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadić*, IT-94-1-A, សាលដីកា, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៩០ ("សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić*")។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić*, IT-97-24-A, សាលដីកា, ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦, កថាខណ្ឌ ៦២។

00486649



គឺជាទម្រង់នៃការទទួលខុសត្រូវដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[15]។ បន្ទាប់ពីបានពិចារណាអំពីពាក្យស្នើសុំរបស់មេធាវីការពារក្តីស្របតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរួច[16] តាមរយៈដីកាស្តីពី JCE ជាលទ្ធផល ក.ស.ច.ស បានសន្និដ្ឋានថា ដំណោះស្រាយបញ្ហាយុត្តាធិការនេះ "មានភាពចាំបាច់សម្រាប់ដឹកនាំកិច្ចស៊ើបសួរ"[17]។ ការកំណត់សម្រេចពាក់ព័ន្ធនឹងបញ្ហាថាតើ JCE អាចអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញដែរឬទេនោះ ប៉ះពាល់ទៅដល់ការដឹកនាំកិច្ចស៊ើបសួរទាំងមូល និងក្រោយមកទៀតប៉ះពាល់ទៅដល់សំណើសុំបំពេញកិច្ចស៊ើបសួរនានា។ ដូចនេះ វាមានលក្ខណៈច្បាស់លាស់ណាស់ពាក់ព័ន្ធនឹងមូលហេតុដែល ក.ស.ច.ស នឹងពិចារណា (*តាមឆន្ទៈផ្ទាល់ proprio motu* ប្រសិនបើចាំបាច់)[18] លើពាក្យស្នើសុំរបស់មេធាវីការពារក្តី ថាជាកិច្ចស៊ើបសួរមួយ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន យោងតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។

*ដីកា JCE អាចត្រូវបានប្តឹងឧទ្ធរណ៍ដោយផ្ទាល់ យោងតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង*

៩. នៅក្នុងកថាខណ្ឌទី១២ ក.ស.ព បានលើកឡើងនូវការសម្រេចទាំងឡាយដែលមាន "គោលការណ៍" ដែលអង្គបុរេជំនុំជម្រះប្រើប្រាស់ ដើម្បីកំណត់អំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍។ គោលការណ៍មួយក្នុងចំណោមគោលការណ៍ដែលធ្លាប់បានហៅទាំងអស់នេះ គឺថា បណ្តឹងឧទ្ធរណ៍ណាមួយដែលយោងលើវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង មិនអាចធ្វើតែឯងបានទេ[19]។ អង្គបុរេជំនុំជម្រះមិនបានផ្តល់នូវហេតុផលជាក់លាក់ឱ្យបានគ្រប់គ្រាន់ពាក់ព័ន្ធនឹងមូលហេតុដែលថា ហេតុអ្វី

---

[15] *សូមមើល* ការចេញផ្សាយសារព័ត៌មាន, សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា, ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧។

[16] ដីកាស្តីពី JCE, កថាខណ្ឌ៨។

[17] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[18] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងចែងដោយផ្នែកថា៖ "សហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ ..."

[19] *សូមមើល រឿងក្តី អៀង ធីរិទ្ធ,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២៦), សាលដីកាលើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចអំពីការប្រើប្រាស់ចម្លើយដែលបានមក ឬ ដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩, ឯកសារ D130/9/21, ERN: 00416830-00416838 ("សាលដីកា អ.ប.ជ លើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងចម្លើយដែលបាន ឬ អាចបានមកដោយការធ្វើទារុណកម្ម") កថាខណ្ឌ ១៩។

បណ្តឹងឧទ្ធរណ៍ដែលយោងលើវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង មិនអាចធ្វើតែឯងបាននោះឡើយ[20]។ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ចែងថា ដីកា "បើកផ្លូវប្តឹងឧទ្ធរណ៍"។ នៅក្នុងរឿងក្តីរបស់ *ឌុច* អង្គបុរេជំនុំជម្រះបានយល់ឃើញថា ក.ស.ច.ស មិនបានកំណត់អំពីអង្គហេតុជាសត្យានុម័តឱ្យបានពិស្តារជាក់លាក់គ្រប់គ្រាន់ឡើយ[21] និងបន្ទាប់មកទៀតបានធ្វើការកំណត់សម្រេចផ្ទាល់ខ្លួន។ អង្គបុរេជំនុំជម្រះមិនបានអនុវត្តតាមការបង្ហាញហេតុផលផ្ទាល់របស់ខ្លួនឡើយនៅក្នុងការផ្តល់នូវភាពជាក់លាក់គ្រប់គ្រាន់ក្នុងការលើកឡើងអំពីមូលហេតុអ្វី ដែលបណ្តឹងឧទ្ធរណ៍ដែលយោងលើវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង មិនអាចធ្វើតែឯងបាននោះ។ ដូចនេះសហមេធាវីការពារក្តីត្រូវបានបង្ខាប់ឱ្យធ្វើការកំណត់សម្រេចផ្ទាល់ខ្លួន និងអនុវត្តតាមអត្ថន័យពិតប្រាកដនៃវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។ លើសពីនេះទៀត ក.ស.ព ខកខានមិនបានពន្យល់អំពីបញ្ហា ហេតុអ្វីបានជាបណ្តឹងឧទ្ធរណ៍នេះមិនត្រូវបានអនុញ្ញាត អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។ តាមរយៈការអនុវត្តតាមអត្ថន័យពិតប្រាកដនៃ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង - ដែលការលើកឡើងរបស់សហមេធាវីការពារក្តីកំពុងធ្វើការត្រួតពិនិត្យ - ដីកាស្តីពី JCE បើកផ្លូវប្តឹងឧទ្ធរណ៍ដោយផ្ទាល់ យោងតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

*ដីកាស្តីពី JCE រំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ហេតុដូច្នេះហើយអាចប្តឹងឧទ្ធរណ៍បាន*

១០. នៅក្នុងកថាខណ្ឌទី១៤ ក.ស.ព បានអះអាងយ៉ាងត្រឹមត្រូវថា អង្គបុរេជំនុំជម្រះត្រូវពិនិត្យថាតើវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង គួរត្រូវបានបកស្រាយ "ដោយទូលំទូលាយ ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីធានាកិច្ចដំណើរការនីតិវិធី ប្រកបដោយ "យុត្តិធម៌ និងឆាប់រហ័ស" ដែរឬទេ"[22]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះគួរតែធ្វើការបកស្រាយវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ពីព្រោះវាការពារដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌របស់លោក អៀង សារី ក៏ដូចជារបស់ជនត្រូវចោទគ្រប់រូប

---

[20] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ១៩។

[21] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច"*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ឯកសារ D99/3/42, ERN: 00249846-00249887, កថាខណ្ឌ ៥៦-៥៨។

[22] ចម្លើយតប, កថាខណ្ឌ ១៤។ សាលដីកា អ.ប.ជ លើភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងចម្លើយដែលបានឬ អាចបានមកដោយការធ្វើទារុណកម្ម, កថាខណ្ឌ ២៥។

ផងដែរ។ ដូចនេះ អង្គបុរេជំនុំជម្រះត្រូវប្រើអំណាចឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួននៅក្នុងការសម្រេចថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន នៅពេលដែលដីកាស្តីពី JCE រំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌របស់លោក អៀង សារី។

១១. នៅក្នុងកថាខណ្ឌទី១៥ និងទី១៧ ក.ស.ព អះអាងថា អង្គបុរេជំនុំជម្រះនឹងមិនរំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌របស់ជនត្រូវចោទនោះទេ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបានទេនោះ ពីព្រោះបច្ចុប្បន្ននេះគ្មានជនត្រូវចោទណាម្នាក់ត្រូវបានផ្តន្ទាទោសអំពីបទឧក្រិដ្ឋណាមួយ ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវ JCE នោះឡើយ[23]។ ទឡ្ហីករណ៍នេះត្រូវបានគ្រប់គ្រងដោយជំនឿខុសឆ្គងដែលថា JCE អាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញ។ ជំនឿខុសឆ្គងនេះធ្វើឱ្យមានការសន្និដ្ឋានខុស ទោះបីជាមានការបង្ហាញឱ្យឃើញថា ដំណើរការគិតពិចារណារបស់ ក.ស.ព មានភាពសមរម្យក៏ដោយ។ ជំនឿខុសឆ្គងប្រភេទដែលត្រូវបានស្គាល់ថាជាការសន្មតចំណុចដំបូង (*petition principii* ឬ *begging the question*) នេះ ត្រូវបានពណ៌នាយ៉ាងសក្តិសមដោយលោក Aristotle ថា: "វាពិតណាស់ដែលថា ការបង្ហាញហេតុផលមួយចំនួននោះមានលក្ខណៈពិតប្រាកដ ខណៈពេលដែលការបង្ហាញហេតុផលផ្សេងទៀតហាក់ដូចជាពិតប្រាកដដែរ តែមិនមែននោះទេ។ ដូចនៅកន្លែងដទៃទៀតដែរ រឿងនេះកើតឡើងដោយមានទឡ្ហីករណ៍នានា តាមរយៈភាពដូចគ្នាមួយចំនួនរវាងការពិត និងការក្លែងបន្លំ"[24]។ តាមរយៈដីកាស្តីពី JCE ក.ស.ច.ស អនុញ្ញាតឱ្យមានការស្នើសុំទម្រង់នៃការទទួលខុសត្រូវហួសពីយុត្តាធិការរបស់ អ.វ.ត.ក។ បញ្ហានេះបន្សល់ទុកនូវសក្តានុពលមួយសម្រាប់ការផ្តន្ទាទោសធ្វើឡើង ដោយផ្អែកលើទម្រង់នៃការទទួលខុសត្រូវដែល អ.វ.ត.ក គ្មានយុត្តាធិការក្នុងការអនុវត្តទេ។ ក.ស.ព បានបង្ហាញរួចហើយនូវចេតនារបស់ខ្លួនក្នុងការអនុវត្តការទទួលខុសត្រូវ JCE ចំពោះជនត្រូវចោទនានានៅក្នុងសំណុំរឿងលេខ

---

[23] ចម្លើយតប, កថាខណ្ឌ ១៥។

[24] Aristotle, *De Sophisticis Elenchis*, *អាចមើលបាននៅ* http://etext.virginia.edu/etcbin/toccer-new2?id=AriSoph.xml&images=images/modeng&data=/texts/english/modeng/parsed&tag=public&part=1&division=div2 ។

00486652



០០២[25]។ ដូចនេះ បណ្ដឹងឧទ្ធរណ៍មិនមែនមាន "លក្ខណៈជាទ្រឹស្ដី" ដូចដែល ក.ស.ព បាន អះអាងនោះឡើយ[26] ប៉ុន្តែគឺអាចអនុវត្តបាន។ គ្រោងការរឿងក្ដីដ៏អាក្រក់បំផុតនោះគឺថា ជនត្រូវចោទត្រូវបានផ្ដន្ទាទោសដោយផ្អែកតាមការទទួលខុសត្រូវ JCE ទាំងស្រុងតែម្ដង។ ប្រសិនបើបណ្ដឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថា មិនអាចទទួលយកបាន រីឯ JCE ត្រូវបានអនុវត្តដោយ ក.ស.ច.ស នោះ - ទោះបីជាវាជាទម្រង់នៃការទទួលខុសត្រូវដែលមិនអាចអនុញ្ញាតឱ្យបានក៏ដោយ - លោក អៀង សារី នឹងទទួលរងនូវការឈឺចាប់ដែលបណ្ដាលមកពីការរំលោភពិតប្រាកដលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់គាត់។

១២. នៅក្នុងកថាខណ្ឌទី១៦ និងទី១៧ ក.ស.ព អះអាងថា សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់ជនត្រូវចោទ នឹងមិនត្រូវបានរំលោភនោះឡើយ ពីព្រោះជនត្រូវចោទ "នឹងមានបុព្វហេតុដែលមានសុពលភាពក្នុងការរៀបចំនូវការជំទាស់ផ្នែកយុត្តាធិការ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអាចមាន "អំណាចក្នុងការកែប្រែការកំណត់លក្ខណៈផ្លូវច្បាប់នៃបទឧក្រិដ្ឋទាំងឡាយ" ត្រឹមដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនោះ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការដកហូតការទទួលខុសត្រូវពីលោក អៀង សារី ដើម្បីស្វែងរកប្រភេទនៃការការពារ និងការដោះបន្ទុក ដែលបច្ចុប្បន្ននេះរូបគាត់មានសិទ្ធិទទួលបាន។ ចំណុចនេះអាចអនុវត្តបានជាពិសេស (ដូចដែលបានជំទាស់ទៅនឹងលក្ខណៈជាទ្រឹស្ដី) ពាក់ព័ន្ធនឹងសិទ្ធិក្នុងការទទួលបាននូវ "ពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន" ដូចមានចែងនៅក្នុងមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR") ដែលត្រូវបានច្របាច់បញ្ចូលគ្នាយ៉ាងជាក់លាក់នៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀង[27]។ ដោយសារតែនៅដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី ក.ស.ច.ស មិនទទួលបន្ទុកលើរឿងក្ដី

---

[25] ចម្លើយតប, កថាខណ្ឌ ៩៤ និយាយដោយផ្អែកថា "[ការ]ច្រានចោលនូវការទទួលខុសត្រូវតាម JCE មុខជានឹងលះបង់ចោលនូវទម្រង់នៃការទទួលខុសត្រូវមួយ ដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងយ៉ាងពិតប្រាកដ នូវអាកប្បកិរិយារបស់ដើមបណ្ដឹងឧទ្ធរណ៍នានា ទាក់ទងនឹងអំពើសាហាវយង់ឃ្នងដ៏ទូលំទូលាយរបស់ពួកខ្មែរក្រហមជាមិនខានឡើយ"។

[26] ចម្លើយតប, កថាខណ្ឌ ១៥។

[27] កិច្ចព្រមព្រៀង មាត្រា១៣(១)។ មាត្រានេះចែងដោយផ្អែកថា៖ "សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្ដី"។

តទៅទៀត[28] រីឯមេធាវីការពារក្តីត្រូវបានណែនាំប្រឆាំងនឹងការដឹកនាំកិច្ចស៊ើបសួរផ្ទាល់ខ្លួននោះ[29] បញ្ហានេះអាចនឹង (ដូចដែលបានជំទាស់ទៅនឹងលក្ខណៈជាទ្រឹស្តី) ប៉ះពាល់ដល់លោក អៀង សារី៖ គាត់នឹងគ្មានភាពងាយស្រួល[30] ក្នុងការរៀបចំការពារខ្លួនឱ្យបានពេញលេញតទល់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តីនោះឡើយ។ លើសពីនេះទៀត ប្រសិនបើ អង្គបុរេជំនុំជម្រះមិនសម្រេចទៅលើភាពអាចអនុវត្តបាននៃទម្រង់ JCE នៅ អ.វ.ត.ក ទេនោះ ទំហំនៃការចោទប្រកាន់ទាំងឡាយនឹងនៅតែមានភាពមិនច្បាស់លាស់ រហូតដល់ពេលចេញសាលក្រមសម្រេចនៅក្នុងសំណុំរឿងលេខ ០០២។ បញ្ហានេះនឹងប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី ដែលក្នុងនោះរូបគាត់នឹងមិនត្រូវបានជូនដំណឹងឱ្យបានត្រឹមត្រូវអំពីទំហំនៃការចោទប្រកាន់ទាំងឡាយប្រឆាំងនឹងរូបគាត់នោះទេ រហូតដល់ពេលបញ្ចប់ការជំនុំជម្រះក្តីនោះ។

*តាមនីតិវិធី ការបដិសេធបណ្តឹងឧទ្ធរណ៍មិនជួយជម្រុញដល់សេដ្ឋកិច្ចតុលាការនោះទេ*

១៣. នៅក្នុងកថាខណ្ឌទី១៨ ក.ស.ព អះអាងថា ប្រសិនបើអង្គបុរេជំនុំជម្រះធ្វើការពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងនេះ ដែលនឹងមានបន្ទាប់គ្នានូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើភាពអាចអនុវត្តបាននៃទម្រង់ JCE ដែលការនេះ "នឹងនាំឱ្យមានការសម្រេចជាន់គ្នា ឬក៏អាចឈានដល់ការសម្រេចផ្ទុយគ្នា"។ ចំណុចនេះលើកឡើងថា ក.ស.ព ទទួលស្គាល់ភាពមិនច្បាស់លាស់ដែលមានជុំវិញបញ្ហាទម្រង់ JCE។ ជាការពិត ក.ស.ព បានរួមចំណែកគួរឱ្យកត់សម្គាល់ចំពោះភាពមិនច្បាស់លាស់នេះតាមរយៈការលើកឡើងអំពីបញ្ហា JCE នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី *ឌុច*[31] បន្ទាប់ពីបញ្ហាត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ[32]។ លើសពីនេះទៀត

---

[28] *សូមមើល* វិធាន៦៧ នៃវិធានផ្ទៃក្នុង។

[29] *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចធ្វើការព្រមានដោយអនុវត្តតាមវិធាន ៣៨, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០, ឯកសារ D367, ERN: 00478513-00478519, កថាខណ្ឌ ៩។

[30] មាត្រា ១៤(៣)(ខ) នៃ ICCPR ចែងដោយផ្នែកថា ជនគ្រប់រូបត្រូវ "មានពេលវេលា និង<u>សម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន</u>។" (គូសបញ្ជាក់បន្ថែម)។

[31] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ឯកសារ E1/39.1, ERN: 00345656-00345765, ទំព័រ ៨-៩។

[32] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ឯកសារ D99/3/42, ERN: 00249846-00249887, កថាខណ្ឌ ១៤២។

អង្គហេតុដែលថា ការផ្ទុយគ្នាអាចកើតមានឡើងរវាងសេចក្ដីសម្រេចទាំងឡាយដែលធ្វើដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង គឺជាលក្ខណៈនៃប្រព័ន្ធច្បាប់ផ្ទាល់របស់ អ.វ.ត.ក។ ចំណុចនេះ មិនគួរត្រូវបានយល់ឃើញថាជាឧបសគ្គសម្រាប់អង្គបុរេជំនុំជម្រះធ្វើការពិចារណាលើបណ្ដឹងឧទ្ធរណ៍នេះឡើយ។ ការអនុវត្តតាមការបង្ហាញហេតុផលប្រភេទនេះមិនគ្រាន់តែមានលក្ខណៈផ្ទុយទៅនឹងបទបញ្ញត្តិនានាដែលបានកំណត់ដោយវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ថែមទាំងលុបបំបាត់នូវបន្ទុកការងារភាគច្រើនដ៏ធំធេងរបស់អង្គបុរេជំនុំជម្រះទៀតផង ដូចនេះធ្វើឱ្យវាគ្មានប្រយោជន៍ទៀតទេ។ អង្គបុរេជំនុំជម្រះអាចជួយកាត់បន្ថយភាពមិនច្បាស់លាស់នេះ ខណៈពេលដែល ការជួយជម្រុញដល់សេដ្ឋកិច្ចតុលាការធ្វើឡើងតាមរយៈការកំណត់សម្រេចលើបណ្ដឹងឧទ្ធរណ៍ជាសំខាន់នោះ។

១៤. នៅក្នុងកថាខណ្ឌទី៩ ក.ស.ព អះអាងថា នៅក្នុងរឿងក្ដី *ឌុច* អង្គជំនុំជម្រះសាលាដំបូងបានទទួលនូវការជំទាស់នានាដែលស្ទើរតែដូចគ្នា ហើយដើម្បីភាពស្របគ្នាផ្នែកយុត្តិសាស្ត្រ អង្គបុរេជំនុំជម្រះត្រូវធ្វើការបដិសេធបណ្ដឹងឧទ្ធរណ៍។ ការបន្សល់ទុកនូវការជំទាស់ឱ្យអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដី *ឌុច* នឹងហាមឃាត់លោក អៀង សារី មិនឱ្យធ្វើការបង្ហាញអំពីភាពអាចអនុវត្តបាននៃទម្រង់ JCE នៅអ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងនឹងមិនបានផលប្រយោជន៍អ្វីអំពីការជំទាស់ទាំងស្រុងទៅលើភាពអាចអនុវត្តបាននៃទម្រង់ JCE នោះទេ ដោយសារតែលក្ខណៈដែលបានកំហិតទៅលើមេធាវីការពារក្ដីនៅក្នុងរឿង *ឌុច*។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្ដឹងជំទាស់ផ្នែកយុត្តាធិការនេះ អាចត្រូវបានរំពឹងថាបានទទួលមុនដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ ០០២ តែទោះជាយ៉ាងណាក៏ដោយ គ្មានការធានាថាវានឹងកើតឡើងបែបនេះទេ។ ការបន្សល់ទុកនូវការកំណត់សម្រេចលើភាពអាចអនុវត្តបាននៃទម្រង់ JCE នៅក្នុងដំណាក់កាលដ៏យឺតយ៉ាវនេះដោយគ្មានការធានាអំពីការកំណត់សម្រេចណាមួយនោះ មិនគ្រាន់តែប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោក អៀង សារី នោះទេ វាថែមទាំងមិនជួយជម្រុញដល់សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធីផងដែរ។

១៥. លើសពីនេះទៀត នៅក្នុងកថាខណ្ឌទី១៩ ដល់ទី២១ ក.ស.ព បានអះអាងថា ពេលវេលាល្អបំផុតក្នុងការកំណត់សម្រេចអំពីភាពអាចអនុវត្តបាននៃទម្រង់ JCE គឺនៅពេលណាដែលលោក អៀង សារី បានទទួលនូវការចោទប្រកាន់។ ការពន្យារការសម្រេចលើភាពអាចអនុវត្តបាននៃទម្រង់ JCE នៅ អ.វ.ត.ក នៅដំណាក់កាលនេះ មិនជួយដល់សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធីដ៏ប្រុងប្រយ័ត្ននោះឡើយ ដោយសារតែ: ១) នៅមានលទ្ធភាពដែលលោក អៀង សារី អាចមិនត្រូវរងនូវការ

00486655



ចោទប្រកាន់ ហេតុដូច្នេះហើយអាចឈានដល់អង្គជំនុំជម្រះសាលាដំបូងប្រសិនបើត្រូវបានរកឃើញថា JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលមិនអាចអនុវត្តបាននៅ អ.វ.ត.ក។ និង ២) វានឹងមិនជួយដល់សេដ្ឋកិច្ចតាមកិច្ចដំណើរការនីតិវិធីឡើយ ប្រសិនបើផ្នែកខ្លះនៃការចោទប្រកាន់ ឬការចោទប្រកាន់ទាំងមូល បានផ្អែកលើទម្រង់ JCE ហើយក្រោយមកទៀតអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ទម្រង់ JCE គឺជាទម្រង់នៃការទទួលខុសត្រូវដែលមិនអាចអនុវត្តបាននៅ អ.វ.ត.ក ទេនោះ។ នៅក្នុងវិធានផ្ទៃក្នុង ពុំមានបញ្ញត្តិដែលអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះបន្សល់ទុកនូវបញ្ហាទាំងឡាយដែលជាសមត្ថកិច្ចត្រូវធ្វើការជំនុំជម្រះរបស់ខ្លួន ឱ្យទៅអង្គជំនុំជម្រះសាលាដំបូងឡើយ។ តាមរយៈការបន្សល់ទុកនូវការកំណត់សម្រេចលើភាពអាចអនុវត្តបាននៃទម្រង់ JCE ឱ្យអង្គជំនុំជម្រះសាលាដំបូង អង្គបុរេជំនុំជម្រះនឹងមិនបំពេញមុខងាររបស់ខ្លួន "យ៉ាងត្រឹមត្រូវ និងឆាប់រហ័ស" ស្របតាមមាត្រា ៥(៣) នៃក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក ឡើយ[33]។

១៦. នៅក្នុងកថាខណ្ឌទី២០ ក.ស.ព យល់ស្របយ៉ាងខ្លាំងថា នៅមានលទ្ធភាពដែលលោក អៀង សារី អាចមិនត្រូវរងនូវការចោទប្រកាន់តាមការទទួលខុសត្រូវ JCE។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចនេះនៅតែបន្សល់ទុកនូវលទ្ធភាពដែល លោក អៀង សារី អាចមិនត្រូវរងនូវការចោទប្រកាន់តាមការទទួលខុសត្រូវ JCE។ ដោយសារតែ JCE មិនអាចអនុវត្តបាននៅ អ.វ.ត.ក លទ្ធភាពនេះមានន័យថា អ.វ.ត.ក កំពុងដើរតួនាទីហួសពីយុត្តាធិការរបស់ខ្លួន។ ចំណុចនេះមិនអាចជួយជម្រុញដល់សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធីនោះទេ ពីព្រោះការអនុវត្តច្បាប់ដែលមិនអាចអនុវត្តបានណាមួយ នឹងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ហេតុនេះធ្វើឱ្យមានការពន្យារដល់ដំណើរការតុលាការ។

១៧. នៅក្នុងកថាខណ្ឌទី២២ ក.ស.ព លើកឡើងថា "ការអនុវត្តទម្រង់ JCE ផ្ទុះបញ្ចាំងអំពីអង្គហេតុ"។ ចំណុចនេះបង្ហាញថា ក.ស.ព ខកខានមិនបានលើកតម្កើងនូវស្ថានភាពលំបាកដែលអង្គបុរេជំនុំជម្រះត្រូវដោះស្រាយនោះឡើយ។ បញ្ហានៅចំពោះមុខ ក.ស.ច.ស ហើយពេលនេះនៅចំពោះមុខអង្គបុរេជំនុំជម្រះ គឺថាតើ ទម្រង់ JCE អាចអនុវត្តបាននៅ អ.វ.ត.ក ដែរឬទេ។ នៅពេលណាដែលបញ្ហានេះត្រូវបានដោះស្រាយ និងមានតែពេលដែលបញ្ហានេះត្រូវបានដោះស្រាយប៉ុណ្ណោះ ទើបអាចនិយាយអំពីអង្គហេតុនានាបាន។ មិនអាចធ្វើបញ្ច្រាសពីនេះបានទេ។ ហេតុនេះ វិធីល្អ

---

[33] ក្រមសីលធម៌ចៅក្រម អ.វ.ត.ក, ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨។ មាត្រា ៥(៣) ចែងដោយផ្នែកថា៖ "ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ"

ក្នុងការជួយដល់សេដ្ឋកិច្ចនៃកិច្ចដំណើរការនីតិវិធីភាគច្រើន គឺជាការដែលអង្គបុរេជំនុំជម្រះយល់ឃើញថាបណ្តឹងឧទ្ធរណ៍អាចទទួលយកបាន។

III. **សេចក្តីសន្និដ្ឋានស្តីពីនីតិវិធី**

១៨. ផ្នែកនៃចម្លើយតបនេះ ពិភាក្សាអំពីការត្រូវការឱ្យមានចម្លើយតបរួមមួយ ទទ្បីករណីមួយដែលមិនតម្រូវឱ្យមានសវនាការដេញដោលផ្ទាល់មាត់ និងការច្របាច់បញ្ចូលគ្នាតាមរយៈការយោងលើបណ្តឹងទាមទារទាំងឡាយដែលមានពីមុន។ សារណាតបទៅនឹងផ្នែកនេះ គ្មានភាពចាំបាច់ឡើយ។

IV. **ឧឡ្លីករណ៍**

**ក. ទម្រង់ JCE មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីតុលាការ Nuremberg នោះទេ**

១៩. នៅក្នុងកថាខណ្ឌទី៣២ ក.ស.ព មិនបានផ្តល់នូវសម្អាងផ្លូវច្បាប់សម្រាប់ការអះអាងរបស់ខ្លួនដែលថា "ច្បាប់លក្ខន្តិកៈអន្តរជាតិ សំណុំរឿង និងការប្រកាសរបស់អាជ្ញាធរអន្តរជាតិនានា ក៏ដូចជាសំណុំរឿងក្នុងស្រុក" គាំទ្រដល់អត្ថិភាពនៃទម្រង់ JCE ដែលមានចាប់តាំងពីតុលាការ Nuremburg មកម្ល៉េះឡើយ។ ក.ស.ព ក៏មិនបានផ្តល់នូវសម្អាងផ្លូវច្បាប់សម្រាប់ការអះអាងរបស់ខ្លួន ដែលថា ចំណុចនេះបានផ្តល់នូវភស្តុតាងស្តីពីការអនុវត្តយ៉ាងទូលំទូលាយរបស់រដ្ឋ និងសច្ចាធារណ៍ធម្មានុរូបនៃអំពើ ឬការទទួលស្គាល់ថាជាច្បាប់ដោយរដ្ឋ *(opinio juris)* ដែលចាំបាច់សម្រាប់បង្កើតឱ្យមានច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សហមេធាវីការពារក្តីបានធ្វើការបង្ហាញយ៉ាងទូលំទូលាយរួចមកហើយថា ការអនុវត្ត យ៉ាងទូលំទូលាយរបស់រដ្ឋ ឬក៏ ការទទួលស្គាល់ថាជាច្បាប់ដោយរដ្ឋ *(opinio juris)* បែបនេះ គឺគ្មានទេ[34]។

២០. នៅក្នុងកថាខណ្ឌទី៣៣ ក.ស.ព លើកឡើងថា ការទទួលខុសត្រូវសម្រាប់ការចូលរួមក្នុងផែនការរួម គឺមាននៅក្នុង "ច្បាប់ជាតិ ឬយុត្តិសាស្ត្ររបស់ប្រទេសជាច្រើនដែលអនុវត្តតាមប្រព័ន្ធច្បាប់ខំមិនឡ និងប្រព័ន្ធច្បាប់ស៊ីវិលឡ ចាប់តាំងពីសតវត្សទី១៩"។ ជាថ្មីម្តងទៀត ពុំមានសម្អាងផ្លូវច្បាប់ណាមួយត្រូវបានបង្ហាញសម្រាប់ការអះអាងបែបនេះឡើយ។ ទោះបីជាការអះអាងបែបនេះជាការពិតក៏ដោយ "ទម្រង់មួយចំនួន" នៃទទួលខុសត្រូវចំពោះផែនការរួម មិនមានលក្ខណៈស្មើគ្នានឹងទម្រង់ JCE នោះទេ ដូចបានធ្វើឡើងតាមរយៈរឿងក្តី Tadic។ ក.ស.ព អះអាងថា

---

[34] *សូមមើល ឧទាហរណ៍,* បណ្តឹងឧទ្ធរណ៍, ឧបសម្ព័ន្ធ ក, ផ្នែក II, ឃ, ១។

យុត្តាធិការ "ដែលបានអភិវឌ្ឍ" ជាច្រើន បានទទួលស្គាល់នូវទម្រង់នៃការចូលរួមប្រព្រឹត្តរួមគ្នា ប្រហាក់ប្រហែលគ្នា នឹងទម្រង់លាតសន្ធឹង ( JCE III)។ ចំណុចនេះមិនបង្ហាញនូវការគាំទ្រ នូវអត្ថិភាពនៃទម្រង់ JCE នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះឡើយ។ ទម្រង់នៃការចូលរួមប្រព្រឹត្តរួមគ្នាមានលក្ខណៈខុសប្លែកគ្នាពីទម្រង់ JCE គួរឲ្យកត់សម្គាល់[35]។ ក.ស.ព ខកខានមិនបានពន្យល់អំពីហេតុអ្វីបានជា អ.វ.ត.ក មិនត្រូវអនុវត្តទម្រង់នៃការចូលរួមប្រព្រឹត្តរួមគ្នាដែលមានចែងនៅក្នុងច្បាប់កម្ពុជា (ត្រូវបានបំផុសគំនិត និង ត្រូវបានធ្វើជាគំរូបន្ទាប់ពីមានប្រព័ន្ធច្បាប់បារាំង) និងដែល ក.ស.ព បានទទួលស្គាល់ថាមាន នៅក្នុងយុត្តាធិការ "ដែលបានអភិវឌ្ឍ" ជាច្រើននោះឡើយ។ អង្គបុរេជំនុំជម្រះពីរនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ("ICC") ថ្មីៗនេះបានពិនិត្យលើការបែងចែកដាច់ពីគ្នា រវាងទម្រង់នៃការចូលរួមប្រព្រឹត្តរួមគ្នាយោងតាមច្បាប់លក្ខន្តិកៈរបស់តុលាការ ICC និងទម្រង់ JCE និងបានសន្និដ្ឋានថា ទម្រង់ទាំងពីរនេះមិនអាចមានលក្ខណៈស្មើគ្នានោះទេ[36] ។ លោក Schomburg អតីតចៅក្រម នៃអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY/ICTR បានពន្យល់ថា "ទស្សនាទាននៃសហឧក្រិដ្ឋកម្មរួម... គឺអាចបកស្រាយបានតែម្យ៉ាងគត់ថាជា "ការប្រព្រឹត្ត" ...។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗជាច្រើន

---

[35] ៣៥. ភាពខុសគ្នារវាងការរួមប្រព្រឹត្ត និងសហឧក្រិដ្ឋកម្មរួម ត្រូវបានអង្គុលបង្ហាញជាញឹកញ៉ាប់ដោយ មេធាវីការពារក្តី។ "ច្បាប់កម្ពុជាស្តីពីការរួមប្រព្រឹត្ត ដូចដែលបានចែងក្នុងមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ខុសគ្នាជាសត្យានុម័តពីសហឧក្រិដ្ឋកម្មរួម ចំពោះហេតុផលចំនួនបីដូចខាងក្រោមនេះ :

**ទីមួយ** ការប្រព្រឹត្តរួមតម្រូវឲ្យមានវត្តមានសហចារីនីមួយៗនៅកន្លែងកើតហេតុ។ ចំពោះការភ្ជាប់ទៅនឹងការទទួលខុសត្រូវសហចារីនីមួយៗ ត្រូវតែបានសម្រេចនូវសកម្មភាពជាក់ស្តែងជាបុគ្គល ដែលចាត់ទុកថាជាបទល្មើស។ ផ្ទុយទៅវិញ វាត្រូវបានគេយល់ឃើញថា វត្តមានរបស់សមាជិក JCE គឺមិនតម្រូវឲ្យជនជាប់ចោទ ត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោមសហឧក្រិដ្ឋកម្មរួមឡើយ។

**ទីពីរ** ដោយសារតែការប្រព្រឹត្តរួម តម្រូវឲ្យសហចារីនីមួយៗ បានសម្រេចនូវសកម្មភាពជាក់ស្តែងជាបុគ្គល ដែលចាត់ទុកថាជាបទល្មើស សហចារីនីមួយៗមិនអាចប្រើអ្នកដទៃ ដែលមិនមែនជាសហចារីឲ្យប្រព្រឹត្តបទល្មើសជាក់ស្តែងបានឡើយ។ ផ្ទុយទៅវិញ វាត្រូវបានគេយល់ឃើញថា ជនជាប់ចោទអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តដោយអាទិចារី ឬចារីដែលដល់ ដែលនៅខាងក្រៅ JCE ប្រសិនបើពួកគេត្រូវបានប្រើប្រាស់ដោយសមាជិករបស់ JCE។

**ទីបី** JCE បំបែកផែនការរួមដែលត្រូវបានចោទប្រកាន់ ចេញជាគោលបំណង និងវិធីសាស្ត្រដែលត្រូវបានពិចារណាដើម្បីសម្រេចនូវគោលបំណងនោះ។ ផ្ទុយទៅវិញ ការប្រព្រឹត្តរួម មិនបានធ្វើការបែងចែកចំណុចទាំងពីរនេះទេ"។ ដូចយោងខាងលើ ឧបសម្ព័ន្ធ ក កថាខណ្ឌទី២០ (ការដកស្រង់ខាងក្នុងត្រូវបានលុបចោល)។

[36] *សូមមើល* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤៩-៥៨ និងអាគតដ្ឋានជាប់ពាក់ព័ន្ធ។

"ការប្រព្រឹត្ត" ត្រូវបានធ្វើការបកស្រាយខុសៗគ្នា។ ចាប់តាំងពីតុលាការ Nuremberg និងតុលាការទីក្រុងតូក្យូមក ច្បាប់ព្រហ្មទណ្ឌជាតិ ក៏ដូចជាអន្តរជាតិ បានទទួលស្គាល់ជាពិសេសថា ការចូលរួមប្រព្រឹត្តរួមគ្នា និងភាពជាចារីប្រយោល (ការប្រព្រឹត្តតាមរយៈមធ្យោបាយ) គឺជាទម្រង់នៃ "ការប្រព្រឹត្ត"[37]។

២១. នៅក្នុងកថាខណ្ឌ ៣៤ ក.ស.ព អះអាងថា "Grotian moment" បានកើតឡើង ទាក់ទិនទៅនឹងការទទួលត្រូវ JCE បន្ទាប់ពីមានសាលក្រមដែលចេញមកពីបណ្តាតុលាការក្រោយសង្គ្រាមលោកលើកទី២។ ទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិកើតចេញមកពី Grotian moment ក៏ដោយ វាអាចធ្វើទៅបានតែនៅក្នុងកាលៈទេសៈដែលបានកំណត់ប៉ុណ្ណោះ។ ដោយមិនគិតអំពីថាតើច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចលេចឡើងបែបណានោះ លក្ខខណ្ឌតម្រូវដែលវាត្រូវតែអនុលោមទៅនឹងការអនុវត្តរបស់រដ្ឋ និង ការទទួលស្គាល់ថាជាច្បាប់ដោយរដ្ឋ *(opinio juris)* គឺជាមូលដ្ឋាន[38]។ ដូច្នេះ សម្រាប់ទ្រឹស្តីនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ លេចឡើងដោយមានភាពឆាប់រហ័សខុសពីធម្មតា និងមានការទទួលយកវិធាន ឬទ្រឹស្តីនោះ[39] ជាពិសេស Grotian moment ត្រូវបានកម្រិតត្រឹមច្បាប់ ដែលអាចត្រូវបានអនុវត្តដោយបណ្តារដ្ឋដែលមានចំនួនកំណត់ប៉ុណ្ណោះ។ ឧទាហរណ៍ ការអនុវត្តណាមួយរបស់រដ្ឋ និងទស្សនច្បាប់ ស្តីពី ច្បាប់ស្តីពីអវកាស (space law) អាចត្រូវបានគេអនុវត្តបានដោយបណ្តារដ្ឋទាំងឡាយ ដែលមានលទ្ធភាពចូលទៅដល់អវកាសប៉ុណ្ណោះ។ ក្នុងអំឡុងរយៈពេលនៃសង្គ្រាមត្រជាក់ មានតែសហរដ្ឋអាមេរិក និងសហភាពសូវៀតប៉ុណ្ណោះដែលអាចអនុវត្តទៅបាន។ ច្បាប់ទំនៀម ទម្លាប់អន្តរជាតិ ដែលតាមនិយមន័យមានតែរដ្ឋពីរប៉ុណ្ណោះអាចប្រើប្រាស់បាន អាចបង្កើតយ៉ាងឆាប់រហ័សថែមទៀត និងត្រូវបានទទួលស្គាល់

---

[37] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Gacumbitsi*, ICTR-2001-64-A, សាលដីកា មតិយោបល់ដាច់ដោយឡែកពីគ្នារបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ដើមបណ្តឹងឧទ្ធរណ៍ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២00៦ កថាខណ្ឌទី១៦។

[38] "ច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ផ្តើមឡើងជាការអនុវត្តជាទម្លាប់ ហើយក្រោយមកមានការអភិវឌ្ឍពេញលេញជាច្បាប់រួមមួយ នៅពេលដែលអ្នកដែលអនុវត្តតាមច្បាប់នោះ ចាប់ផ្តើមចាត់ទុកការអនុវត្តនោះជាកាតព្វកិច្ចមួយសម្រាប់ពួកគេ"។ George P. Fletcher & Jens David Ohlin, *Reclaiming Fundamental Principles of Criminal Law in the Darfur Case*, 3 J. INT'L CRIM. JUST. ទំព័រ ៥៣៩, ៥៥៦ (២00៥)។ វាត្រូវបានកត់សម្គាល់ថា "[វា]លំបាកខ្លាំងណាស់ក្នុងការបង្កើតបាននូវការព្រមព្រៀងគ្នាមួយដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើឱ្យច្បាប់មួយមានសុពលភាពជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ *ដូចដើងទំព័រខាងលើ*។

[39] ចម្លើយតប, កថាខណ្ឌ ៣៤។

យ៉ាងងាយស្រួលថែមទៀត[40]។ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បណ្តារដ្ឋទាំងអស់អាចអនុវត្ត និង សម្តែងនូវការយល់ឃើញថាខ្លួនមានកាតព្វកិច្ចផ្លូវច្បាប់ដើម្បីធ្វើការអភិវឌ្ឍការទទួលខុសត្រូវ JCE។ ដូច្នេះ ការយកទទ្បីករណី Grotian moment មកអនុវត្ត វាមានការលំបាកយ៉ាងខ្លាំង ក្នុងការបង្កើតទស្សនៈច្បាប់ និងការអនុវត្តរបស់រដ្ឋឱ្យមានលក្ខណៈដូចគ្នានៅក្នុងវិស័យច្បាប់ ដែលរដ្ឋទាំងអស់[41] នឹងមានសិទ្ធិសម្រេចចំពោះការវិវឌ្ឍន៍ និងការទទួលស្គាល់ការទទួលខុសត្រូវ JCE និងលើសពីនេះទៀត ធាតុផ្សំនៃការទទួលខុសត្រូវ JCE។ ដូចដែលមានបញ្ជាក់ច្បាស់នៅក្នុង បណ្តឹងឧទ្ធរណ៍ ការទទួលខុសត្រូវ JCE គឺមិនអាចទទួលយកបាន និងមិនត្រូវបានកំណត់ និយមន័យឱ្យបានដូចគ្នា ពីបណ្តារដ្ឋទាំងអស់ ឬរដ្ឋភាគច្រើនឡើយ។ ហេតុដូច្នេះ JCE មិនអាចជា លទ្ធផលនៃ Grotian moment ឡើយ។

២២. នៅក្នុងកថាខណ្ឌ៣៥ ក.ស.ព អះអាងថា "គណៈកម្មាធិការច្បាប់អន្តរជាតិ របស់អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ធម្មនុញ្ញ Nuremberg ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ព្រមទាំង ការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមក្រោយសង្គ្រាមលោកលើកទី២ (រឿងក្តីចំនួនដប់ត្រូវបានដកស្រង់ ដាក់ក្នុងរឿងក្តី *Tadić*) បានបង្កើតនូវគំរូជាអន្តរជាតិ សម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល"។ របាយការណ៍គណៈកម្មាធិការច្បាប់របស់អង្គការសហប្រជាជាតិ ("អង្គការសហប្រជាជាតិ") ដែលត្រូវបានដកស្រង់គឺពីឆ្នាំ១៩៩៦ ដែលនៅក្រោយរយៈកាលយុត្តាធិការនៃ អ.វ.ត.ក។ លើសពីនេះទៀត របាយការណ៍នេះមិនបានធ្វើការប្រកាសឱ្យបានទូលំទូលាយបែបនេះឡើយ។ របាយការណ៍នេះមិនបានបញ្ជាក់ថា វា "បានបង្កើតគំរូទាំងស្រុង សម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ"។ របាយការណ៍នេះបានបញ្ជាក់ថា "គោលការណ៍នៃការទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ត្រូវបានបង្កើតឡើងយ៉ាងច្បាស់នៅ Nurnberg"[42]។ សេចក្តីថ្លែងការណ៍នេះ មិនបានគាំទ្រការអះអាងរបស់ ក.ស.ព ឡើយថា <u>ការទទួលខុសត្រូវ JCE</u> ត្រូវបានបង្កើតឡើងយ៉ាងច្បាស់នៅ Nuremberg។ លើសពីនេះទៀត ការយោងទៅលើ JCE (ជាពិសេស JCE III) ថាជាទម្រង់នៃ*ការទទួលខុសត្រូវព្រហ្មទណ្ឌជា*

---

[40] *សូមមើល* MALCOLM N. SHAW, INTERNATIONAL LAW ទំព័រ៧៥-៧៦ (បោះពុម្ពដោយ Cambridge University Press ២០០៣)។

[41] បច្ចុប្បន្ននេះមានរដ្ឋជាសមាជិកធម្មនុញ្ញអង្គការសហប្រជាជាតិចំនួន ១៩២ រដ្ឋ។

[42] *របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារកិច្ចប្រជុំលើកទី៤៨របស់ខ្លួន,* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦, ឯកសារផ្លូវការណ៍របស់មហាសន្និបាត, កិច្ចប្រជុំលើកទី៥១, សេចក្តីបន្ថែមលេខ ១០, ទំព័រ១៩។

*បុគ្គល* គឺហួសបន្តិចពីអត្ថន័យច្បាប់ ដោយគិតអំពីធាតុផ្សំរួមនៅក្នុងទម្រង់នៃការទទួលខុសត្រូវនេះ[43]។ បន្ទាប់មក ក.ស.ព អះអាងថា មហាសន្និបាតអង្គការសហប្រជាជាតិ បានបញ្ជាក់ច្បាស់លាស់ជាឯកច្ឆន្ទលើគោលការណ៍ធម្មនុញ្ញ Nuremberg និងសេចក្តីសម្រេចរបស់តុលាការ Nuremberg ។ ក.ស.ព អះអាងថា ការបញ្ជាក់ដោយមហាសន្និបាតអង្គការសហប្រជាជាតិនេះ "បានបញ្ជាក់ច្បាស់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទាំងច្បាប់សារធាតុ និងទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ជាបុគ្គល (រួមទាំង ការទទួលខុសត្រូវ "ផែនការរួម")... ដែលដាក់ [ការទទួលខុសត្រូវផែនការរួម] ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចគ្នាទៅនឹងទស្សនជាសារវ័ន្តនៃការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌជាអន្តរជាតិ..."។ សេចក្តីសម្រេចរបស់មហាន្និបាតអង្គការសហប្រជាជាតិ មិនមានឥទ្ធិពល ឬអំណាចដើម្បី "សម្រេច" អំពីទស្សនាទានច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ មេធាវីការពារក្តីបានបង្ហាញរួចហើយថា គោលការណ៍ Nuremberg មិនបានបញ្ចូលការទទួលខុសត្រូវ JCE ឡើយ[44]។ ការទទួលខុសត្រូវផែនការរួម ត្រូវបានទទួលស្គាល់ ទាក់ទិនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព<u>តែប៉ុណ្ណោះ</u>[45]។ ដូច្នេះ ទោះបីជាសេចក្តីសម្រេច

[43] *សូមមើល* Elies van Sliedregt, *Criminal Responsibility in International Law, Liability Shaped by Policy Goals and Moral Outrage,* 14 EUR. J. CRIME, CRIM. L. & CRIM. JUST. ទំព័រ ៨១-៨២ (២០០៦)។

[44] *សូមមើល* បណ្តឹងឧទ្ធរណ៍, ឧបសម្ព័ន្ធ ក, ផ្នែក II, ឃ, ១, គ។

[45] ការអានដោយយកចិត្តទុកដាក់នូវគោលការណ៍ទាំងប្រាំពីរ ដែលមានរៀបរាប់នៅក្នុងរបាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ បង្ហាញឲ្យឃើញច្បាស់ថា ការទទួលខុសត្រូវលើផែនការរួម ត្រូវបានប្រមើលឃើញតែចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្តតែប៉ុណ្ណោះ។ *របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីកិច្ចប្រជុំលើកទីពីររបស់ខ្លួន,* ពីថ្ងៃទី៥ ខែមិថុនា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៥០, ឯកសារផ្លូវការណ៍របស់មហាសន្និបាត, កិច្ចប្រជុំលើកទីប្រាំ, សេចក្តីបន្ថែមលេខ ១២ (A/1316)។ គោលការណ៍ទាំងឡាយថែងផ្នែកដែលមានភាពទំនាក់ទំនងគ្នាដូចខាងក្រោម៖

*គោលការណ៍ទី VI*៖ ឧក្រិដ្ឋកម្មបង្ហាញបន្ទាប់ពីនេះគឺអាចត្រូវដាក់ទណ្ឌកម្មជាឧក្រិដ្ឋកម្មតាមច្បាប់អន្តរជាតិ៖

(*ក*) ឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្ត៖

(i) ការរៀបផែនការ ការត្រៀមរៀបចំ ការផ្តួចផ្តើមគំនិត ឬ ការចាប់ផ្តើមធ្វើសង្គ្រាមឈ្លានពាន ឬ សង្គ្រាមណាមួយដែលរំលោភបំពានលើសន្ធិសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង ឬការធានាអះអាង

(ii) ការចូលរួមនៅក្នុងផែនការរួម ឬការរួមគំនិតគ្នាដើម្បីធ្វើឲ្យបានសម្រេចនូវអំពើណាមួយដូចរៀបរាប់ក្នុងចំណុច(i)។

(*ខ*) ឧក្រិដ្ឋកម្មសង្គ្រាម៖

ការរំលោភបំពានច្បាប់ ឬទំនៀមទម្លាប់នៃសង្គ្រាម ដែលរាប់បញ្ចូលដោយមិនកម្រិតកំណត់ត្រឹមតែអំពើឃាតកម្ម ការធ្វើបាប ឬការនិរទេសប្រជាជនស៊ើវិលនៃទឹកដីកាន់កាប់ ឬក្នុងទឹកដីដែលខ្លួនកាន់កាប់ដើម្បីឲ្យចេញទៅធ្វើទាសករពលកម្ម ឬដើម្បីគោលបំណងណាមួយផ្សេងទៀត រអំពើឃាតកម្ម ឬការធ្វើបាបអ្នកទោសឈ្លើយសង្គ្រាម ឬមនុស្ស

របស់មហាន្និបាតអង្គការសហប្រជាជាតិ មានកម្លាំងអំណាចក្នុងការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនត្រូវបានគេបង្កើតឡើង ពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ JCE ឡើយ។

២៣. ក្នុងកថាខណ្ឌ ៣៦ ក.ស.ព ដកស្រង់សេចក្តីថ្លែងការណ៍ដែលបានធ្វើឡើងដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឆ្នាំ១៩៩៣ និងអះអាងថា វាបានបញ្ជាក់ពីភាពត្រឹមត្រូវក្នុងឆ្នាំ១៩៧៥ "ដោយសារតែគ្មានការវិវឌ្ឍន៍សំខាន់ផ្សេងៗទៀតក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ចន្លោះរវាងឆ្នាំ ១៩៧៥ និងពេលបង្កើតតុលាការ ICTY ក្នុងឆ្នាំ១៩៩៣" ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានបញ្ជាក់ថា លក្ខន្តិកៈតុលាការ ICTY ត្រូវបានព្រាងដើម្បីអនុវត្ត "វិធានច្បាប់មនុស្សធម៌

---

កំពុងស្ថិតនៅតាមសមុទ្រ អំពើសម្លាប់ចំណាប់ខ្មាំង អំពើប្លន់ទ្រព្យសម្បត្តិរដ្ឋ ឬទ្រព្យសម្បត្តិសាធារណៈ អំពើបំផ្លិចបំផ្លាញទីក្រុង ទីប្រជុំជន ឬភូមិនានាដោយគ្មានគ្រាប្រណី ឬបំផ្លាញខ្ទេចខ្ទីដោយមិនត្រឹមត្រូវតាមភាពចាំបាច់ ខាងយោធា។

(*គ*) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ:

អំពើឃាតកម្ម ការធ្វើឱ្យសាបសូន្យ ការយកទៅធ្វើជាទាសករ ការបណ្តេញចេញ និងអំពើអមនុស្សធម៌ដទៃទៀតដែលប្រព្រឹត្តប្រឆាំងនឹងប្រជាពលរដ្ឋស៊ីវិលណាមួយ ឬការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅពេលអំពើទាំងនេះត្រូវបានប្រព្រឹត្តឡើង ឬការធ្វើទុក្ខបុកម្នេញបែបនោះ ត្រូវបានបន្ត អនុវត្តន៍ឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្តណាមួយ ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ ឬជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្តណាមួយ ឬឧក្រិដ្ឋកម្មសង្គ្រាមណាមួយ។

*គោលការណ៍ទី VII៖* ការសមគំនិតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្ត ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលមានចែងក្នុងគោលការណ៍ទី VI តាមច្បាប់អន្តរជាតិគឺជាឧក្រិដ្ឋកម្ម។

វាមានភាពច្បាស់លាស់ដែលថាការលើកឡើងពី "ការចូលរួមក្នុងផែនការរួម" នៅក្នុងគោលការណ៍ទី VI ជាប់ទាក់ទងតែចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្តតែប៉ុណ្ណោះ ដោយសារវាត្រូវបានរៀបរាប់នៅក្រោមអនុផ្នែកនោះតែប៉ុណ្ណោះ ហើយ*មិន*មាននៅក្នុងអនុផ្នែកបន្ទាប់ទៀត ដែលយោងទៅលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ គោលការណ៍ទី VII លើកឡើង "ការសមគំនិត" ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងភាពសុខសាន្ត ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ពាក្យ "ការទទួលខុសត្រូវក្នុងផែនការរួម" និង "ការសមគំនិត" មិនត្រូវ ហើយមិនអាចត្រូវបានប្រើជំនួសគ្នាទៅវិញទៅមកបានទេ។ ការពិតដែលថាគោលការណ៍ទី VI និង VII ប្រើពាក្យពីរខុសគ្នា បង្ហាញថាការទទួលខុសត្រូវក្នុងផែនការរួម និងការសមគំនិត មិនមែនជាទស្សនទានដូចគ្នាទេ៖ ពាក្យទាំងនេះមិនអាចត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក បានឡើយ។

អន្តរជាតិ ដែលហួសពីវិមតិសង្ស័យ ថាជាផ្នែកមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[46]។ លក្ខន្តិកៈតុលាការ ICTY មិនមានបញ្ជាក់អំពី JCE ឡើយ។ ច្បាប់នេះ ត្រូវបានដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈនៅដំណាក់កាលក្រោយមកទៀត ដោយអង្គជំនុំជម្រះតុលាការកំពូល ICTY លើរឿងក្តី *Tadić* ។ លើសពីនេះទៀត បញ្ហាមិនគួរថាតើមានការវិវឌ្ឍសំខាន់ៗនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ឬយ៉ាងណានោះទេ ប៉ុន្តែថាតើការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈស៊ីសង្វាក់គ្នា និងទូលំទូលាយ មានអត្ថិភាពក្នុងឆ្នាំ១៩៧៥ ឬយ៉ាងណា។ ក.ស.ព បានដកស្រង់សំដីអ្នកអត្ថាធិប្បាយម្នាក់ដែលបានកត់សម្គាល់ថា "ប្រភពនៃទ្រឹស្តី JCE អាចត្រូវបានរកឃើញ ក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី២"[47]។ អ្នកអត្ថាធិប្បាយរូបនេះ មិនបានបញ្ជាក់ថា វាបានលេចឡើងយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយនៅពេលនោះ។

២៤. នៅក្នុងកថាខណ្ឌ ៣៧ ក.ស.ព អះអាងថា JCE មានប្រភពនៅក្នុងធម្មនុញ្ញ Nuremberg និងជាការរួមបញ្ចូលគ្នារវាងច្បាប់ខំមិនឡូ និងច្បាប់ស៊ីវិលឡូ។ ក.ស.ព មិនបានធ្វើការពន្យល់ថាហេតុអ្វី អ.វ.ត.ក ដែលមិនផ្អែកទៅលើការរួមបញ្ចូលគ្នារវាងទំនៀមទម្លាប់ច្បាប់ខំមិនឡូ និងច្បាប់ស៊ីវិលឡូដូចតុលាការមិនអចិន្ត្រៃយ៍នានានោះ គួរតែអនុវត្តនូវទស្សនាទានចំរុះបែបនេះ។ អ.វ.ត.ក គឺជាផ្នែកមួយនៃយុត្តាធិការស៊ីវិលឡូ។ ក.ស.ព អះអាងថា ការរួមបញ្ចូលគ្នារវាងច្បាប់ខំមិនឡូ និងច្បាប់ស៊ីវិលឡូនេះ តំណាងឱ្យ "ការសំយោគរវាងយុត្តាធិការផ្សេងៗទៀត" ដែលត្រូវបានបង្កើតឡើងនៅពេលដែល "ប្រទេសមហាអំណាចបានស្វែងរកការបង្កើតវិធីសាស្ត្រនៅក្នុងធម្មនុញ្ញ Nuremberg..."។ មេធាវីការពារក្តីបដិសេធការអះអាងណាដែលថា វិធីសាស្ត្រស៊ីសង្វាក់គ្នា និងច្បាស់លាស់មួយ ត្រូវបានយកមកពី Nuremberg។ សាលក្រមក្រោយសង្គ្រាមលោកលើកទី២ មានលក្ខណៈខ្លី ដោយមានការសម្អាងផ្អែកច្បាប់មានកំណត់ ដែលបង្ខំឱ្យអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ធ្វើការសន្និដ្ឋានអំពីទម្រង់នៃការទទួលខុសត្រូវ ដែលជនត្រូវចោទ

---

[46] ដូចដែលបានដកស្រង់នៅក្នុងចម្លើយតប, កថាខណ្ឌ ៣៦។

[47] ចម្លើយតប, កថាខណ្ឌ ៣៦, *ដកស្រង់ពីអត្ថបទនិពន្ធដោយ* Ciara Damgaard, មានចំណងជើងថា *The Joint Criminal Enterprise Doctrine: A "Monster Theory of Liability" or a Legitimate and Satisfactory Tool in the Prosecution of the Perpetrators of Core International Crimes?*, *នៅក្នុង* INDIVIDUAL CRIMINAL RESPONSIBILITY FOR CORE INTERNATIONAL CRIMES ទំព័រ១២៩, ១៣២, ១៣៥ (បោះពុម្ពដោយ Springer, ២០០៨) ("Damgaard") (គូសបញ្ជាក់បន្ថែម)។

ទីបំផុតត្រូវបានផ្តន្ទាទោស ដោយផ្អែកលើសេចក្តីថ្លែងរបស់អយ្យការ[48]។ ការដាក់បញ្ចូលគ្នានៃវិធីសាស្ត្រខុសគ្នា គ្រាន់តែគាំទ្រជំហររបស់មេធាវីការពារក្តីប៉ុណ្ណោះ ដែលអាចមិនមានការអនុវត្តរបស់រដ្ឋស៊ីសង្វាក់គ្នា និងទូលំទូលាយ ពាក់ព័ន្ធនឹងការទទួលខុសត្រូវ JCE ដោយសារតែវាមិនមែនជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានអនុវត្តដោយស៊ីសង្វាក់គ្នាទូទាំងយុត្តាធិការទាំងមូលឡើយ។ វាគឺជាទម្រង់ថ្មីមួយដែលត្រូវបានបង្កើតឡើងដោយចៅក្រមក្នុងរឿងក្តី *Tadić* ។

២៥. នៅក្នុងកថាខណ្ឌ ៣៨ ក.ស.ព អះអាងថា “តុលាការ Nuremberg និងច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានបង្កើតទស្សនាទាន “ផែនការរួម” ក្នុងទម្រង់របស់ខ្លួន ហេតុដូច្នេះបានកែប្រែផែនការរួមឱ្យក្លាយទៅជាអ្វីដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម”។ នៅក្នុងន័យដែលថាតុលាការទាំងនេះមិនបានអនុវត្តគោលការណ៍យ៉ាងត្រឹមត្រូវនោះ មេធាវីការពារក្តីយល់ស្របជាមួយនឹងសេចក្តីថ្លែងនេះ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនពិតឡើយដែលតុលាការក្រោយសង្គ្រាមលោកលើកទី២ទាំងនេះ បានបង្កើត និងអនុវត្តទស្សនាទានស៊ីសង្វាក់គ្នានោះ ចំពោះហេតុផលនានាដែលត្រូវបានបញ្ជាក់នៅក្នុងកថាខណ្ឌមុន។ ក.ស.ព បានអះអាងបន្ថែមទៀតថា តុលាការ Nuremberg បានប្រកាសថា សេចក្តីសន្និដ្ឋាននានារបស់ខ្លួនត្រូវបានធ្វើឡើង ដោយអនុលោមតាមគោលការណ៍ច្បាប់យ៉ាងត្រឹមត្រូវ។ ដោយសារតែតុលាការ Nuremberg ប្រកាសបែបនេះទោះបីជាយ៉ាងណាក៏ដោយ វាមិនមែនជាការពិតប្រាកដឡើយ[49]។ សាលក្រម ដែលកើតចេញមកពីតុលាការក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានគេរិះគន់ចំពោះកង្វះខាតនៃ ការសម្អាងហេតុផលផ្អែកច្បាប់ ដូចដែលបានគូសបញ្ជាក់ខាងលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍[50]។ លើសពី

---

[48] *សូមមើល* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤៥-៤៦។

[49] “ជាការសន្និដ្ឋានទូទៅ វិធាននានាដែលត្រូវបានអនុវត្តក្នុងការជំនុំជម្រះនេះ មិនមែនជាវិធាននៃច្បាប់អន្តរជាតិទេ។ មិនមានការប៉ុនប៉ងណាមួយដើម្បីឱ្យយល់ទាំងស្រុងចំពោះអ្វីដែលអាចការពារបានក្នុងច្បាប់អន្តរជាតិទេ ។ ជាក់ស្តែង ធម្មនុញ្ញ នេះគ្រាន់តែមានបំណងនាំខ្លួនចុងចោទមួយចំនួន យកមកកាត់ទោស និងដាក់ទោសតែប៉ុណ្ណោះ។ ឧទាហរណ៍ ខ្ញុំបានយោងទៅលើការពិភាក្សា ដែលមានគោលដៅបង្ហាញឱ្យដឹងពីទស្សនៈទានរបស់អាមេរិកចំពោះការសមគំនិត (American Concept of Conspiracy) មានន័យថាជាផែនការរួម ឬការរៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋ ។ អ្នកចូលរួមក្នុងទ្វីប (Continental participants) ក្នុងសន្និសិទនេះ មានការមន្ទិលសង្ស័យខ្លះដែរ ចំពោះការដាក់បញ្ចូលគោលគំនិត ដែលពួកគេមិនបានដឹង ក្នុងវិធាននានាក្នុងធម្មនុញ្ញទីក្រុងឡុងដ៍ ។” *ដកស្រង់ពីអត្ថបទនិពន្ធដោយ* Otto Kranzbuhler, មានចំណងជើង *Nuremberg Eighteen Years Afterwards*, *in* GUÉNAËL METTRAUX (ED.), PERSPECTIVES ON THE NUREMBERG TRIAL 436 (បោះពុម្ពដោយ Oxford University Press, 2008)។

[50] *សូមមើល* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៤៤-៤៥។

00486664



នេះទៀត កថាខណ្ឌមុនបង្ហាញនូវភាពមិនពិតនៃសេចក្តីថ្លែងនេះ។ វាពិភាក្សាអំពីការបង្កើតទម្រង់ដែលត្រូវបានកែប្រែនៃសំណើរបស់សហរដ្ឋអាមេរិក ឱ្យបញ្ចូលបទសមគំនិតទៅក្នុងលក្ខន្តិកៈរបស់តុលាការ Nuremberg។ នេះគឺជាការបង្កើតថ្មី មិនមែនជាគោលការណ៍ច្បាប់ត្រឹមត្រូវឡើយ។ អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* មិនចាំបាច់ផ្អែកជាសំខាន់ទៅលើរឿងក្តីដែលមិនច្បាស់លាស់ និងមិនត្រូវបានបោះពុម្ពផ្សាយឡើយ ប្រសិនបើតុលាការទាំងនេះបានអនុវត្តគោលការណ៍ច្បាប់ដែលមានលក្ខណៈត្រឹមត្រូវគ្រប់គ្រាន់នោះ[51]។

២៦. ក្នុងកថាខណ្ឌ ៣៩ ក.ស.ព អះអាង ដោយបានដកស្រង់សាលក្រមរបស់តុលាការ ICTY លើរឿងក្តី *Kupreškić* ថា យុត្តិសាស្ត្រពីតុលាការក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានចាត់ទុកថាជាការបកស្រាយតាមអាជ្ញាព្រឹត្តនៃធម្មនុញ្ញ និងសេចក្តីសម្រេចរបស់ Nuremberg និងបង្ហាញឱ្យឃើញថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដំបូង ការដកស្រង់សាលក្រមមួយរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មិនបានធ្វើឱ្យមានការថ្លែងជាទូទៅថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានចាត់ទុកថាមានអាជ្ញាព្រឹត្តឡើយ។ សំខាន់ជាងនេះទៀត នេះគឺជាបទបង្ហាញមិនត្រឹមត្រូវរបស់ *Kupreškić* ។ អង្គជំនុំជម្រះសាលាដំបូងនេះពិតណាស់បានបញ្ជាក់ថា :

> គេអាចនិយាយយ៉ាងដូច្នេះក្នុងករណីនេះថា សេចក្តីសម្រេចតុលាការមុនៗ អាចធ្វើឱ្យតុលាការជឿជាក់ថា សេចក្តីសម្រេចទាំងអស់នោះបានផ្អែកទៅលើវិធីសាស្រ្តត្រឹមត្រូវ ប៉ុន្តែ <u>សេចក្តីសម្រេចទាំងនោះមិនបានបង្ខំឱ្យមានសេចក្តីសន្និដ្ឋានយ៉ាងដូច្នេះ ដោយគ្រាន់តែការប្រើប្រាស់ឥទ្ធិពលដែលមានកន្លងមកនោះទេ</u>។
>
> ...
>
> <u>វាមិនអាចត្រូវបានគេបដិសេធឡើយថា តម្លៃដ៏សំខាន់គួរតែត្រូវបានភ្ជាប់ទៅនឹងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងនេះ ដូចជាតុលាការអន្តរជាតិ Nuremberg</u> ឬ Tokyo ឬក៏ភ្ជាប់ទៅនឹងតុលាការជាតិដែលដំណើរការ ដោយសារតែ និងពីព្រោះតែច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ច្បាប់របស់អង្គការនីតិបញ្ញត្តិដែលត្រូវបានអនុម័តរួមគ្នាក្នុងឆ្នាំ១៩៤៥ ដោយមហាអំណាចបួនប្រទេសដែលគ្រប់គ្រងគេនោះ ហើយដូច្នេះ ឆ្លុះបញ្ចាំងនូវកិច្ចព្រមព្រៀងជាអន្តរជាតិក្នុងចំណោមប្រទេសមហាអំណាច ស្តីអំពីច្បាប់ដែលអាច

[51] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៤០ រួមទាំងជើងទំព័រដែលជាប់ពាក់ព័ន្ធ។

> អនុវត្តបាន ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងយុត្តាធិការរបស់តុលាការដែលត្រូវបានយកមកប្រើ ដើម្បីសម្រេចលើបទឧក្រិដ្ឋទាំងនោះ។
>
> ...
>
> សរុបសេចក្តីមក តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជាតុលាការអន្តរជាតិ ត្រូវតែ<u>ពិចារណាឱ្យបានហ្មត់ចត់ទៅលើសេចក្តីសម្រេចរបស់តុលាការផ្សេងៗទៀត មុនពេលសម្រេចផ្អែកទៅលើករណីយុត្តិសាស្ត្ររបស់តុលាការទាំងនោះ ចំពោះច្បាប់ដែលមានស្រាប់</u>[52]។

លើសពីនេះទៀត មេធាវីការពារក្តីបានបង្ហាញរួចហើយអំពីវិការៈនៃសាលក្រមក្រោយសង្គ្រាមលោកលើកទី២[53]។ សាលក្រមទាំងនោះមិនអាចចាត់ទុកថាមានអាជ្ញាព្រឹត្តឡើយ ពីព្រោះសាលក្រមទាំងនោះ មានការសំអាងផ្អែកច្បាប់មានកំណត់ ហើយត្រូវបានចាត់ទុកថាជិតដាមទៅដោយយុត្តិធម៌សម្រាប់អ្នកឈ្នះ[54]។

---

[52] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kupreškić*, IT-95-16-T, សាលក្រម, ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២000, កថាខណ្ឌ ៥៤០-៥៤២ (គូសបញ្ជាក់បន្ថែម)។

[53] *សូមមើល* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៣៨-៤០។

[54] *សូមមើល*អត្ថបទនិពន្ធដោយ RICHARD H. MINEAR មានចំណងជើងថា VICTOR'S JUSTICE: THE TOKYO WAR CRIMES TRIAL 16 (1971). "បើសិនច្បាប់អន្តរជាតិបច្ចុប្បន្ន មិនមានភាពច្បាស់លាស់ និងមិនត្រូវបានគេពេញចិត្ត តួយ៉ាងទាក់ទងទៅនឹងការទទួលខុសត្រូវជាបុគ្គលចំពោះអំពើផ្សេងៗរបស់រដ្ឋនោះ មេដឹកនាំសម្ព័ន្ធមិត្តទាំងបួន (Big Four) នឹងរៀបចំតាក់តែងច្បាប់អន្តរជាតិ ដែលអំពើរបស់ប្រទេសអាល្លឺម៉ង់ និងជប៉ុន បានក្លាយជាអំពើឧក្រិដ្ឋ ហើយមេដឹកនាំម្នាក់ៗដែលជាសត្រូវត្រូវទទួលខុសត្រូវ" *សូមមើលផងដែរនូវ*អត្ថបទនិពន្ធដោយ Mirjan Damaska មានចំណងជើងថា *The Shadow Side of Command Responsibility*, 49 AM. J. COMP. L. 455, 486-87 (2001) ។ "វាមិនតម្រូវឱ្យមានការយល់ដឹងជ្រៅជ្រះក្នុងការសិក្សាសេចក្តីសម្រេចចិត្តនានា ដែលធ្វើឡើងដោយតុលាការយោធាក្រោយសង្គ្រាមលោកទី២ទេ ដើម្បីឱ្យយល់ដឹងថាសេចក្តីសម្រេចចិត្តទាំងនោះ មិនមានជាប្រភពច្បាស់លាស់បំផុតណាមួយ ដែលរំពឹងថានឹងមានការជម្រុញខ្លះដើម្បីឱ្យមានឥទ្ធិពលទៅលើច្បាប់អន្តរជាតិទំនើបឡើយ។ តុលាការទាំងនេះ ដែលត្រូវប្រឈមមុខនឹងបុគ្គលគួរឱ្យស្អប់ខ្ពើម ដែលត្រូវបានចោទពីបទឧក្រិដ្ឋគួរឱ្យរន្ធត់ មិនគួរបិទបាំងយើងនូវអង្គហេតុដែលបទដ្ឋានច្បាប់ដែលពួកគេបានបង្កើតឡើង (ជាពិសេសក្នុងតំបន់ចុងបូព៌ា) មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីផ្តល់ការយល់ដឹងអំពីច្បាប់ឧក្រិដ្ឋកម្ម ក្នុងបំណងមនុស្សធម៌។ ដូចអ្នកប្រាជ្ញអន្តរជាតិល្បីឈ្មោះម្នាក់បានលើកឡើងយូរមកហើយ ជារឿយៗ បទដ្ឋានទាំងនេះ មានបំណងឱ្យមេធាវីភ្លេចបទដ្ឋានទាំងអស់នេះឱ្យឆាប់បំផុតតាមតែអាចធ្វើបាន។ ទាក់ទងនឹងគោលបំណងបច្ចុប្បន្ន ចរិក ទូទៅរបស់បទដ្ឋានទាំងនេះ មានលក្ខណៈធូន់ធូរដោយគ្មានភាពរៀនខ្នាស់ ដែលជាការត្រឹមត្រូវអាចចាត់ទុកបានថាជាប្រភពចំបងនៃការកើនឡើងនូវការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលនៅជាប់ជាមួយក្នុងការទទួលខុសត្រូវរបស់ថ្នាក់លើ (command responsibility)" *សូមមើលផងដែរនូវ*អត្ថបទនិពន្ធដោយ Curt Hessler មានចំណងជើងថា *Command Responsibility for War Crimes*, 82 Yale L.J.

២៧. នៅក្នុងកថាខណ្ឌ ៤០ ក.ស.ព អះអាងថា ការវិភាគលើរឿងក្តីជាច្រើនរបស់ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ បានគាំទ្រសេចក្តីសន្និដ្ឋានដែលថា ការទទួលខុសត្រូវ JCE ត្រូវបានតុលាការទាំងនោះប្រើប្រាស់នៅឆ្នាំ១៩៤៦-១៩៤៧។ ទោះបីជាវាមានលក្ខណៈច្បាស់លាស់ដែលថា រឿងក្តីទាំងនេះពិតជាប្រើប្រាស់ការទទួលខុសត្រូវ JCE ក៏ដោយ ក៏ការប្រើប្រាស់ការទទួលខុសត្រូវ JCE នៅក្នុងរឿងក្តីទាំងនេះ នឹងមិនគ្រប់គ្រាន់ក្នុងការបង្ហាញនូវការអនុវត្តរបស់រដ្ឋដ៏ស៊ីសង្វាក់គ្នា និងទូលំទូលាយឡើយ។ លើសពីនេះទៀត យោងតាមអ្នកអត្ថាធិប្បាយម្នាក់ រឿងក្តីទាំងនេះ ដែលត្រូវបានគេធ្វើការជំនុំជម្រះអនុលោមតាមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ "មិនអាចចាត់ទុកថាជាផ្នែកនៃច្បាប់អន្តរជាតិឡើយ ដោយសារតែវាត្រូវបានអនុម័តដោយអំណាចនីតិបញ្ញត្តិនៅប្រទេសអាឡឺម៉ង់ (ក្រុមប្រឹក្សាត្រួតពិនិត្យសម្ព័ន្ធមិត្ត)។ ជាលទ្ធផល សាលក្រមដែលបានសម្រេចអនុលោមតាមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ មិនបានបង្កើតជាករណីយុត្តិសាស្ត្រអន្តរជាតិដែលមានសុពលភាពឡើយ ហើយ "គោលការណ៍នៃការចូលរួមក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ" ដែលត្រូវបានប្រកាសនៅពេលសវនាការទាំងនេះ "មិនមានសុពលភាពជាបន្តបន្ទាប់មកទៀតឡើយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ""[55]។ ក.ស.ព កត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* បានផ្អែកមួយផ្នែកលើរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ ដែលបានប្រើប្រាស់ការទទួលខុសត្រូវ JCE និងបានអះអាងថា ខ្លួនបានរកឃើញនូវរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ ចំនួនដប់ប្រាំមួយបន្ថែមទៀត ដែលបានប្រើប្រាស់ការទទួលខុសត្រូវ JCE។ អង្គហេតុដែល ក.ស.ព បានរកឃើញរឿងក្តីបន្ថែមទៀត ដែលអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* មិនអាចរកឃើញនោះ បង្ហាញថា វាមានការលំបាកក្នុងការកំណត់ថាទម្រង់នៃការទទួលខុសត្រូវអ្វី ដែលត្រូវបានអនុវត្តនៅក្នុងរឿងក្តីជាច្រើនក្រោយសង្គ្រាមលោកលើកទី២នោះ ពីព្រោះសាលក្រម មានលក្ខណៈខ្លី និងមិនមានការសំអាងហេតុផលផ្នែកច្បាប់ឲ្យបានគ្រប់គ្រាន់នោះ។ ក.ស.ព អះអាងថា រឿងក្តីទាំងនេះ បានបញ្ជាក់យ៉ាងច្បាស់នូវអត្ថន័យនៃការទទួលខុសត្រូវផែនការរួម ដែលបច្ចុប្បន្ននេះគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម។ វាពិបាកក្នុងការស្រមៃថា បញ្ហានេះអាចក្លាយទៅជាបែបហ្នឹងដោយរបៀបណា ដោយពិចារណាថា ការចោទប្រកាន់តាម

---

1274, 1275 (1972-1973)។ "ការសម្រេចចិត្តភាគច្រើន គឺជាការប៉ុនប៉ងរបស់អង្គជំនុំជម្រះក្នុងការផ្តល់ការគាំទ្រភស្តុតាងផ្លូវចិត្ត និងផ្លូវច្បាប់ទាំងអស់ដែលអាចធ្វើបាន"។

[55] *ដកស្រង់ពីអត្ថបទនិពន្ធដោយ* Attila Bogdan មានចំណងជើងថា *Individual Criminal Responsibility in the Execution of a "Joint Criminal Enterprise" in the Jurisprudence of the* ad hoc *International Tribunal for the Former Yugoslavia*, 6 INT'L CRIM. L. REV. 63, 100 (2006)

ច្បាប់ជាតិរាប់ពាន់ករណី ក្រោមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ១០ ត្រូវបានផ្អែកលើទម្រង់នៃការទទួលខុសត្រូវជាច្រើន មិនមែនផ្អែកតែទៅលើទ្រឹស្តីនៃគោលបំណងរួមឡើយ[56] ដែលខុសពីការទទួលខុសត្រូវ JCE ពីព្រោះវាត្រូវបានគេអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍នានា។ ក.ស.ព បានផ្តល់នូវសម្រង់បាយការណ៍ពីរ របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ[57] និងបានអះអាងថា "ស្របគ្នាតាមសេចក្តីពន្យល់នេះ" សេចក្តីសម្រេច JCE លើរឿងក្តី *Ojdanić*[58] បានរកឃើញថា ការទទួលខុសត្រូវផែនការរួម និងការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម មានលក្ខណៈដូចគ្នា។ សេចក្តីពន្យល់ ដែលបានដកស្រង់ពីរបាយការណ៍របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ គ្រាន់តែពន្យល់អំពីភាពខុសគ្នារវាងបទសមគំនិត និងការប្រព្រឹត្តតាមផែនការរួមប៉ុណ្ណោះ។ វាមិនបានបញ្ជាក់អំពីការទទួលខុសត្រូវ JCE ឡើយ ហើយពិតជាមិនដូចគ្នាទៅនឹងការទទួលខុសត្រូវផែនការរួមឡើយ។ សេចក្តីសម្រេច JCE លើរឿងក្តី *Ojdanić* <u>ពិតជា</u>បានបញ្ជាក់ថា ពាក្យទាំងនេះអាចត្រូវបានយកមកប្រើជំនួសគ្នាបាន ប៉ុន្តែ ក្នុងកាលៈទេសៈណាក៏ដោយ នេះ<u>មិនមែន</u>មានន័យថា "ផែនការរួម" ដូចដែលវាត្រូវបានគេយល់ដឹងនៅក្នុងគោលការណ៍ Nuremberg (អនុវត្តតែចំពោះបទឧក្រិដ្ឋប្រឆាំងសន្តិភាពប៉ុណ្ណោះ) អាចស្មើគ្នាទៅនឹងការទទួលខុសត្រូវ JCE ដូចដែលត្រូវបានគេយកអនុវត្តនៅតុលាការមិនអចិន្ត្រៃយ៍ឡើយ។

២៨. ក្នុងកថាខណ្ឌ ៤១ ក.ស.ព ទទួលស្គាល់ថា មាន "ឧទាហរណ៍តែមួយចំនួនតូចប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងយុត្តិសាស្ត្រជាតិ ដែលអនុវត្តទម្រង់នានានៃការទទួលខុសត្រូវ JCE"។ ក្រោយមក ក.ស.ព បានប្រកាសថា សេចក្តីសម្រេចរបស់តុលាការ Jerusalem District Court និងសេចក្តីសម្រេចរបស់តុលាការកំពូលប្រទេសអ៊ីស្រាអែល "បង្ហាញថា គិតត្រឹមឆ្នាំ១៩៦១ តុលាការជាតិនានា

---

[56] *សូមមើល* M. CHERIF BASSIOUNI, CRIMES AGAINST HUMANITY IN INTERNATIONAL CRIMINAL LAW ទំព័រ ៥៣០-៣៥ (ប្រែសម្រួលលើកទី២. បោះពុម្ពដោយ Kluwer Law International, ១៩៩៩)។

[57] សេចក្តីស្រង់ដែលផ្តល់ឱ្យដោយ ក.ស.ព មានដូចខាងក្រោម៖ "ការចោទប្រកាន់ត្រូវមានការបង្ហាញឱ្យឃើញបន្ថែមអំពីអត្ថិភាព នៃផែនការរួម [និង] នៅពេលអត្ថិភាព ត្រូវបង្ហាញការចោទប្រកាន់អាចផ្អែកលើវិធាន ដែលមាននៅក្នុងប្រព័ន្ធជាច្រើននៃច្បាប់ដែលជនទាំងឡាយណា ចូលរួមក្នុងផែនការរួម ដើម្បីប្រព្រឹត្តិបទល្មើសដែលប្រព្រឹត្តិដោយជនម្នាក់ ក្នុងចំណោមនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបទល្មើសនោះ ដោយអនុលោមតាមច្បាប់ព្រហ្មទណ្ឌ" ។

[58] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Milutinović និងអ្នកផ្សេងទៀត*, IT-99-37-AR72, សេចក្តីសម្រេចលើពាក្យសុំរបស់ Dragoljub Ojdanić ប្រឆាំងនឹងយុត្តាធិការ – *សហឧក្រិដ្ឋកម្មរួម*, ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ("សេចក្តីសម្រេច JCE ក្នុងរឿងក្តី *Ojdanić*")

បានទទួលស្គាល់រួចទៅហើយចំពោះសហឧក្រិដ្ឋកម្មរួម ដែលបានវិវឌ្ឍន៍ទៅតាមច្បាប់ និង យុត្តិសាស្ត្រនានាក្រោយពីសង្គ្រាមលោកលើកទី២ បានបញ្ចប់ភ្លាមៗ”។ នេះអាច បង្ហាញថា តុលាការក្នុងស្រុកចំនួនពីរនៅពេលនោះ បានទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវរួមគ្នា ប៉ុន្តែ ពិតណាស់ មិនមានភស្តុតាងបង្ហាញអំពីការទទួលស្គាល់ទូលំទូលាយអំពីការទទួលខុសត្រូវ JCE ឡើយ។

២៩. នៅក្នុងកថាខណ្ឌ ៤២ ក.ស.ព បញ្ជាក់ថា ចេតនាជាក់ច្បាស់ចំពោះការទទួលខុសត្រូវអំពើ ប្រល័យពូជសាសន៍តាមរយៈសហឧក្រិដ្ឋកម្មរួម គឺជាចេតនាជាក់លាក់។ មេធាវីការពារក្តីយល់ស្របថា ប្រសិនបើសហឧក្រិដ្ឋកម្មរួមត្រូវបានអនុវត្ត អ្នកចូលរួមនីមួយៗនៅក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវតែមានកម្រិតនៃចេតនាដែលតម្រូវដោយឧក្រិដ្ឋកម្មដែលបានគូសបញ្ជាក់។ ដូច្នេះ ជនត្រូវចោទ/ជនជាប់ចោទ មិនអាចត្រូវបានផ្តន្ទាទោសអំពីអំពើប្រល័យពូជសាសន៍តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមបានឡើយ លុះត្រាតែជននោះមានចេតនាជាក់លាក់ក្នុងការបំផ្លាញទាំងស្រុង ឬផ្នែកខ្លះទៅលើក្រុមជាតិពិន្ទុ ជនជាតិ ពូជសាសន៍ ឬសាសនា។ ដូច្នេះ នេះនឹងច្រានចោលចំពោះការទទួលខុសត្រូវអំពើប្រល័យពូជសាសន៍ តាមរយៈសហឧក្រិដ្ឋកម្មរួមទម្រង់III។ ប្រសិនបើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងនៅខាងក្រៅផែនការរួម ស្ថិតក្រោម JCE III អ្នកចូលរួមនៅក្នុងផែនការនោះ អាចទទួលខុសត្រូវ ដរាបណាឧក្រិដ្ឋកម្មនៅខាងក្រៅនេះ គឺជាផលវិបាកជាធម្មជាតិ និងអាចព្យាករណ៍ទុកជាមុនបានអំពីគោលបំណងរួមដែលមានអនុភាព[59]។ នេះគឺជាកម្រិតនៃធាតុអត្តនោម័ត *(mens rea)* ដែលមានលក្ខណៈទាបមែនទែន ជាងចេតនាជាក់លាក់ក្នុងបទប្រល័យពូជសាសន៍។ ក.ស.ព បានលើកឡើងបន្ថែមទៀតអំពី សាលក្រមលើរឿងក្តី *Eichmann* នៅក្នុងកថាខណ្ឌនេះ។ ក.ស.ព ដកស្រង់ដោយភ័ន្តច្រឡំអំពីតុលាការកំពូលប្រទេសអ៊ីស្រាអែល ដែលបញ្ជាក់ថា “ប្រសិនបើមានការព្រមព្រៀងជាឯកច្ឆន្ទទៅលើសេចក្តីថ្លែងការណ៍ស្តីពីច្បាប់ដែលមានជាធរមាន ពីប្រទេសទាំង ៥៨ នោះ វាហាក់បីដូចជា បានសេចក្តីថា ការប្រកាសទទួលស្គាល់ច្បាប់ជាធរមាននោះពុំមានន័យអ្វីក្រៅអំពីថា វាជាភស្តុតាងឯកច្ឆន្ទនៃការទទួលស្គាល់ច្បាប់ជាធរមាន ហើយការព្រមព្រៀងដោយមតិភាគច្រើនបែបនេះ ផ្តល់តម្លៃយ៉ាងពិសេសក្នុងការកំណត់អំពីច្បាប់ជាធរមាន”។ គេអាចសន្មតថា តុលាការជំនុំជម្រះទោសលើរឿងក្តី *Eichmann* កំពុងពិភាក្សាអំពីការទទួលខុសត្រូវ JCE នៅទីនេះ។ វាមិនមែនបែបនេះឡើយ។

[59] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Vasiljević*, IT-98-32-A, សាលដីកា, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤, កថាខណ្ឌ ៩៩។

តុលាការជំនុំជម្រះទោសលើរឿងក្តី *Eichmann* កំពុងពិភាក្សាអំពីយុត្តាធិការលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយបដិសេធទ្រឹស្តីនៃការការពារខ្លួនរបស់នៃបញ្ជារបស់ថ្នាក់លើ។

៣០. នៅក្នុងកថាខណ្ឌ ៤៣ ក.ស.ព សន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមមានអត្ថិភាពជាច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥-១៩៧៩។ មេធាវីការពារក្តី បដិសេធសេចក្តីសន្និដ្ឋាននេះ ដោយមានហេតុផលដូចដែលបានបញ្ជាក់ជូនខាងលើ[60]។ ផ្តល់ជូននូវឧទាហរណ៍មួយដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍ ប្រសិនបើសហឧក្រិដ្ឋកម្មរួម ត្រូវបានសម្រេចយ៉ាងច្បាស់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥-១៩៧៩ ហេតុអ្វីបានជាអ្នកធ្វើសេចក្តីព្រាងនៃលក្ខន្តិកៈរបស់តុលាការ ICC បានសម្រេចមិនបញ្ចូលសហឧក្រិដ្ឋកម្មរួម?

**ខ. JCE មិនអាចអនុវត្តបានឡើយនៅ អ.វ.ត.ក**

៣១. នៅក្នុងកថាខណ្ឌទី ៤៤ កសព គ្រាន់តែផ្តល់សេចក្តីថ្លែមមួយចំពោះផ្នែកនេះ ។ ប៉ុន្តែមេធាវីការពារក្តីជំទាស់ទៅនឹងការអះអាងរបស់ កសព ដែលថា លោក អៀង សារី បានដឹងគ្រប់គ្រាន់ថាការចូលរួមរបស់គាត់នៅក្នុង JCE ដែលត្រូវចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងដាក់ឱ្យគាត់ទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើដែលត្រូវបានប្រព្រឹត្តស្របតាមការចូលរួមនេះ ហើយទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវបានចែងយ៉ាងច្បាស់ ឬ មិនច្បាស់លាស់នៅក្នុងឯកសាររបស់តុលាការ ។

*JCE មិនអាចយល់បាន និង មិនអាចដឹងជាមុននៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩*

៣២. នៅក្នុងកថាខណ្ឌទី ៤៥ កសព គ្រាន់តែស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធគោលជំហររបស់មេធាវីការពារក្តីដែលថា JCE មិនអាចអនុវត្តបាននៅកម្ពុជានៅអំឡុងពេលយុត្តាធិការពេលវេលារបស់ អវតក ហើយដូច្នេះ ការអនុវត្ត JCE នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព ។ មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលយកគោលជំហររបស់ខ្លួន ដែលត្រូវគាំទ្រដោយមូលដ្ឋានសំអាងផ្លូវច្បាប់ និងសំអាងហេតុ ។

៣៣. នៅក្នុងកថាខណ្ឌទី ៤៦ កសព ថ្លែងយ៉ាងត្រឹមត្រូវថាច្បាប់បង្កើត អវតក ដាក់បញ្ចូលមាត្រា ១៥(១) នៃកតិកាសញ្ញា ICCPR ។ កតិកាសញ្ញា ICCPR មិនមែនជាប្រភពតែមួយគត់ដើម្បី

---

[60] *សូមមើល* បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ ៣៦-៦៥។

ពិចារណានោះទេ ដូចដែលបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍[61] JCE ត្រូវតែបានបញ្ចូលទៅក្នុងច្បាប់ជាតិនៅពេលវេលាពាក់ព័ន្ធសិន ដូចដែលក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហាមឃាត់ការអនុវត្តច្បាប់ជាប្រតិសកម្មអញ្ចឹងដែរ ។

៣៤. នៅក្នុងកថាខណ្ឌទី ៤៧ កសព គ្រាន់តែពិភាក្សាកតិកាសញ្ញា ICCPR ហើយបានអះអាងថាគេត្រូវតែបង្ហាញឲ្យឃើញថាៈ ១) JCE បានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា ឬ ច្បាប់ទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥ និង ២) ដើមបណ្តឹងឧទ្ធរណ៍បានដឹងគ្រប់គ្រាន់ថាការចូលរួមរបស់ពួកគេនៅក្នុង JCE នឹងដាក់ឲ្យពួកគេទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើដែលបានប្រព្រឹត្ត ស្របតាមការចូលរួមនេះ ។ ចំនុចនេះមិនអើពើចំពោះករណីដែលថា វាមិនគ្រប់គ្រាន់ទេ បើគ្រាន់តែ JCE កើតមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ ។ JCE ត្រូវតែមានអត្ថិភាពនៅក្នុងច្បាប់កម្ពុជានៅពេលនោះ ស្របតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦[62] ផងដែរ។

៣៥. នៅក្នុងកថាខណ្ឌទី ៤៨ កសព អះអាងថាគោលការណ៍នីត្យានុកូលភាពតម្រូវថា ការទទួលខុសត្រូវ ត្រូវតែអាចព្យាករណ៍បានជាមុន និងស្វែងរកបានគ្រប់គ្រាន់នៅពេលវេលាពាក់ព័ន្ធ ។ ដោយបានយោងសំដៅលើយុត្តិសាស្ត្ររបស់ ICTY កសព អះអាងថា ចំនុចនេះមិនបានរារាំងតុលាការពីការបកស្រាយ ឬ បំភ្លឺធាតុផ្សំនៃឧក្រិដ្ឋកម្មណាមួយនោះទេ ឬក៏មិនបានរារាំងតុលាការឲ្យអភិវឌ្ឍន៍ច្បាប់ឲ្យបានជឿនលឿននោះដែរ ។ គោលការណ៍នីត្យានុកូលភាពតម្រូវថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ត្រូវតែអាចព្យាករណ៍បានជាមុន និងស្វែងរកបានគ្រប់គ្រាន់ ។ ប៉ុន្តែការអះអាងរបស់ កសព ទាក់ទងនឹងការបកស្រាយ ឬ ការបំភ្លឺពីបទល្មើស អាចអនុវត្តយ៉ាងសមស្របនៅក្នុងយុត្តាធិការច្បាប់ common law[63] ។

៣៦. កថាខណ្ឌទី ៤៩ កសព អះអាងថា បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាយល់បានដឹងយ៉ាងគ្រប់គ្រាន់ថា អំពើដែលគាត់បានប្រព្រឹត្ត នឹងនាំឲ្យគាត់ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្រោម JCE ប្រសិនបើមានកត្តាពីរកើតឡើង ។ កសព បានធ្វើបញ្ជីរាយនាមកត្តាទាំងពីរនេះ ហើយបានសំអាងលើ

---

[61] កថាខណ្ឌទី ៧២-៧៣ នៃសូមមើលបណ្តឹងឧទ្ធរណ៍ ។

[62] ដូចខាងលើ ។

[63] *សូមមើល* Mohamed Shahabuddeen, *Does the Principle of Legality Stand in the Way of Progressive Development of the Law?*, 2 J. INT'L CRIM. JUST. 1007, 1012 (2004) ។

សេចក្តីសម្រេច JCE ក្នុងករណី *Ojdanić*[64] ។ កត្តាទាំងនេះមាន: (១) ចរិតលក្ខណៈ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និង (២) អត្ថិភាពនៃសាលក្រមរបស់តុលាការ, លិខិតុបករណ៍អន្តរជាតិ និងបទបញ្ញត្តិក្នុងស្រុកដែលទទួលស្គាល់ទម្រង់នៃការទទួលខុសត្រូវ JCE ។ សេចក្តីសម្រេច JCE ក្នុងករណី *Ojdanić* បានបញ្ជាក់ថា តុលាការត្រូវតែធ្វើការពិចារណាលើកត្តាទាំងនេះ នៅពេលសម្រេចពីភាពអាចព្យាករណ៍បាន ។ ប៉ុន្តែ សេចក្តីសម្រេចនេះមិនបានវាយនាមចំណុចទាំងនេះថាជាកត្តាអ្វីនោះទេ ដែលអាចមានន័យថាបញ្ជិតបញ្ជៀងថា មានវាយតម្លៃដាក់លាក់មួយ។ ពុំមានការគូសបញ្ជាក់ថាកត្តាទាំងនេះ គឺសម្រាប់តែការពិចារណាទេ ហើយក៏មិនមានការបញ្ជាក់ថា ជនជាប់ចោទអាចត្រូវបានគេចាត់ទុកថាបានដឹងយ៉ាងគ្រប់គ្រាន់ដែរ ប្រសិនបើ "កត្តា" ទាំងនេះកើតឡើងមែននោះ ។ សេចក្តីសម្រេច JCE ក្នុងករណី *Ojdanić*E ពិតជាបានបញ្ជាក់ថា "នៅក្នុងករណីនេះ ... មានសេចក្តីសម្រេចរបស់តុលាការ លិខិតុករណ៍អន្តរជាតិ និងបទប្បញ្ញត្តិជាតិដែល... នឹងបានផ្តល់ឱ្យគាត់នូវការយល់ដឹងសមហេតុផលថា បទដ្ឋាននោះនឹងដាក់គាត់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប្រសិនបើគាត់បានរំលោភលើបទប្បញ្ញត្តិទាំងនោះ"។ អង្គជំនុំជម្រះតុលាការកំពូល មិនបានធ្វើការសន្និដ្ឋានជាទូទៅទេថា ប្រសិនបើ "កត្តាទាំងនេះត្រូវបានឆ្លើយតប នោះការយល់ដឹងគ្រប់គ្រាន់ អាចត្រូវបានគេចាត់ទុកថាពិតជាមានមែន ។ កសព អះអាងបន្ថែមទៀតថា "មានការប្រើប្រាស់យ៉ាងទូលំទូលាយនូវការទទួលខុសត្រូវប្រភេទ JCE ទាំងនៅក្នុងច្បាប់ប្រព័ន្ធ common law និងប្រព័ន្ធច្បាប់ស៊ីវិល" ប៉ុន្តែ កសព ខកខានមិនបានផ្តល់មូលដ្ឋានសំអាងផ្លូវច្បាប់ដើម្បីគាំទ្រការដល់អំណះអំណាងរបស់ខ្លួនឡើយ។ ម្យ៉ាងទៀត "ការទទួលខុសត្រូវប្រភេទ JCE" មិនអាចដូចគ្នានឹងការទទួលខុសត្រូវ JCE" បានឡើយ ។ កសព មិនបានបង្ហាញថាជនត្រូវចោទបានយល់ដឹងគ្រប់គ្រាន់ថា គាត់ត្រូវទទួលខុសត្រូវ JCE បើផ្អែកតាមកត្តាទាំងពីរនេះ។ កសព មិនបានដោះស្រាយលើអំណះអំណាងរបស់មេធាវីការពារក្តីដែលថា ប្រសិនបើមានការវាយតម្លៃដោយឥតលំអៀងថាតើបទល្មើសអាចត្រូវបានដឹងជាមុនយ៉ាងគ្រប់គ្រាន់ ត្រូវបានប្រើប្រាស់ជាមួយ JCE III នោះជនជាប់ចោទអាចត្រូវទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ ដែលគាត់មិនអាចដឹងជាមុន[65] នោះទេ។

---

[64] កថាខណ្ឌទី ៣៩-៤២ នៃសេចក្តីសម្រេច *Ojdanić* ។

[65] កថាខណ្ឌទី៦២, ៧៧ នៃបណ្តឹងឧទ្ធរណ៍ ។

៣៧. កថាខណ្ឌទី ៥០ កសព បកស្រាយមិនត្រឹមត្រូវនូវអំណះអំណាងរបស់មេធាវីការពារក្ដីទាក់ទងនឹងការសំអាងរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងក្ដី *Tadić* លើរឿងក្ដីដែលមិនទាន់ផ្សព្វផ្សាយ និងការសង្ខេបលើសេចក្ដីវិនិច្ឆ័យជាលាយលក្ខណ៍អក្សរ ។ មេធាវីការពារក្ដីពិភាក្សាលើចំនុចនេះនៅពេលបង្ហាញពីមូលហេតុអ្វីបានជាអង្គជំនុំជម្រះតុលាការកំពូលក្នុងក្ដី *Tadić* មានកំហុសនៅក្នុងការយល់ឃើញពីអត្ថិភាពនៃ JCE នៅក្នុងទម្លាប់អន្តរជាតិ ដោយមិនបានពិភាក្សាលើភាពអាចយល់បាននោះ ។ ប៉ុន្តែ វាជាការពិតដែលថាជនត្រូវចោទប្រហែលជាមិនបានដឹងអំពីសាលក្រមទាំងនោះទេ។ ម្យ៉ាងទៀត បើទោះបីជាមានការអះអាងរបស់ កសព ថារបាយការណ៍របស់គណៈកម្មាធិការឧក្រិដ្ឋម្មសង្គ្រាមនៃអង្គការសហប្រជាជាតិឆ្នាំ ១៩៤៩ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក៏ដោយ ក៏ជនត្រូវចោទមិនជាទំនងមានសំណៅនៃរបាយការណ៍ដែលមានកម្រាស់ដ៏ក្រាស់បែបនេះដែរ បើពិចារណាលើកាលៈទេសៈនៅពេលនោះ ។ ដោយពុំបានប្រកាន់យកដោយផ្ទាល់នូវជំហររបស់ខ្លួន កសព បានបង្ហាញថា សារណារបស់អ្នកមិនមែនជាភាគីតុលាការនៃសកលវិទ្យាល័យMcGill អះអាងថា "វិធីសាស្ត្ររបស់តុលាការបណ្ដោះអាសន្ន (Ad hoc) ត្រូវបានគេសន្មតថាលក្ខខណ្ឌតម្រូវនៃការអាចព្យាករណ៍បានជាមុន និងស្វែងរកបានត្រូវបានបំពេញ ប្រសិនបើអំពើដែលបានប្រព្រឹត្តនោះត្រូវផ្ដន្ទាទោសក្រោមច្បាប់អន្តរជាតិ"។ សារណារបស់សកលវិទ្យាល័យ McGill ចែងថា "វិធីសាស្ត្រនៅតុលាការបណ្ដោះអាសន្ន ត្រូវបានគេសន្មតថាលក្ខខណ្ឌតម្រូវទាំងពីរ (អាចព្យាករណ៍បានជាមុន និងស្វែងរកបាន) ត្រូវបានបំពេញ ប្រសិនបើអំពើដែលបានប្រព្រឹត្តត្រូវផ្ដន្ទាទោសក្រោមច្បាប់អន្តរជាតិ"[66]។ បើទោះជាមានការអះអាងថាវាជាវិធីសាស្ត្រទូទៅនៅតុលាការ ICTY ក៏ដោយ តែសារណានេះលើកមកសំអាងនូវប្រភពតែមួយប៉ុណ្ណោះ[67] ដែលមើលទៅមិនគាំទ្រដល់ការអះអាងនេះផង ។

៣៨. នៅក្នុងកថាខណ្ឌទី ៥១ កសព អះអាងថា វាមិនសមរម្យទេសម្រាប់ការសម្រេចថាតើ JCE មាននៅក្នុងច្បាប់កម្ពុជានៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ប៉ុន្តែ កសព មិនបានពន្យល់ពីមូលហេតុដែល

---

[66] ករណីកាំង ហ្គេកអ៊ាវ ហៅ "ឌុច", 001/18-07-2007-ECCC-OCIJ (PTC02), កថាខណ្ឌទី១៣សារណារបស់អ្នកមិនមែនជាភាគីតុលាការ ដាក់ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង Legal Pluralism, McGill University, ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៨, ឯកសារលេខ D99/3/25, ERN: 00234856-00234883 ("McGill Brief")។

[67] ប្រភពដែលលើកមកសំអាងនៅក្នុងសារណារបស់សកលវិទ្យាល័យ McGill គឺករណីរដ្ឋអាជ្ញា តទល់ជាមួយ *Martić*, IT-95-11-A, សាលដីកាលើបណ្ដឹងឧទ្ធរណ៍- សាលដីកាដាច់ដោយឡែករបស់ចៅក្រម Schomburg ស្ដីពីការទទួលខុសត្រូវជាមេបញ្ជាការរបស់ Milan Martić ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ។

00486673



ខ្លួនពិចារណាយ៉ាងដូច្នេះទេ។ កសព គ្រាន់តែសំអាងលើសារណារបស់សកលវិទ្យាល័យ McGill ដោយមិនបានផ្តល់ការពន្យល់ណាមួយ ទាក់ទងនឹងភាពពាក់ព័ន្ធជាមួយការអះអាងរបស់ខ្លួននោះទេ។ កថាខណ្ឌមួយនៅសារណារបស់សកលវិទ្យាល័យ McGill ដែលត្រូវបានសំអាង ធ្វើការអះអាងស្រដៀងគ្នានេះ តែមិនបានពន្យល់ ឬ ផ្តល់មូលដ្ឋានសំអាងផ្លូវច្បាប់ណាមួយនោះទេ[68]។ ទាក់ទងនឹងចំនុចនេះ កសព ខកខានមិនបានពិចារណាលើអំណះអំណាងដែលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទេ[69]។ បន្ទាប់មក កសព អះអាងថាក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ "ជាទូទៅគាំទ្រចំពោះគំនិតបង្កប់នៅក្នុង JCE"។ ឧទាហរណ៍ កសព បានប្រើពាក្យដូចជាៈ ការប្រព្រឹត្តរួមគ្នា, ការសមគំនិត និងការប្រព្រឹត្តដោយមានគូកនច្រើន។ ទម្រង់នៃការទទួលខុសត្រូវទាំងនេះ

---

[68] នៅក្នុងកថាខណ្ឌទី ១៣ នៃសារណារបស់ McGill គ្រាន់តែចែងថា "បញ្ហាទីពីរគឺពាក់ព័ន្ធជាមួយលក្ខខណ្ឌតម្រូវនៃភាពអាចដឹងជាមុន និងភាពអាចយល់បានរបស់គោលការណ៍គ្មានទោសបើគ្មានច្បាប់ចែង (*nullum crimen sine lege*) ។ ដូចបានបង្ហាញពីខាងលើ លក្ខខណ្ឌតម្រូវ "ភាពអាចដឹងជាមុន" នៃគោលការណ៍ *nullum crimen sine lege* នឹងត្រូវបំពេញ ប្រសិនបើមានការបង្ហាញឱ្យឃើញថា ជនល្មើសអាចដឹងជាមុននិងអាចយល់បានថាអំពើរបស់គាត់នឹងត្រូវផ្តន្ទាទោស នៅពេលប្រព្រឹត្តបទល្មើសនោះ។ វិធីសាស្ត្រ នៅតុលាការ Ad hoc ត្រូវបានសន្មតថាលក្ខខណ្ឌទាំងពីរនេះត្រូវបានបំពេញ ប្រសិនបើអំពើត្រូវផ្តន្ទាទោសក្រោមច្បាប់អន្តរជាតិ។ វាធ្វើដូច្នេះ នឹងដាក់កម្រិតយ៉ាងធ្ងន់ធ្ងរចំពោះការអនុវត្តទ្រឹស្តី *ignorantia juris non excusa* ។

[69] ឧទាហរណ៍ បណ្តឹងឧទ្ធរណ៍ពន្យល់ថា "កសចស មានកំហុសនៅពេលសម្រេចថា ការអនុវត្តនៃការទទួលខុសត្រូវ JCE នឹងមិនរំលោភបំពានលើគោលការណ៍នៃនីត្យានុកូលភាពទេ ពីព្រោះធាតុផ្សំការទទួលខុសត្រូវ JCE "អាចដឹងជាមុន និងអាចយល់បាន ក្រោមច្បាប់អន្តរជាតិនៅឆ្នាំ ១៩៧៥ នៅកម្ពុជា..."។ កសចស ប្រើការវាយតម្លៃមិនត្រឹមត្រូវនៅពេលធ្វើការសម្រេចនេះ ។ កសចស សន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពនឹងអាចបំពេញបាន ប្រសិនបើការទទួលខុសត្រូវ JCE កើតមាននៅក្នុងច្បាប់អន្តរជាតិ ដោយយោងទៅលើមាត្រា ៣៣ ថ្មីនៃច្បាប់បង្កើត អវតក ដែលចែងពីគោលការណ៍នីត្យានុកូលភាព តាមរយៈការយោងមាត្រា ១៥ នៃកតិកាសញ្ញាឆ្នាំ ១៩៥៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ប៉ុន្តែ អវតក គឺជាតុលាការជាតិនៃកម្ពុជា ហើយ "គេត្រូវតែញែកឱ្យ ដាច់ពីគ្នារវាងលក្ខខណ្ឌបុរេនៃគោលការណ៍នីត្យានុកូលភាព ដោយសារតែវាត្រូវបានកំណត់ក្នុងកម្រិតអន្តរជាតិ ហើយគោលការណ៍ នីត្យានុកូលភាពរបស់ដីកាសម្រេចរបស់តុលាការជាតិ....។ មានប្រព័ន្ធច្បាប់ជាតិជាច្រើន ជាអាទិ៍ ច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេសអាឡឺម៉ង់ (មាត្រា ១០៣(៣)- តម្រូវឱ្យមានការគោរពយ៉ាងតឹងរឹងចំពោះគោលការណ៍នីត្យានុកូលភាព។ ចំនុចនេះកើតចេញពីករណី *Aussaresses* ....។ ភាគីបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តីនោះអះអាងថា អត្ថិភាពនៃវិធានរបស់ច្បាប់អន្តរជាតិនៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្ត នឹងបំពេញបាននូវគោលការណ៍នីត្យានុកូលភាព។ ទឡ្ហីករណ៍នេះត្រូវបានច្រានចោល ។ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ចែងថា "ច្បាប់ព្រហ្មទណ្ឌគ្មានអនុភាពជាប្រតិសកម្មទេ ។ មិនអាចផ្តន្ទាទោសលើបទល្មើសដោយការអនុវត្តការផ្តន្ទាទោស ដែលមិនមានចែងដោយច្បាប់ នៅមុនពលដែលបទល្មើសនេះបានប្រព្រឹត្ត បានទេ។ ដូច្នេះ ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ តម្រូវឱ្យមានការគោរពយ៉ាងតឹងរឹងនូវគោលការណ៍នីត្យានុកូលភាព ។ ការទទួលខុសត្រូវ JCE ត្រូវតែបានបញ្ចូលទៅក្នុងច្បាប់កម្ពុជា នៅពេលវេលាពាក់ព័ន្ធ ។

00486674



អាចរកបាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ប៉ុន្តែពួកវាមានលក្ខណៈខុសគ្នាពី JCE ដូចដែលមេធាវីការពារក្តីបានបង្ហាញជាច្រើនដងរួចមកហើយនៅក្នុងសារណាលើកមុនរបស់ខ្លួន[70]។ ប្រសិនបើ កសព អះអាងថាទម្រង់នៃការទទួលខុសត្រូវទាំងនេះជាទូទៅគាំទ្រការទទួលខុសត្រូវ JCE នោះ កសព ត្រូវតែបានពន្យល់ហេតុអ្វីបានខ្លួនមិនអាចយល់ឃើញថាទម្រង់នៃការទទួលខុសត្រូវទាំងនេះមានលក្ខណៈគ្រប់គ្រាន់ដើម្បីប្រើនៅ អវតក និងថាហេតុអ្វីបានជា កសព បន្តទាមទារឲ្យ អវតក អនុវត្ត JCE ដែលជាទម្រង់នៃការទទួលខុសត្រូវមួយមានលក្ខណៈចម្លែកថ្មីចំពោះការអនុវត្តច្បាប់ និង យុត្តិសាស្ត្រកម្ពុជា។

៣៩. នៅក្នុងកថាខណ្ឌទី ៥២ កសព សន្និដ្ឋានថា ការទទួលខុសត្រូវ JCE ត្រូវបានគេអាចព្យាករណ៍បានជាមុន និងស្វែងរកបានគ្រប់គ្រាន់នៅពេលវេលាពាក់ព័ន្ធ ។ សម្រាប់មូលហេតុទាំងអស់ដែលលើកឡើងពីលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍[71] មេធាវីការពារក្តីច្រានចោលការសន្និដ្ឋានបែបនេះ ។

*JCE មិនបានដាក់បញ្ចូលនៅក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អវតក ទេ*

៤០. នៅក្នុងកថាខណ្ឌទី ៥៣ កសព ស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធចោលគោលជំហររបស់មេធាវីការពារក្តីដែលថា កសចស មានកំហុសក្នុងការយល់ឃើញថា JCE គឺជាទម្រង់នៃការប្រព្រឹត្ត ។ ទាក់ទងចំនុចនេះ មេធាវីការពារក្តីស្នើឲ្យអង្គបុរេជំនុំជម្រះទទួលយកអំណះអំណាងរបស់ខ្លួន ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍[72] ។ ដូចដែលបានបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ "ការប្រព្រឹត្ត" មានន័យខុសៗគ្នានៅក្នុងប្រព័ន្ធច្បាប់ផ្សេងៗ[73]។ នៅកម្ពុជា "ការប្រព្រឹត្ត" ត្រូវបាន

---

[70] ឧទាហរណ៍ សូមមើលបណ្តឹងឧទ្ធរណ៍ ឧបសម្ព័ន្ធ ក ផ្នែក II គ ។

[71] សូមមើលបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៧៤-៧៩ ។

[72] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៦៦-៧១ ។

[73] ទស្សនៈទានស្តីពីសហឧក្រិដ្ឋកម្មរួម មិនបានចែងយ៉ាងច្បាស់លាស់នៅក្នុងលក្ខន្តិកៈ ICTY ហើយមានលទ្ធផលតែមួយគត់ដើម្បីបកស្រាយ "ការប្រព្រឹត្តនេះ" ទាក់ទងនឹងបទឧក្រិដ្ឋនៅក្រោមលក្ខន្តិកៈ ICTR និង ICTY ។ ប៉ុន្តែ នៅក្នុងប្រព័ន្ធច្បាប់មួយចំនួនទៀត "ការប្រព្រឹត្ត" ត្រូវបានបកស្រាយខុសៗគ្នា ។ ចាប់តាំងសវនាការនៅ Nuremberg និង Tokyo ច្បាប់ជាតិព្រមទាំងច្បាប់អន្តរជាតិ ទទួលស្គាល់ថា ការប្រព្រឹត្តដោយមានតួកទ្រើននាក់ និងការប្រព្រឹត្តដោយប្រយោល (ការប្រព្រឹត្តដោយមធ្យោបាយ) ជាទម្រង់មួយនៃ "ការប្រព្រឹត្ត"។ *រឿងក្តីរដ្ឋអាជ្ញា តទល់ជាមួយ Gacumbitsi*, ICTR-2001-64-A, កថាខណ្ឌទី ១៦ សាលដីកាដាច់ដោយឡែករបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវរបស់ភាគីប្តឹងឧទ្ធរណ៍ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី ៧ ខែ កក្កដា ២០០៦ (បញ្ជាក់បន្ថែម) ។ ចំពោះការពន្យល់បន្ថែមថាហេតុអ្វីបានជា JCE

កំណត់ជា ការប្រព្រឹត្ត និងការរួមគ្នាប្រព្រឹត្ត[74]។ម្យ៉ាងវិញទៀត "ការយល់ឃើញ...ដែលថាសហឧក្រិដ្ឋកម្មរួម គឺដូចគ្នានឹង "ការប្រព្រឹត្ត" បទល្មើសដែរ ។ ... ការជំទាស់ជាមួយអត្ថន័យធម្មតា "ការប្រព្រឹត្ត" ថាជាការប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬ ការប្រព្រឹត្តអំពើអកម្មដែលត្រូវផ្តន្ទាបន្ទោស ផ្ទុយពីច្បាប់ព្រហ្មទណ្ឌ ហើយដូច្នេះ គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌត្រូវតែបកស្រាយយ៉ាងតឹងរ៉ឹងបំផុត"[75]។

៤១. នៅក្នុងកថាខណ្ឌទី ៥៤ កសព អះអាងដោយមិនត្រឹមត្រូវថា មាត្រា២៩ នៃច្បាប់បង្កើត អវតក ឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដច្បាប់លក្ខន្តិកៈរបស់តុលាការ ad hoc។ ពាក្យពេចន៍ខុសគ្នាយ៉ាងមានន័យខុសគ្នាយ៉ាងពិតប្រាកដ ។ មាត្រា ២៩ យោងទៅលើជនសង្ស័យណាដែលមាន "ផែនការញុះញង់, បញ្ជា, ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម" ខណៈមាត្រា ៧(១) នៃលក្ខន្តិកៈ ICTY ចែង "<u>ឬបើមិនដូច្នេះទេ បានជួយនិងជំរុញ</u>" ។ ភាពខុសគ្នានេះបង្ហាញឲ្យឃើញថា មាត្រា ២៩ មានបញ្ចីពេញលេញទម្រង់នៃការទទួលខុសត្រូវ ខណៈដែលលក្ខន្តិកៈនៃតុលាការ Ad hoc មិនមាននោះទេ ។ កសព ធ្វើការធៀបប្រដូចដោយមិនត្រឹមត្រូវរវាង អវតក ជាមួយតុលាការ Ad hoc ទាំងនេះ។ ដូចដែលមានពិភាក្សាយ៉ាងច្រើននៅក្នុងបណ្តឹងឧទ្ធរណ៍ អង្គជំនុំជម្រះវិសាមញ្ញ[76] គឺជាតុលាការជាតិរបស់កម្ពុជា។ អាស្រ័យហេតុនេះ តុលាការ Ad hoc "មិនមែនជាតុលាការដែលមានលក្ខណៈជាបងប្អូននោះទេ" ។ មិនដូចតុលាការ Ad hoc អង្គជំនុំជម្រះវិសាមញ្ញ គឺផ្អែកលើប្រព័ន្ធច្បាប់កម្ពុជាដែលនៅជាធរមាន ដែលចំលងចេញពីប្រព័ន្ធច្បាប់ស៊ីវិលរបស់ប្រទេសបារាំង ។ ហេតុដូច្នេះ តុលាការនេះមិនអាចនាំចូលច្បាប់ common law ឬ ប្រព័ន្ធច្បាប់ចំរុះបានទេ បើទោះជាជាតុលាការ Ad hoc ផ្សេងៗបានអនុវត្តរួចមកហើយក៏ដោយចុះ។ ជាចុងក្រោយ វាមិនត្រូវជាការព្រួយបារម្ភចំពោះចៅក្រមនៅ អវតក ដូចដែលបានលើកឡើងដោយ កសព ឡើយថា តើមានស្ថាប័នច្បាប់មនុស្សធម៌យ៉ាងរ៉ឹងមាំដែរឬយ៉ាងណា ។ ចៅក្រមនៅតុលាការ ICC ទទួលស្គាល់ចំនុចនេះនៅក្នុងការសេចក្តីសម្រេចរបស់ខ្លួន

---

មិនឋិតនៅក្រោមប្រភេទ "ការប្រព្រឹត្ត" ដែលមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អវតក ។ សូមមើលបណ្តឹងឧទ្ធរណ៍ ឧបសម្ព័ន្ធ ក ផ្នែក II ខ,២ ។

[74] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៦៣-៦៦ ។

[75] Shane Darcy "ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងគោលបំណងរបស់យុត្តិធម៌អន្តរជាតិ LEIDEN J. INT'L L. 377, 384 (2007)។

[76] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៧-២៤ ។

00486676



បដិសេធចោល JCE ដូចដែលបានបង្កើតឡើងក្នុងរឿង *Tadić* ។ អង្គជំនុំជម្រះវិសាមញ្ញត្រូវព្រួយបារម្ភចំពោះពីការអនុវត្តច្បាប់ឲ្យបានសមរម្យសម្រាប់តុលាការនេះ តែប៉ុណ្ណោះ។ ចំនុចនេះអាចខុសគ្នាពីច្បាប់ដែលត្រូវអនុវត្តនៅក្នុងប្រព័ន្ធ ដែលប្រកាន់តាមច្បាប់ common law ឬ ប្រព័ន្ធចំរុះ។

៤២. នៅក្នុងកថាខណ្ឌទី ៥៥ កសព អះអាងថាអ្នកពង្រាងច្បាប់បង្កើត អវតក បានដឹងពីសេចក្ដីសម្រេចរបស់ ICTY នៅក្នុងរឿងក្ដី *Tadić* និង បានដឹងយ៉ាងច្បាស់ថាការទទួលខុសត្រូវ JCE នឹងដកចេញពីច្បាប់នេះ ប្រសិនបើពួកគេមានបំណង ។ អំណះអំណាងនេះ គឺគ្រាន់តែជាការនិយាយស្មានៗដែលមិនសមហេតុផល។ វាជាការសមស្របក្នុងការពិចារណាថា ការខកខានមិនបានដាក់បញ្ចូលការទទួលខុសត្រូវ JCE នៅក្នុងច្បាប់បង្កើត អវតក អ្នកពង្រាងច្បាប់នេះមានបំណងមិនបញ្ចូលវាទៅក្នុងច្បាប់នោះ ។ អនុលោមប្រព័ន្ធច្បាប់ស៊ីវិល និងជាពិសេស ច្បាប់ដែលយកលំនាំតាមច្បាប់បារាំង ដែលប្រព័ន្ធច្បាប់ អវតក យកលំនាំតាមយ៉ាងខ្លាំង គឺថារាល់ទម្រង់ទាំងអស់នៃការទទួលខុសត្រូវ ត្រូវតែមានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិជាលាយលក្ខណ៍អក្សរ ប្រសិនបើមានបំណងអនុវត្តវា[77]។ ការមិនបញ្ចូល JCE នៅក្នុងច្បាប់បង្កើត អវតក ប្រាប់ជាសញ្ញាថា JCE មិនមែនជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបាននៅ អវតក នោះទេ ។ ម្យ៉ាងទៀតវាប្រាកដជាក់ណាស់ថាអ្នកពង្រាងច្បាប់ អវតក បានដឹងពីបង្កើតការទទួលខុសត្រូវ JCE ដោយសាលក្រមរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងក្ដី *Tadić* ដែលមិនមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ ICTY បានបង្កនូវវិវាទយ៉ាងខ្លាំង ហើយក៏មានភាពចម្រូងចម្រាស់ខ្លាំងណាស់ដែរ[78]។ ប្រសិនបើអ្នកពង្រាងច្បាប់បង្កើត អវតក មានបំណងដាក់បញ្ចូលការទទួលខុសត្រូវ JCE បើទោះបីជាបានដឹងពីប្រវត្តិនៃការវិវាទ និងភាពចម្រូងចម្រាស់បែបនេះ នោះពួកគេនឹងដាក់បញ្ចូលវាយ៉ាងច្បាស់ជាពុំខាន

[77] សូមមើលច្បាប់បារាំងទាក់ទងនឹងគោលការណ៍គ្មានទោស បើគ្មានច្បាប់ចែង *nullum crimen sine lege scripta*, Crim. 8 Sep. 1809, S 1809-11.1.107 ។ សូមមើលផងដែរ JOHN BELL ET AL., គោលការណ៍ច្បាប់បារាំង PRINCIPLES OF FRENCH LAW 204 (Oxford University Press 1998) ។ វិធីសាស្ត្រនេះក៏អនុវត្តនៅប្រទេសអាឡឺម៉ង់ ។ សូមមើល *Streletz, Kessler & Krenz* តទល់ជាមួយអាឡឺម៉ង់ (ករណីឆ្មាំព្រំដែនអាឡឺម៉ង់) ពាក្យសុំលេខ 34044/96, 35532/97 and 44801/98, កថាខណ្ឌទី ២២ ។ តាមពិត វិធីសាស្ត្រក៏បានអនុវត្តដោយអង្គបុរេជំនុំជម្រះនៅក្នុងការវាយតម្លៃវិសាលភាពនៃសិទ្ធិ ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ កសចស ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់ អវតក ។ សូមមើលករណី អៀង សារី 002/19-09-2007-ECCC/OCIJ(PTC08) សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងលិខិតទាក់ទងនឹងសំណើសុំព័ត៌មានទាក់ទង នឹងមន្ត្រីច្បាប់ David Boyle ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, កថាខណ្ឌទី ១៧។

[78] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៦ ។

00486677



ឡើយ។ តុលាការពិសេសសម្រាប់ប្រទេសលីបង់ ("STL") ជាប្រភេទតុលាការមួយផ្សេងទៀត ដែលឯកសារបង្កើតតុលាការនេះត្រូវបានពង្រាងឡើងបន្ទាប់ពីសាលដីកា *Tadić* បានចែងជាពិសេសសម្រាប់ការទទួលខុសត្រូវរួមគ្នា[79]។ វាមិនគួរឱ្យភ្ញាក់ផ្អើលទេ ពីព្រោះលោកចៅក្រម Cassese ដែលជាមេក្លោងក្នុងការបង្កើត JCE ជាប្រធានតុលាការនេះ ។

៤៣. នៅក្នុងកថាខណ្ឌទី ៥៦ កសព ផ្តល់ឧទាហរណ៍ពីលក្ខន្តិកៈរបស់ក្រុមប្រឹក្សាវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត ដែលត្រូវបានអនុម័តនៅឆ្នាំ ២០០០ គឺរយៈពេលមួយឆ្នាំមុនការអនុម័តច្បាប់បង្កើត អវតក។ លក្ខន្តិកៈនេះប្រើប្រាស់ពាក្យពេចន៍មាត្រា ២៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម ICC ។ វាជាការពិតដែលថាក្រុមប្រឹក្សាវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត បានប្រើវិធីសាស្ត្រផ្សេងចំពោះលក្ខន្តិកៈរបស់ខ្លួន ខុសពីអ្នកពង្រាងច្បាប់បង្កើត អវតក ។ លក្ខន្តិកៈទាំងពីនេះត្រូវ បានអនុម័តនៅពេលវេលាប្រកិតៗគ្នា ប៉ុន្តែ វានៅស្រពិចស្រពិលថាតើ អ្នកពង្រាងច្បាប់បង្កើត អវតក បានពិចារណាលើក្ខន្តិកៈរបស់ក្រុមប្រឹក្សាវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើតដែរឬយ៉ាងណានោះ។ម្យ៉ាងវិញទៀត ករណីដែលក្រុមប្រឹក្សាវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត ប្រកាន់យកវិធីសាស្ត្ររបស់ ICC ជាជាងវិធីសាស្ត្ររបស់ដែលប្រើប្រាស់ដោយតុលាការ *Ad hoc* ដទៃទៀត នោះវាបង្ហាញឱ្យឃើញថា JCE មិនមែនជាគោលការណ៍ល្អនោះទេ ។ ដូចដែលបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍[80] ទាក់ទងនឹងការទទួលខុសត្រូវ JCE លក្ខន្តិកៈរបស់ ICC មិនបានប្រកាន់យកយុត្តិសាស្ត្ររបស់តុលាការ *Ad hoc* ដទៃទៀតឡើយ ។

៤៤. នៅក្នុងកថាខណ្ឌទី ៥៧ កសព អះអាងថាការអនុវត្តនូវការទទួលខុសត្រូវ JCE ត្រូវបានគាំទ្រដោយគោលដៅ និងគោលបំណងនៃច្បាប់បង្កើត អវតក ។ ប៉ុន្តែ ទម្រង់នៃការទទួលខុសត្រូវទាំងនេះចែងយ៉ាងច្បាស់នៅក្នុងមាត្រា ២៩ ដែលអាចគាំទ្រគ្រប់គ្រាន់ទៅលើគោលដៅ និង គោលបំណងដោយមិនចាំបាច់ដាក់បញ្ចូលទស្សនទានផ្នែកច្បាប់របស់បរទេសទៅក្នុងច្បាប់បង្កើត អវតក ឡើយ។ ប្រសិនបើអ្នកពង្រាងច្បាប់បង្កើត អវតក ជឿជាក់លើការទទួលខុសត្រូវ JCE នោះពួកគេត្រូវតែបានបញ្ចូលវាយ៉ាងច្បាស់ទៅក្នុងច្បាប់នេះហើយ ។

---

[79] មាត្រា ៣(១)(ខ) ច្បាប់លក្ខន្តិកៈតុលាការពិសេសលីបង់ ។

[80] សូមមើលបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៤៩-៥៨ ។

00486678



៤៥. នៅក្នុងកថាខណ្ឌទី ៥៨ និង ៥៩ កសព ផ្តល់សម្រង់មួយចំនួនដែលបង្ហាញថា លក្ខណៈតែមួយនៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំ ផ្តល់ហេតុផលដល់ការអនុវត្តការទទួលខុសត្រូវ JCE ។ សម្រង់ទាំងនេះមិនបានបង្ហាញថា ទម្រង់នៃការទទួលខុសត្រូវមួយដែលមិនបានទទួលស្គាល់ដោយច្បាប់កម្ពុជា ឬ ច្បាប់ទម្លាប់អន្តរជាតិ ត្រូវតែអនុវត្តនោះទេ ។ ការរួមគ្នាប្រព្រឹត្ត ដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជា គឺវាសក្តិសមមែនទែនទៅនឹងលក្ខណៈគ្មានពីរនៃបទល្មើសដែលមានទំហំធំធេងបែបនេះ។ ដូចដែលចៅក្រម Schomburg បានកត់សម្គាល់ថា "ការចូលរួមប្រព្រឹត្តរួមគ្នាឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ ការកត់សម្គាល់នេះត្រូវបានទទួលស្គាល់ដោយមាត្រា ២៥(៣)(ក) នៃលក្ខន្តិកៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ICC ដែលរួមបញ្ចូលនូវសញ្ញាណនៃការចូលរួមប្រព្រឹត្តរួមគ្នាផងដែរ" ។ ICC ដែលបង្កើតឡើងដោយសន្ធិសញ្ញា គឺជា "តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ដំបូងគេបង្អស់ ដើម្បីបញ្ឈប់និទណ្ឌភាពចំពោះជនដែលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលជាការព្រួយបារម្ភដល់សហគមន៍អន្តរជាតិ"[81]។ ដូចដែលបានបង្ហាញពីខាងលើរួចមកហើយ ការដែល ICC បានបដិសេធមិនប្រើការទទួលខុសត្រូវ JCE[82] ហើយបានជ្រើសយក "ការរួមគ្នាប្រព្រឹត្ត" នោះបង្ហាញឱ្យឃើញថា ការទទួលខុសត្រូវ JCE មិនមែនជាឧបករណ៍ចាំបាច់ដើម្បីដោះស្រាយ លើលក្ខណៈតែមួយនៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំនោះទេ ។ ម្យ៉ាងទៀត សាស្ត្រាចារ្យ Professor Weigend ពន្យល់ថា "ពិតណាស់ បញ្ហាថាតើ គោលបំណង (ដែលអាចយល់បាន) ដើម្បីនាំ "ជនដៃដល់" ទាំងអស់មកទទួលការជំនុំជម្រះក្តី គឺជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចថា តើនរណាជា "ជនដៃដល់" នោះ ។ ក្នុងន័យផ្សេងទៀត JCE តាមរយៈការពង្រាយសំណាញ់ធំពេកអាចជួបការលំបាកក្នុងការពន្យល់ថា ហេតុអ្វីបានជាគ្រប់គ្រីដែលបានចាប់សមនឹងដាក់ទណ្ឌកម្មលើការប្រព្រឹត្តខុសឆ្គងជាអន្តរជាតិ[83]។

៤៦. នៅក្នុងកថាខណ្ឌទី ៦០ កសព អះអាងថា "ចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិយ៉ាងច្រើនលើសលប់ដែលបានពិនិត្យបញ្ហានេះ បានអនុវត្តការទទួលខុសត្រូវ JCE" ។ កសព មិនបានបង្ហាញមូលដ្ឋានសំអាងផ្លូវច្បាប់សម្រាប់ការថ្លែងនេះទេ ។ តាមពិត ចៅក្រមភាគច្រើននៃតុលាការ *Ad*

---

[81] គេហទំព័ររបស់ ICC អំពីតុលាការ, អាចរកបាននៅ http://www.icc-cpi.int/Menus/ICC/About+the+Court/ ។

[82] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី ៤៩-៥៨ ។

[83] Thomas Weigend, ចេតនា, កំហុស និង ការរួមគ្នាប្រព្រឹត្ត នៅក្នុងសាលក្រមក្នុងក្តី Lubanga លើការបញ្ជាក់ពីបទចោទប្រកាន់ (*Intent, Mistake of Law and Co-perpetration)* 6 J. INT'L CRIM. JUST. 471, 477 (2008) ។

*hoc* មិនបានពិចារណាថាតើ ត្រូវអនុវត្ត JCE ដែរឬយ៉ាងណានោះទេ ។ ពួកគេគ្រាន់តែធ្វើយ៉ាងដូច្នេះ ដោយសារតែចៅក្រមមុនៗបានធ្វើរួចមកហើយ ។ ដូចបង្ហាញនៅក្នុងបណ្ដឹងឧទ្ធរណ៍:

> ការសម្រេចដោយភាន់ច្រឡំនេះ ត្រូវបានទទួលយកដោយ ICTY និង ICTR (ដែលចែករំលែកអង្គជំនុំជម្រះតុលាការកំពូលជាមួយគ្នា) ដោយពុំមានការវិភាគបន្ថែម បើទោះជាមានរិះគន់ខ្លាំងៗក៏ដោយ និង បើទោះជាអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចលើបញ្ហានៃឋានៈជាច្បាប់ទម្លាប់អន្តរជាតិរបស់ការទទួលខុសត្រូវ JCE ដោយពុំមានអំណះអំណាងជាលាយលក្ខណ៍អក្សរពីរដ្ឋអាជ្ញា និងមេធាវីការពារក្ដី ហើយមេធាវីការពារ *Tadić* មិនបានជំទាស់ទៅនឹងការអនុវត្តការទទួលខុសត្រូវ JCE ទេ[84] ។

មតិរបស់ចៅក្រមទាំងនេះមិនអាចចងកាតព្វកិច្ច អវតក បានទេ ដោយសារតុលាការនេះ មិនមែនជាតុលាការអន្តរជាតិដែរ ហើយតុលាការនេះអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល មិនដូចតុលាការ *Ad hoc* ដទៃទៀតទេ ។ ដោយពុំបានបង្ហាញនូវមូលដ្ឋានសំអាងច្បាប់ កសព ក៏បានអះអាងថា "មតិអ្នកស្រាវជ្រាវបានគាំទ្រយ៉ាងទូលំទូលាយដល់ការទទួលខុសត្រូវ JCE នេះ" ។ ដូចមេធាវីការពារក្ដីបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ -<u>ព្រមជាមួយការផ្ដល់មូលដ្ឋានសំអាងច្បាប់</u>- មានមតិអ្នកស្រាវជ្រាវបានតិះតៀនយ៉ាងទូលំទំលាយទៅលើទ្រឹស្ដីនេះ ។ មានឧទាហរណ៍ពីរផ្ដល់ជូនគឺ លោកសាស្ត្រាចារ្យ Professor Schabas បានថ្លែងថា "បច្ចេកទេសទាំងពីរនេះ [JCE និងការទទួលខុសត្រូវរបស់ថ្នាក់លើ] សម្របសម្រួលដល់ការវិនិច្ឆ័យទោសបុគ្គលដែលបានចូលរួមនៅក្នុងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែ បច្ចេកទេសទាំងពីរនេះ បានបញ្ចុះតម្លៃការវិនិច្ឆ័យទោស ដែលនាំទៅដល់ការបន្ធូរបន្ថយជៀសមិនផុតនូវសារៈសំខាន់នៃសាលក្រមតុលាការ ហើយនឹងបង្កអន្តរាយដល់មរតកជាប្រវត្តិសាស្ត្ររបស់តុលាការទៀតផង[85]។ Ciara Damgaard បានថ្លែងថា "ទ្រឹស្ដីនេះកើតចេញពីការព្រួយបារម្ភយ៉ាងធ្ងរធ្ងរ" ។ ក្នុងចំនោមបញ្ហាដទៃទៀត ការព្រួយបារម្ភនេះ គឺជាការព្រួយបារម្ភមិនច្បាស់លាស់ ដែលអាចបន្ធូរបន្ថយបទដ្ឋាននៃភស្តុតាង និងអន្តរាយដល់គោលការណ៍នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គល ដែលអំណោយផលដល់ការទទួលខុសត្រូវជាសមូហភាព និងរំលោភបំពានដល់គោលការណ៍គ្មានទោសបើគ្មានច្បាប់ចែង (nullum crimen

---

[84] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌទី ៣៧ (លុបសំអាងផ្ទៃក្នុង) ។

[85] William A. Schabas, ធាតុផ្សំចេតនា និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី *Mens Rea and the International Criminal Tribunal for the Former Yugoslavia*, 37 NEW ENGLAND L. REV. 1015, 1033-34 (2002-03) ។

sine lege) និងរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជម្រះក្តីដោយយុត្តិធម៌[86]។ សាស្ត្រាចារ្យ Ambos បានតិតៀនខ្លាំងៗចំពោះការអនុវត្ត JCE[87] មេធាវីការពារក្តីកត់សម្គាល់ថា កសព ខកខានមិនបានដោះស្រាយ និងជំទាស់ទៅលើអំណះអំណាង សមហេតុផលដែលសាស្ត្រាចារ្យ Ambos បានលើកឡើងប្រឆាំងនឹងឋានៈរបស់ JCE ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ បើទោះបីជាអំណះអំណាងទាំងនេះមានចែងលំអិតនៅបណ្តឹងឧទ្ធរណ៍ក៏ដោយ[88]។ ការពឹងផ្អែកជ្រុលពេករបស់ កសព លើចៅក្រម Cassese ដោយគិតថាគាត់ជាមនុស្សដំបូងគេក្នុងការបង្កើតទ្រឹស្តីនៃការទទួលខុសត្រូវ JCE នោះមិនបានគាំទ្រដល់ការអះអាងរបស់ កសព ដែលថាការទទួលខុសត្រូវ JCE ត្រូវបានគាំទ្រយ៉ាងទូលំទូលាយនោះទេ ។

៤៧. នៅក្នុងកថាខណ្ឌទី ៦១ កសព បានស្រង់សំដីរបស់ Professor Osiel ដែលពន្យល់ថា "ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម... គឺសមស្រប [ជាងការទទួលខុសត្រូវរបស់ថ្នាក់លើ] ខុសគ្នាពីអំពើព្រៃផ្សៃជាទ្រង់ទ្រាយធំ ដែលឥទ្ធិពលនៃគំនិតព្យាបាទនៃការចូលរួមនេះ ធ្វើឡើងតាមរយៈបណ្តាញរាយប៉ាយយ៉ាងទូលំទូលាយ និងក្រៅផ្លូវការ"។ ការថ្លែងនេះមិនបានបង្ហាញពីការគាំទ្ររបស់លោក Osiel ដល់ការទទួលខុសត្រូវ JCE នោះឡើយ ។ ដូចដែល កសព សារភាព សាស្ត្រាចារ្យ Osiel តិតៀនខ្លាំងៗដល់ការទទួលខុសត្រូវ JCE ។

៤៨. នៅក្នុងកថាខណ្ឌទី ៦២ កសព ស្នើសុំអង្គបុរេជំនុំជម្រះឱ្យយល់ឃើញថា អ្នកពង្រាងច្បាប់បង្កើត អវតក មានបំណងចង់ឱ្យមាត្រា ២៩ ដាក់បញ្ចូលទម្រង់នៃការទទួលខុសត្រូវទាំងបី ។ សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីច្រានចោលការស្នើសុំបែបនេះ[89]។ ការទទួលខុសត្រូវ JCE មិនមាននៅក្នុងមាត្រា ២៩ ទេ ។ អ្នកពង្រាងច្បាប់បង្កើត អវតក មិនជាពិបាកក្នុងការចង់បញ្ចូល JCE នៅក្នុងបទញ្ញត្តិទេ បើសិនជាពួកគេមានបំណងនោះ ។ ប៉ុន្តែ ពួកគេមិនបានធ្វើទេ ។

---

[86] Ciara Damgaard, នៅទំព័រ ១២៩ ។

[87] សូមមើលករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" 001/18-07-2007-ECCC-OCIJ (PTC02), សារណារបស់អ្នកដែលមិនមែនជាភាគី តុលាការ ទាក់ទងនឹងសំណុំរឿង 001/18-07-2007-ECCC-OCIJ (PTC02) ថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៨ D99/3/27, ERN: 00234912-00234942 ។

[88] សូមមើលបណ្តឹងឧទ្ធរណ៍ ។

[89] ដូចខាងលើ កថាខណ្ឌ ៦៦-៧១ ។

00486681



*ច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចអនុវត្តបានទៅនៅ អវតក*

៤៩. នៅក្នុងកថាខណ្ឌទី ៦៣ កសព អះអាងថា "កាលណាគេបកស្រាយថា សហឧក្រិដ្ឋកម្មរួមមាន ចែងនៅក្នុងលក្ខន្តិក: អវតក ពេលនោះវាមិនសំខាន់ទេ ថាតើមាន ឬអត់នៅក្រោមច្បាប់កម្ពុជា" ។ ការស្នើបែបនេះមិនអើពើចំពោះអំណះអំណាងផ្ទុយយ៉ាងទូលំទូលាយនៅក្នុងបណ្តឹងឧទ្ធរណ៍[90] ។ បើទោះបី ការទទួលខុសត្រូវ JCE ត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់បង្កើត អវតក ក៏ដោយ ក៏ច្បាប់បង្កើត អវតកនេះមិនអាចបង្កើតច្បាប់ថ្មី ដែលត្រូវតែអនុវត្តជាប្រតិសកម្មដែរ ។ បើធ្វើដូច្នេះមែន វានឹងរំលោភលើគោលការណ៍នីត្យានុកូលភាព ដែលតម្រូវថាអំពើដែលត្រូវដាក់ទណ្ឌកម្មនៅក្រោមច្បាប់កម្ពុជានៅពេលវេលាពាក់ព័ន្ធ[91]។ ជាបន្ទាប់ កសព អះអាងថា "ជាតុលាការពិសេសដែលត្រូវគេធ្វើឱ្យមានលក្ខណៈអន្តរជាតិ ដែលមានកាតព្វកិច្ចចងភ្ជាប់ដោយទម្លាប់អន្តរជាតិ និងច្បាប់អន្តរជាតិ ទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់ក្នុងស្រុក មិនគួរយកមកអនុវត្តទាក់ទងនឹងសេចក្តីសម្រេចលើឧក្រិដ្ឋកម្មអន្តរជាតិ នៅចំពោះមុខតុលាការនេះទេ ។ ចំពោះការអះអាងនេះ កសព សំអាងលើសាលដីការបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងដីតចិត្តចៅក្រម ន័យ ថុល។ សេចក្តីសម្រេចនេះ មិនគាំទ្រដល់ការអះអាងនេះឡើយ។ អង្គបុរេជំនុំជម្រះពិភាក្សាពីលទ្ធភាពនៃឋានៈរបស់តុលាការនេះ "ដែលមានលក្ខណៈជាអន្តរជាតិពិសេស" ប៉ុន្តែការពិត មិនបានយល់ឃើញថា វាមិនអាចអនុវត្តទម្រង់ថ្នាក់ជាតិនៃការទទួលខុសត្រូវឡើយ ។ កសព ប៉ុនប៉ងញែក អវតក ឱ្យដាច់ចេញពីតុលាការដទៃទៀតរបស់កម្ពុជា ។ វាជាការត្រឹមត្រូវការដែលអង្គបុរេជំនុំជម្រះនៅក្នុងករណី ០០១ គូសបញ្ជាក់ថា អវតក "មានលក្ខណៈជាអន្តរជាតិ" ប៉ុន្តែ វាមិនមានន័យថាតុលាការនេះមិនមែនជាតុលាការកម្ពុជា ដែលត្រូវចងភ្ជាប់កាតព្វកិច្ចដោយកម្ពុជានោះទេ ។ មេធាវីការពារក្តីបង្ហាញនៅក្នុងបណ្តឹងឧទ្ធរណ៍ពីឋានៈរបស់ អវតក ថាជាតុលាការកម្ពុជា[92]។ បណ្តឹងឧទ្ធរណ៍បានពន្យល់ថា ប្រវត្តិនៃការបង្កើត អវតក បង្ហាញឱ្យឃើញថា តុលាការនេះត្រូវបានបង្កើតឡើងជាតុលាការជាតិ ។ កសព កត់សម្គាល់ថាច្បាប់បង្កើត អវតក ចែងថាតុលាការនេះអាចអនុវត្តនីតិវិធីដែលបង្កើតឡើងនៅកម្រិតអន្តរជាតិ ។ ការអះអាងនេះអាចជាត្រឹមត្រូវ ប៉ុន្តែវាមិនដូច្នេះទេ ដោយសារតែ អវតក មិនមានឋានៈអន្តរជាតិពិសេស ។ ច្បាប់បង្កើត អវតក

---

[90] ដូចខាងលើ កថាខណ្ឌ ២៥-២៩, ៧២-៧៣ ។

[91] ដូចខាងលើ កថាខណ្ឌ ៧២-៧៣ ។

[92] ដូចខាងលើ កថាខណ្ឌ ៧-២៤ ។

ចែងពីចំនុចនេះ ដោយសាររដ្ឋធម្មនុញ្ញតម្រូវថាតុលាការកម្ពុជាទាំងអស់ "ត្រូវទទួលស្គាល់ និង គោរពសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និង អនុសញ្ញានានាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និង សិទ្ធិកុមារ[93] ។

៥០. នៅក្នុងកថាខណ្ឌទី ៦៤ កសព អះអាងថា ICCPR ផ្ទុះបញ្ហាំងគោលការណ៍សំខាន់ៗថា សូម្បីតែតុលាការក្នុងស្រុកអាចជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិ ដោយប្រើទម្រង់នៃការទទួលខុសត្រូវដែលត្រូវទទួលស្គាល់ជាអន្តរជាតិ ថាតើឧក្រិដ្ឋកម្មនោះ ឬទម្រង់នៃការទទួលខុសត្រូវនោះ ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ជាតិ នៅខណៈពេលនៃការប្រព្រឹត្តនោះឬអត់។ វាមិនមែនជាគោលការណ៍សំខាន់នោះទេ ហើយម្យ៉ាងវិញទៀត ICCPR មិនបានផ្តល់អំណាចដល់តុលាការក្នុងស្រុកឲ្យធ្វើដូច្នេះដែរ។ វាគ្រាន់តែមិនបានហាមឃាត់មិនឲ្យធ្វើយ៉ាងដូច្នេះទេ ។ ប្រព័ន្ធទ្វីកនិយមរបស់កម្ពុជា មិនអនុញ្ញាតឲ្យតុលាការរបស់ខ្លួន អនុវត្តដោយផ្ទាល់នូវច្បាប់ទម្លាប់អន្តរជាតិ ដោយពុំបានឆ្លងកាត់ការអនុម័តពីរដ្ឋសភា នោះទេ[94]។

**គ. ការទទួលខុសត្រូវ JCE មានទំនោរអោយមានការពិរុទ្ធភាពរួមគ្នា**

៥១. នៅក្នុងកថាខណ្ឌទី ៦៥ កសព គូសបញ្ជាក់ថាមេធាវីការពារក្តី អះអាងថា ការទទួលខុសត្រូវ JCE ណែនាំនូវទម្រង់ពិរុទ្ធភាពរួមគ្នា ។ មេធាវីការពារក្តីមិនប្រៀបប្រដូចការទទួលខុសត្រូវ JCE ជាមួយពិរុទ្ធភាពរួមគ្នាទេ ប៉ុន្តែ បានបង្ហាញថាមានទំនោរឲ្យមានពិរុទ្ធភាពរួមគ្នា។ ឧទាហរណ៍ មេធាវីការពារក្តី ធ្លាប់បានស្រង់សំដីចៅក្រម Schomburg ដែលបានពន្យល់ថា "យុត្តិកម្មរឹងមាំរបស់អង្គជំនុំជម្រះតុលាការកំពូលដែលត្រូវបានហ៊ុំព័ទ្ធដោយសញ្ញាណរបស់ JCE បង្កើតឲ្យមានក្តីបារម្ភធ្ងន់ធ្ងរ ទាក់ទងនឹងគោលការណ៍គ្មានច្បាប់គ្មានបទល្មើស *nullum crimen sine lege.* ...។

---

[93] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ដែលបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩៩៩ ។

[94] សូមមើល*ករណី អៀង សារី* 002/19-09-2007-ECCC/OCIJ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនៅអវត នូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩, D240, ERN: 00401925-00401940, paras. 17-20, 25-30

<u>ការកែប្រែនិយមន័យបច្ចុប្បន្នរបស់ JCE ប្រភេទទី៣ បានបណ្តាលឲ្យប្រព័ន្ធមួយដែលនឹងដាក់ពិរុទ្ធភាពរួមគ្នា[95]</u>។

៥២. នៅក្នុងកថាខណ្ឌទី ៦៦ កសព ញែកការទទួលខុសត្រូវ JCE ឲ្យដាច់ចេញពីឧក្រិដ្ឋកម្មសមាជិកភាពនៅក្នុងអង្គការឧក្រិដ្ឋកម្ម នៅសវនាការ Nuremberg ។ មេធាវីការពារក្តីមិនជំទាស់ទៅនឹងភាពខុសគ្នានេះទេ ។ ប៉ុន្តែ ភាពខុសគ្នានៅពេលនោះប្រហែលជាមិនអាចយល់បានទេ ។ ជាមួយនឹងការទទួលខុសត្រូវ JCE III "ជាពិសេស ឧទាហរណ៍ ជនជាប់ចោទម្នាក់អាចត្រូវសម្រេចថាមានពិរុទ្ធភាពពីបទមនុស្សឃាតឬពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បើទោះបីជាគាត់មិនដែលមានបំណងប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះក៏ដោយ និងបើទោះបីជាឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានគេប្រព្រឹត្តនៅក្រៅ JCE ដោយមនុស្សដែលមិនស្ថិតនៅក្រោមការត្រួតត្រារបស់គាត់ ។ <u>ពិរុទ្ធភាពរបស់គាត់ផ្អែកលើគោលការណ៍ទទួលខុសត្រូវជាសមូហភាព</u>។ <u>គាត់ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលគាត់មិនបានប្រព្រឹត្តដោយផ្ទាល់ ហើយគាត់ក៏មិនដែលមានចេតនាប្រព្រឹត្តដែរ ។ គាត់ត្រូវបានផ្តន្ទាទោសដោយសារតែការសេពគប់របស់គាត់ជាមួយក្រុមជនល្មើស ។ នេះគឺជាវិវឌ្ឍន៍របស់ច្បាប់ដែលគួរឲ្យបារម្ភ"[96]</u> ។

៥៣. ក្នុងកថាខណ្ឌ៦៧ ក.ស.ព លើកឡើងថា សហឧក្រិដ្ឋកម្មរួម មាននៅក្នុងការពិចារណាអំពីគោលនយោបាយសាធារណៈ។ ក.ស.ព ខកខានមិនបានផ្តល់នូវហេតុផលថាតើហេតុអ្វីបានជាទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាស់ស្តីពីការបង្កើត អ.វ.ត.ក និងច្បាប់កម្ពុជាដទៃទៀតមិនអាចឆ្លើយតបដោយស្មើគ្នាទៅនឹងការពិចារណាគោលនយោបាយសារធារណៈ។ កាលពីមុន ក.ស.ព បានលើកឡើងថា ខ្លួនយល់ឃើញថា ទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់កម្ពុជាមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ទទួលខុសត្រូវJCE[97] ប៉ុន្តែ ក.ស.ព មិនអាចផ្តល់នូវការពន្យល់ថាតើហេតុអ្វីបានជាខ្លួនចាត់ទុកទម្រង់ទាំងនោះថា មានលក្ខណៈមិនគ្រប់គ្រាន់នោះទេ។ ក.ស.ព ខកខានមិនបាន បង្ហាញថាតើហេតុអ្វីបានជាគោលនយបាយសាធារណៈ

---

[95] *រឿងក្តីរដ្ឋអាជ្ញា តទល់ជាមួយ* *Martić*, IT-95-11-A សាលក្រម, មតិដាច់ដោយឡែករបស់ចៅក្រម Schomburg ទាក់ទងនឹងការទទួលខុសត្រូវផ្ទៃព្រហ្មទណ្ឌជាបុគ្គលរបស់ Milan Martić, ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨, កថាខណ្ឌទី ៧ (បញ្ជាក់បន្ថែម) ។

[96] Damgaard, ទំព័រ ២៣៨ (បញ្ជាក់បន្ថែម)។

[97] សូមមើលចម្លើយតប,កថាខណ្ឌ៥

ប្រហែលជាត្រូវការទម្រង់នៃការទទួលខុសត្រូវJCE ជាងទម្រង់ទទួលខុសត្រូវដទៃទៀតឡើយ។ ចារី ដែលដែលបានពន្យល់ខាងលើ គឺត្រូវទៅនឹងប្រភេទតែមួយគត់នៃឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំ ហើយនឹងបម្រើដល់ទិសដៅគោលនយោបាយសាធារណៈដូចគ្នាដែលការអះអាងរបស់ ក.ស.ព បានធ្វើយុត្តិកម្មទៅលើJCE។ លើសពីនេះទៀតអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្តី Bradanin បានពន្យល់ថា "អង្គជំនុំជម្រះ បានច្រានចោលនូវការអះអាងតាមបែបទូរបាតុភូតសាស្ត្រ teleological របស់មេធាវីដាក់បន្ទុក ដែលថាតុលាកការគួរតែអនុម័តនូវទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ព្រោះវានឹងអនុញ្ញាតឱ្យតុលាការនេះ កាត់ទោស និងដាក់ទណ្ឌកម្មអ្នកដែលបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងឋានៈជាមេដឹកនាំមិនត្រឹមតែអ្នកដែលនៅក្រោមបង្គាប់របស់ពួកគេប៉ុណ្ណោះទេ។ ការពិចារណាពីគោលនយោបាយសាធារណៈបែបនេះគឺមិនមានលក្ខណៈសមស្របជាមូលដ្ឋានសម្រាប់ទ្រឹស្តីនៃការទទួលខុសត្រូវបែបព្រហ្មទណ្ឌ របស់បុគ្គលឡើយ[98]"។

៥៤. ក្នុងកថាខណ្ឌ៦៨ ក.ស.ព បានលើកឡើងថា ការទទួលខុសត្រូវJCE " គឺអាស្រ័យទៅលើ និងមានជាធម្មតាចំពោះគម្រោងផែនការឧក្រិដ្ឋកម្មរួម។ "ឧក្រិដ្ឋបន្ទាប់បន្សំ"កើតចេញពីការកាត់សេចក្តីដោយ និងសំអាងទៅលើការកើតឡើងគម្រោងផែនការរួមជាមុនដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មរួមគ្នា ឬឧក្រិដ្ឋកម្មចម្បងនៃសហឧក្រិដ្ឋកម្មរួម"។ ការថ្លែងនេះហាក់បីដូចជាផ្ទុយទៅនឹងយុត្តិសាស្ត្រ របស់តុលាការកំពូលនៃប្រទេសសេរ៉ាឡេអូន ("តុលាការ SCSL")។ សាលដីការបស់AFRC លើកឡើងថា "[ទោះ]បីជាគោលបំណងនៃការទទួល និងការអនុវត្តអំណាចនយោបាយ និងការគ្រប់គ្រងដែនដីនៃប្រទេសសេរ៉ាឡេអូន អាចមិនមែនជាឧក្រិដ្ឋកម្មនៅក្រោមលក្ខន្តិកៈ នេះក៏ដោយ សកម្មភាពដែលបានប្រព្រឹត្តធ្វើជាមធ្យោបាយដើម្បីសម្រេចនូវគោលបំណងនោះ គឺត្រូវបានគេចាត់ទុកជាឧក្រិដ្ឋកម្មនៅក្នុងលក្ខន្តិកៈនេះហើយ"[99]។ អ្នកធ្វើអត្ថាធិប្បាយ បានកត់សម្គាល់ថា៖

> អង្គជំនុំជម្រះតុលាការកំពូល... មិនបានបញ្ជាក់ឱ្យបានច្បាស់ថាតើហេតុអ្វីបានជាខ្លួនទទួលយកនូវភាសាថ្មី ហើយថាតើខ្លួនបកស្រាយពាក្យថា "ប្រព្រឹត្ត" ក្នុងបរិបទនេះតាមវិធីណា...ខណៈពេលដែលតុលាការរឿងក្តី *Tadić* បានបញ្ជាក់យ៉ាងច្បាស់ថាផែនការរួម

---

[98] សូមមើលរឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Brđanin* IT-99-36-A, សាលដីកា, ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧, កថាខណ្ឌ ៤២១ (គូសបញ្ជាក់បន្ថែម)

[99] សូមមើលរឿងក្តីអាជ្ញា តទល់នឹង *Brima et al.*, SCSL-04-16-A សាលដីកា, ថ្ងៃទី២២ កុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌ ៨៥។

ត្រូវតែដាក់បញ្ចូល (ឬធ្វើឱ្យក្លាយជា) ឧក្រិដ្ឋកម្មនៅក្នុងលក្ខន្តិកៈរបស់តុលាការICTYនោះ សាលដីការបស់តុលាការ AFRC បានលើកឡើងថា ផែនការរួមត្រូវគិតពិចារណាអំពីតែផែនការឧក្រិដ្ឋដើម្បីសម្រេចគោលបំណងរបស់ខ្លួនតែប៉ុណ្ណោះ។ ដូច្នេះសាលដីកានេះ បានបើកផ្លូវឱ្យមានផែនការរួម ដែលតាមពិតមិនមានការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងលក្ខន្តិកៈនេះទេ ទោះបីជាការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះ ត្រូវបានគេចាត់ទុកថាជាលទ្ធភាពមួយក៏ដោយ[100]។

វាហាក់បីដូចជាថា ក.ស.ព ច្រានចោលនូវការបកស្រាយដោយអង្គជំនុំជម្រះតុលាការកំពូល SCSL ។ ក្រុមមេធាវីការពារក្តីយល់ស្របថា ដំណោះស្រាយរបស់តុលាការ SCSL មិនគួរយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក ទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តី បានកត់សម្គាល់ឃើញថា បញ្ហានេះបានបង្ហាញថែមទៀតនូវការខ្វះរូបរាងច្បាស់លាស់នៃការទទួលខុសត្រូវ JCE និងការលំបាកក្នុងការដាក់ឱ្យអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវដែលមិនច្បាស់លាស់នេះ។ កសព ថ្លែងបន្ថែមទៀតថា "ថ្វីបើ ជនល្មើសបន្ទាប់បន្សំ (secondary offender) មិនមានចេតនារួមគ្នាជាមួយអ្នកចូលរួមប្រព្រឹត្ត ដែលបានចូលរួមពាក់ព័ន្ធនៅក្នុងបទល្មើសដែលបានកើតឡើងក៏ដោយ ពិរុទ្ធភាពរបស់ជនល្មើសបន្ទាប់បន្សំស្ថិតនៅលើអង្គហេតុដែលថា ជននេះអាចចូលរួមនៅក្នុងការប្រព្រឹត្តបែបនេះ ប៉ុន្តែមានចេតនាប្រថុយថាវាភាគច្រើនអាចប្រព្រឹត្តឡើង។ ជននេះអាចបង្កាមិនអោយបទល្មើសត្រូវបានប្រព្រឹត្តឡើងបន្ថែមទៀត ឬ ដកខ្លួនឯងចេញពីការប្រព្រឹត្តដែលទំនងជាកើតមានឡើង ហើយការខកខានមិនបានធ្វើបែបនេះ ធ្វើអោយជននេះខ្លួនឯងដាច់ខាតត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសទាំងនោះ។ ចំណុចវាផ្ទុយគ្នាផងដែរទៅនឹងយុត្តិសាស្ត្រថ្មីៗរបស់តុលាការ SCSL។ មតិភាគច្រើននៅក្នុងសាលដីកាក្នុងរឿងក្តី RUF ច្រានចោលភាពខុសគ្នារវាង ធាតុអត្តនោម័ត (mens rea) ដែលចាំបាច់សម្រាប់ JCE I និងធាតុអត្តនោម័តដែលអនុវត្តចំពោះ JCE III ជាលទ្ធផលបណ្តាលអោយជនជាប់ចោទទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើស*ដែលស្ថិតនៅក្នុង*គោលបំណងរួម ដែលជនជាប់ចោទមិនមានចេតនា ហើយដែលគ្រាន់តែវាសមហេតុផលដែលជននេះអាចប្រមើលមើលទុកជាមុននោះ។ ហេតុដូច្នេះ មតិភាគច្រើន ជាលទ្ធផលលុបបំបាត់ចោលនូវលក្ខខណ្ឌតម្រូវជាគោលសម្រាប់គ្រប់ទម្រង់

[100] Cecily Rose, ដីការបញ្ជូនរឿងទៅជំនុំជម្រះនៅតុលាការពិសេសនៃប្រទេសសេរ៉ាឡេអូន ការសន្និដ្ឋានអំពីសហឧក្រិដ្ឋកម្មរួម និងបទឧក្រិដ្ឋផ្លូវភេទ, ថ្ងៃទី៧ ខែមករា, ឧក្រិដ្ឋកម្មអន្តរជាតិ. JUST. 353, 362-63 (2009).

នៃ JCE (I, II, ឬ III) ចំពោះគោលបំណងរួមនៃបទល្មើសព្រហ្មទណ្ឌ។ ដោយមិនគិតពីចេតនារបស់ជនជាប់ចោទ ឬសូម្បីតែការព្រមព្រៀង តាមមតិភាគច្រើន ជនជាប់ចោទទំនងជាត្រូវទទួលខុសត្រូវចំពោះគ្រប់បទល្មើសទាំងអស់ អនុលោមទៅតាមគោលបំណងរួម ថ្វីបើខ្លួនមិនមានចេតនាមធ្យោបាយ ការរួមចំណែកពិតប្រាកដនៅក្នុងបទល្មើសទាំងនោះក៏ដោយ[101]។ ក្រុមមេធាវីការពារក្តី មិនអាចគាំទ្រសាលដីកានេះបានទេ ប៉ុន្តែក្រុមមេធាវីការពារក្តីនិយាយយោងទៅរកបញ្ហានេះនៅពេលនេះ គឺគ្រាន់តែដើម្បីបង្ហាញថា គោលគំនិតនៃ JCE គឺមិនមានលក្ខណៈងាយស្រួលដូចដែល ក.ស.ព បានលើកឡើងនោះទេ។

៥៥. ក្នុងកថាខណ្ឌ៦៩ ក.ស.ព បានលើកឡើងថា តុលាការអាចគិតពិចារណាពីកម្រិតផ្សេងៗគ្នានៃពិរុទ្ធភាព នៅពេលកាត់ទោស។ ការអះអាងនេះ គឺមានភាពជាក់ស្តែង ប៉ុន្តែមិនអាចធ្វើឱ្យការអនុវត្ត ទម្រង់នៃការទទួលខុសត្រូវដែលអស់សុពលភាពហើយនោះ មានសុពលភាពវិញបានទេ។

៥៦. ក្នុងកថាខណ្ឌ៧០ ក.ស.ព បានបញ្ជាក់ថា ក្រុមមេធាវីការពារក្តី បានចោទសួរអំពីភាពមិនច្បាស់នៃបទដ្ឋានដែលអាចប្រមើលទុកមុនបាននៃ JCE III។ ក.ស.ព មិនបានផ្តល់នូវសេចក្តីយោងដើម្បីគាំទ្រការអះអាងរបស់ខ្លួនដែលថា "ចៅក្រមជាតិ និងអន្តរជាតិ ធ្លាប់មានប្រវត្តិអនុវត្តបទដ្ឋានបែបនេះដោយម៉ត់ចត់ និងដោយយុត្តិធម៌ នៅក្នុងបរិបទជាច្រើនក្នុងច្បាប់ព្រហ្មទណ្ឌនោះទេ"។ បន្ទាប់មក ក.ស.ព អះអាងថា JCE III គឺផ្អែកទៅលើ "ការវាយតម្លៃសត្យានុម័ត" នៃភាពដែលអាចប្រមើលទុកមុនបាន ដូចដែលអ្វីដែលខ្លួនបានអះអាងថាជា ការជួយ និងជម្រុញ។ នេះផ្ទុយទៅនឹងការអះអាងរបស់ ក.ស.ច.ស នៅជើងទំព័រ៤០ នៃសាលដីកា JCE និងការសន្និដ្ឋានរបស់សាលដីកា JCE ដែលក្នុងនោះ ក.ស.ច.ស តម្រូវឱ្យមានបទដ្ឋានអន្តោម័ត។ ប៉ុន្តែ បញ្ហានេះ បានបង្ហាញឱ្យឃើញម្តងទៀតថា បទដ្ឋាននេះតាមពិតទៅមិនត្រូវបានដោះស្រាយនោះទេ ប៉ុន្តែផ្ទុយទៅវិញបទដ្ឋាននេះ មានលក្ខណៈស្រពិចស្រពិលដដែល។ បញ្ហាធ្ងន់ធ្ងរក្នុងការអនុវត្ត ការវាយតម្លៃដោយមិនលំអៀង គឺថាមនុស្សម្នាក់អាចត្រូវបានគេកាត់ទោសពីឧក្រិដ្ឋកម្មដែលគាត់មិនយល់ស្រប និងសូម្បីតែគាត់ខ្លួនឯងផ្ទាល់មិនអាចទាយទុកមុនបានផង[102]។

---

[101] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Sesay et al* សំណុំរឿង SCSL-04-15-A សាលដីកា ចុះថ្ងៃទី ២៦ តុលា ២០០៩ យោបល់ជំទាស់ដោយឡែក និងយោបល់យល់ស្របរបស់ចៅក្រមជាន់ខ្ពស់ (Justic) Shireen Avis Fisher កថាខណ្ឌ ១ ដល់ ៤៦ ។

[102] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ៦០ ដល់៦៣

00486687



៥៧. ក្នុងកថាខណ្ឌ៧១ ក.ស.ព អះអាងថា អ្វីដែលនៅតែជាបញ្ហាចោទនោះ គឺមិនមែនដោយសារតែការទទួលខុសត្រូវ JCE មានចែងក្នុងច្បាប់អន្តរជាតិនោះទេ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថាតើក្រោមលក្ខណ្ឌមួយណា ដែលការទទួលខុសត្រូវ JCE ត្រូវយកមកអនុវត្ត។ ក្រុមមេធាវីការពារក្តីបានច្រានចោល ការសន្និដ្ឋានរបស់ ក.ស.ព ដែលថា ការទទួលខុសត្រូវ JCE ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ប៉ុន្តែយល់ស្របថា មានការអះអាងជាច្រើន អំពីថាតើការទទួលខុសត្រូវ JCE ត្រូវបានគេយកទៅអនុវត្តតាមរបៀបណា នៅក្នុងតុលាការពីរបីដែលបានអនុវត្តវា[103]។ លើសពីនេះទៅទៀត ការសន្និដ្ឋានរបស់ ក.ស.ព បានអះអាងថា តុលាការបណ្តោះអាសន្នពិសេសមួយចំនួន បានបង្ហាញពីរូបរាងរបស់ JCE III ដើម្បីឲ្យវាមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់។ ការលើកឡើងនេះ មិនត្រឹមត្រូវទេ។ វា នៅតែមានធាតុផ្សំមួយចំនួន នៃការទទួលខុសត្រូវ JCE III ដែលនៅមិនទាន់ដោះស្រាយ នៅតុលាការបណ្តោះអាសន្ននោះ ដូចដែលអ្វីដែលក្រុមមេធាវីការពារក្តីបានបង្ហាញខាងលើ និងនៅក្នុងបណ្តឹងឧទ្ធរណ៍[104]។ ជាងនេះទៅទៀត ទោះបីជាឥឡូវនេះទម្រង់នៃទទួលខុសត្រូវ JCE ត្រូវបានគេចាត់ទុកថាមានភាពច្បាស់លាស់ហើយក៏ដោយ ក៏ទម្រង់ទាំងនោះ មិនត្រូវបានកំណត់ឲ្យបានច្បាស់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះដែរ។ នេះ គឺជាភស្តុតាងបន្ថែមទៀតដែលថា JCE ដែលបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* នោះមិនអាចយកទៅអនុវត្តដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះបានទេ។ ក.ស.ព បានអះអាងថា លក្ខណ្ឌរបស់ JCE III គឺៈ

> [បន្ថែម] ទៅលើការចូលរួមយ៉ាងសំខាន់របស់ចុងចោទក្នុងការអនុវត្តគម្រោងការឧក្រិដ្ឋនោះជនជាប់ចោទនោះត្រូវ (ក)ចូលរួមចំណែកដោយចេតនាក្នុងឧក្រិដ្ឋកម្មនោះផងដែរ (ខ) ដឹងអំពីលទ្ធភាព ដែលបទឧក្រិដ្ឋអាចនឹងត្រូវបានគេប្រព្រឹត្ត ដែលជាលទ្ធផលនៃការអនុវត្តន៍អំពើល្មើស ហើយ សុខចិត្តប្រថុយធ្វើ។ ដូច្នេះ បទល្មើសមិនត្រឹមតែជាបច្ច័យដែលគ្រោងទុកមុនបាន និងជាធម្មតាដែលមានលក្ខណៈចាំបាច់សម្រាប់ការចូលរួមនៅក្នុងផែនការនោះ (ដែលពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដែលត្រូវការបទដ្ឋាននៃការធ្វេសប្រហែស ឬ dolus eventualis) ប៉ុណ្ណោះ ទេជនជាប់ចោទប្រាកដជា "សុខចិត្ត" ប្រថុយធ្វើទោះបីជាដឹងពីបច្ច័យនោះជាមុនក៏ដោយ។

---

[103] សូមមើលខាងលើ, កថាខណ្ឌ៣៦

[104] សូមមើលខាងលើ, កថាខណ្ឌ៧៧

ការអះអាងរបស់ ក.ស.ព ដែលថាការចូលរួមនៅក្នុងផែនការរួម មានការពាក់ព័ន្ធទៅនឹងការវាយតម្លៃសត្យានុម័ត និងតម្រូវឱ្យមានបទដ្ឋាននៃការធ្វេសប្រហែសឬ dolus eventualis នោះកើតចេញពីយុត្តិសាស្ត្រដែលបានបង្កើតឡើងដោយតុលាការICTY ដែលថាជនជាប់ចោទប្រាកដជាមានចេតនាចូលរួមក្នុងផែនការរួម[105]។ ប្រយោគចុងក្រោយរបស់ ក.ស.ព នៅក្នុងកថាខណ្ឌនេះមានលក្ខណៈមិនច្បាស់លាស់។ ការតម្រូវឱ្យជនជាប់ចោទ "ដឹង" អំពីផលបច្ច័យដែលអាចព្យាករណ៍ទុកមុនបាន គឺមិនស្របទៅនឹងអំណះអំណាង[106]របស់ ក.ស.ព ដែលថាបទដ្ឋានសត្យានុម័តនៃភាពអាចព្យាករណ៍ទុកមុនបាន គួរតែត្រូវបានគេដាក់ឱ្យអនុវត្ត។ ប្រសិនបើបទដ្ឋានសត្យានុម័តត្រូវបានគេប្រើប្រាស់ ជនជាប់ចោទខ្លួនឯងផ្ទាល់ មិនចាំបាច់ត្រូវដឹងអំពីបច្ច័យដែលអាចព្យាករណ៍ទុកមុននោះទេ។ បញ្ហានេះ បញ្ជាក់បន្ថែមទៀតថា បទដ្ឋាននេះ មិនមានភាពច្បាស់លាស់នោះទេ។

៥៨. ក្នុងកថាខណ្ឌ៧២ ក.ស.ព បានអះអាងថា អង្គជំនុំជម្រះតុលាការកំពូលICTY មាន "ចេតនារារាំងការទទួលខុសត្រូវ JCE មិនពង្រីកខ្លួនតាមលក្ខណៈមួយដែលមិនច្បាស់លាស់"។ ក្រុមមេធាវីការពារក្តី គាំទ្រការខិតខំប្រឹងប្រែបែបនេះ នៅឯតុលាការICTY ប៉ុន្តែករណីនេះ មិនមានឥទ្ធិពល ទៅលើករណីនៃភាពអាចអនុវត្តបានរបស់ JCE នៅចំពោះមុខ អ.វ.ត.ក នោះទេ។

**ឃ. ការទទួលខុសត្រូវ JCE មិនអាចពង្រីកខ្លួនទាំងនៅក្នុងបទឧក្រិដ្ឋថ្នាក់ជាតិ និងអន្តរជាតិនៅក្រោមច្បាប់របស់ អ.វ.ត.ក**

៥៩. ក្នុងកថាខណ្ឌ៧៣ ក.ស.ព គ្រាន់តែបានបង្ហាញពីគោលជំហរ ដែលបានប្រកាន់យកនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន និងបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងការសម្រេចរបស់ ក.ស.ច.ស ដែលថា JCE អាចយកទៅអនុវត្តបានតែចំពោះឧក្រិដ្ឋកម្មអន្តរជាតិប៉ុណ្ណោះដោយសារតែទ្រឹស្តីនៃប្រព័ន្ធស្វ័យភាព។

៦០. ក្នុងកថាខណ្ឌ៧៤ ក.ស.ព អះអាងថា ការសម្រេចរបស់ ក.ស.ច.ស ដែលថា JCEមិនអាចយកទៅអនុវត្តបានចំពោះបទឧក្រិដ្ឋថ្នាក់ជាតិ គឺគ្រាន់តែជា*ការលើកឡើងតែប៉ុណ្ណោះ*(obiter dicta) ហើយគួរតែត្រូវបានគេមើលរំលង។ ក.ស.ព បានអះអាងថា ក្រុមមេធាវីការពារក្តី "មិនបានស្វែង

---

[105] សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* កថាខណ្ឌ២២៨

[106] ចម្លើយតប, កថាខណ្ឌ៧០,៨៥

00486689



រកសេចក្ដីប្រកាសទាក់ទងទៅនឹងភាពអាចអនុវត្តបាននៃ JCE នៅចំពោះមុខតុលាការជាតិរបស់កម្ពុជានោះទេ"។ ក.ស.ព បានអះអាងបន្ថែមទៀតថា ក.ស.ច.ស មិនបានរកឃើញថា មានប្រព័ន្ធស្វ័យភាព នៅក្រោមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក នោះទេ ដូច្នេះហើយ វាហួសពីវិសាលភាពនៃការស៊ើបអង្កេតរបស់ខ្លួន ដើម្បីសម្រេចថាតើ JCE អាចត្រូវគេអនុវត្តចំពោះបទឧក្រិដ្ឋថ្នាក់ជាតិដែរឬអត់។ គោលជំហររបស់ក្រុមមេធាវីការពារក្ដីដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងបណ្ដឹងឧទ្ធរណ៍[107] គឺថា អ.វ.ត.ក គឺជាតុលាការកម្ពុជាថ្នាក់ជាតិ។ ទោះបីជាក្រុមមេធាវីការពារក្ដីបានច្រានចោលការលើកឡើងដែលថាគោលគំនិត នៃប្រព័ន្ធស្វ័យភាពអាចយកមកអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ក៏ដោយ ក៏ខ្លួនពិតជាបានលើកឡើងថា វាមិនមែនស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេតដើម្បីសម្រេចថាតើ JCE អាចត្រូវគេយកមកអនុវត្តចំពោះបទឧក្រិដ្ឋថ្នាក់ជាតិឬអត់នោះទេ។ ថាតើ JCE ត្រូវគេយកមកអនុវត្ត ថាតើវាត្រូវបានគេអនុវត្តដោយរបៀបណា និងថាតើវាត្រូវបានគេអនុវត្តដល់កំរិតណានោះ គឺជាផ្នែកសំខាន់នៃបញ្ហានេះ។ ក្រុមមេធាវីការពារក្ដីត្រូវតែមានព័ត៌មាននេះ ដើម្បីឲ្យមានការកត់សម្គាល់គ្រប់គ្រាន់ ដូចអ្វីដែល ក.ស.ច.ស បានពន្យល់រួចមកហើយ[108]។ ដូចច្នេះ មេធាវីការពារក្ដី ត្រូវតែប្ដឹងឧទ្ធរណ៍ចំពោះសាលដីកាទាក់ទងនឹងការអនុវត្តJCE។

៦១. នៅក្នុងកថាខណ្ឌទី៧៥ ក.ស.ព បានអះអាងថា មិនមានការអនុវត្តន៍ផ្ទុយគ្នានៃប្រព័ន្ធស្វ័យភាពនៅ អ.វ.ត.ក នោះទេ។ ក្រុមមេធាវីការពារក្ដី យល់ស្របថា ការពិភាក្សារបស់ ក.ស.ច.ស អំពីប្រព័ន្ធស្វ័យភាព គឺមានកំហុស និងមិនចាំបាច់។ បន្ទាប់មក ក.ស.ព អះអាងថា មិនថាការអនុវត្តន៍ផ្ទុយគ្នានៃប្រព័ន្ធស្វ័យភាព ដែលគ្រប់គ្រងឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិ មាននៅក្នុងច្បាប់បារាំងឬសូម្បីតែច្បាប់កម្ពុជា ឬអត់ក៏ដោយ អ.វ.ត.ក មាន "ទស្សនៈយុត្តាធិការដាច់ដោយឡែក (Sui gereris) ដោយផ្អែកទៅលើវិធាននៃនីតិវិធីរបស់ខ្លួនដែលមិនបានប្រមើលមើលពីការអនុវត្តន៍ពីរផ្ទុយគ្នាបែបនេះទេ"។ ក្រុមមេធាវីការពារក្ដី បានច្រានចោលការអះអាងនេះ ព្រោះខ្លួនបានបង្ហាញរួចរាល់ហើយថា អ.វ.ត.ក គឺជាតុលាការកម្ពុជាថ្នាក់ជាតិ[109]។ ដូច្នេះហើយ ប្រសិនបើច្បាប់កម្ពុជាពិតជាបានអនុវត្តនូវប្រព័ន្ធស្វ័យភាព នេះមែន អ.វ.ត.ក ត្រូវតែគោរពប្រព័ន្ធស្វ័យភាពនេះ។ ប៉ុន្តែ

---

[107] សូមមើលបណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ៧ ដល់២៤

[108] សូមមើល សាលដីការបស់ ក.ស.ច.ក,កថាខណ្ឌ១០

[109] សូមមើលបណ្ដឹងឧទ្ធរណ៍, កថាខណ្ឌ៧ ដល់២៤

ដូចដែលក្រុមមេធាវីការពារក្តី[110] និងដើមបណ្តឹងរដ្ឋប្បវេណី[111] បានពន្យល់រួមមកហើយ ច្បាប់កម្ពុជា មិនមានចែងពីប្រព័ន្ធស្វ័យភាពនេះទេ។ ជាងនេះទៅទៀត វិធានផ្ទៃក្នុង មិនអនុញ្ញាតឱ្យ អ.វ.ត.ក បំពេញមុខងារក្រៅច្បាប់កម្ពុជា នោះទេ។ វិធានផ្ទៃក្នុង គឺគ្រាន់តែចង់ច្របាច់បញ្ចូលគ្នានូវនីតិវិធីជាធរមានរបស់កម្ពុជា សម្រាប់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក តែប៉ុណ្ណោះ...[112]។ ក.ស.ព បានបញ្ជាក់ថា អង្គបុរេជំនុំជម្រះ បានយល់ឃើញថា វិធានផ្ទៃក្នុង គឺជាលិខិតតុបករណ៍ដ៏សំខាន់ ដែលគួរប្រើជាឯកសារយោងក្នុងការសម្រេចនីតិវិធីចំពោះមុខ អ.វ.ត.ក ដែលមានភាពខុសគ្នារវាងនីតិវិធីក្នុងវិធានទាំងនោះ និងក្រមនីតិវិធីព្រហ្មទណ្ឌជាតិ។ ក្រុមមេធាវីការពារក្តី កត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះ បានធ្វើការអះអាងនេះ បន្ទាប់ពីបានបញ្ចេញទស្សនៈថា វិធានទាំងនេះ មិនបានប្រឆាំងទៅនឹងនីតិវិធីព្រហ្មទណ្ឌជាតិ[113]។

៦២. ក្នុងកថាខណ្ឌ៧៦ ក.ស.ព បានអះអាងថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលជាច្បាប់ពិសេស "(lex specialis) ក្នុងនាមជាតុលាការពិសេស(suin generis)" មិនបង្កើតនូវការអនុវត្តន៍ផ្ទុយពីគ្នាទាក់ទងទៅនឹងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងអន្តរជាតិនោះទេ។ ក្រុមមេធាវីការពារក្តី បានច្រានចោលនូវការកំណត់ថា អ.វ.ត.ក គឺជាតុលាការពិសេស។ ក.ស.ព អះអាងថា មាត្រា២៩ មិនបង្កើតនូវភាពខុសគ្នារវាងទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាលក្ខណៈជាតិ និង អន្តរជាតិឡើយ។ ដូច្នេះហើយទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលកំណត់ក្នុងមាត្រា២៩ (រួមបញ្ចូលទាំងសហឧក្រិដ្ឋកម្មរួមតាមរយៈ"បានប្រព្រឹត្ត") អនុវត្តស្មើគ្នាចំពោះឧក្រិដ្ឋកម្មជាលក្ខណៈជាតិ និងអន្តរជាតិ។ ក្រុមមេធាវីការពារក្តី យល់ស្របថា មាត្រានេះ មិនបានបង្កើតភាពខុសគ្នារវាងបទឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិទេ ប៉ុន្តែបានបដិសេធជាថ្មីម្តងទៀតថាJCEអាចត្រូវបានគេចាត់ទុកថាជាទម្រង់នៃការ"ប្រព្រឹត្ត"។ ក.ស.ព អះអាងថា មាត្រា២៩ គួរតែត្រូវបានគេបកស្រាយ "អនុលោមតាមវិធានស្តង់ដានៃការបកស្រាយសន្ធិសញ្ញា"។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក <u>មិនមែន</u> ជាសន្ធិសញ្ញាទេ។ វា គឺជាច្បាប់ក្នុងស្រុក ដែលអនុម័តដោយរដ្ឋធម្មនុញ្ញកម្ពុជា និងដាក់ឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រ

---

[110] សូមមើលខាងលើ, កថាខណ្ឌ៣២ ដល់៣៥

[111] សូមមើលសំណុំរឿង អៀង សារី

[112] វិធាន, បុព្វកថា

[113] សំនុំរឿង នួន ជា, 002/19-09-2007-ECCC/OCIJ(PTC 06),សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងទៅនឹងដីកាបដិសេធសំណើមោឃ ភាព,ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨, D55/I/8, ERN: 00219322-00219333។

កម្ពុជា។ ក.ស.ព គូសបញ្ជាក់ថា គោលដៅ និងគោលបំណង នៃមាត្រា២៩ ដូចនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ "គឺដើម្បីនាំទៅការកាត់សេចក្តីនៅឯអង្គសវនាការ ដែលផ្តោតជាពិសេសទៅលើក្រុមមនុស្សដែលបានរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ"។ ក.ស.ព បានអះអាងថា "ទម្រង់នៃការទទួលខុសត្រូវជាទំនៀមទម្លាប់ ដូចជាសហឧក្រិដ្ឋកម្មរួម ត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា២៩"។ វាមិនមានន័យដូច្នេះទេ។ ដូចដែលបានពន្យល់ម្តងហើយម្តងទៀតថា៖

> ទី១,ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានចែងឲ្យច្បាស់ថា ច្បាប់នេះអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនឹងត្រូវយកទៅអនុវត្តដោយផ្ទាល់ប្រឆាំងទៅនឹងបុគ្គលដែលត្រូវនាំទៅជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក។ ទី២, JCE ជាទម្រង់នៃការទទួលខុសត្រូវ ហើយមិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិទេ។ វាមិនអាចទៅរួចទេ ដែលត្រូវរំលោភទម្រង់នៃការទទួលខុសត្រូវ។ ដូច្នេះហើយ ច្បាប់នេះ មិនតម្រូវឲ្យ អ.វ.ត.ក អនុវត្ត នូវទម្រង់នៃការទទួលខុសត្រូវ ដោយផ្អែកទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ទី៣, ការអនុវត្តច្បាប់នេះ អាចត្រឹមតែដាក់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលវាមានអត្ថិភាព នៅក្នុងការបរិច្ឆេទពេលនោះ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តបន្ទាប់ពីច្បាប់នេះចូលជាធរមាន។ ដូច្នេះច្បាប់ស្តីពីការបង្កើត អ.វ.ត.ក អាចដាក់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ២០០១ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តបន្ទាប់ពីការបរិច្ឆេទនេះ។ វាមិនអាចដាក់បញ្ចូលជាធរមាននូវច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីឆ្នាំ១៩៧៥បានទេហើយច្បាប់នេះអនុវត្តចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តទៅនៅពេលនោះតែប៉ុណ្ណោះ[114]។

### ង. JCE ត្រូវបានចោទប្រកាន់យ៉ាងត្រឹមត្រូវក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

៦៣. ដោយសារតែផ្នែកនេះពាក់ព័ន្ធទៅនឹងការអះអាង ដែលលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ វាមិនត្រូវបានគេដោះស្រាយនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តី ទោះបីជាក្នុងកាលទេសៈណាក៏ដោយ មិនយល់ស្របថា JCE ត្រូវបានគេចោទប្រកាន់យ៉ាងត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទេ។

---

114 បណ្តឹងឧទ្ធរណ៍, ឧបសម្ព័ន្ធ, កថាខណ្ឌ១០២ (ការស្រង់ជាសំអាងជាប់មកជាមួយត្រូវបានលុបចោល)។

## ច. សេចក្តីប្រកាសJCE មិនមានហេតុផល មិនច្បាស់ ឬមានការពន្យារពេល

៦៤. ដោយសារផ្នែកនេះ ទាក់ទងទៅនឹងការអះអាងដែលលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន និង អៀង ធីរិទ្ធ ក្រុមមេធាវីការពារក្តី នឹងមិនធ្វើការដោះស្រាយនូវការអះអាងនោះភាគច្រើន ដែលបានលើកឡើងនៅក្នុងចម្លើយតបផ្នែកនេះឡើយ លើកលែងតែការអះអាងពីរនៅក្នុងកថាខណ្ឌ ៨៥។ ទី១, នៅក្នុងកថាខណ្ឌនោះ ក.ស.ព បានលើកឡើងថា ផ្នែកសំអាងហេតុរបស់ ក.ស.ច.ស ទាក់ទង ទៅនឹងបណាងឧក្រិដ្ឋ ក្នុងJCE III គឺគ្រាន់តែជាការ*លើកឡើងប៉ុណ្ណោះ* (obiter dicta) ដូច្នេះគួរតែបំភ្លេចចោល។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រកាសថាទម្រង់នៃការទទួលខុសត្រូវមួយ ត្រូវយកមកអនុវត្ត ដោយមិនបានកំណត់ទម្រង់នៃការទទួលខុសត្រូវនោះឲ្យបានច្បាស់លាស់ទេនោះ នឹងមិនមានលក្ខណៈគ្រប់គ្រាន់ ក្នុងការផ្តល់ការជូនដំណឹងដល់ក្រុមមេធាវីការពារក្តីនោះទេ។ ក.ស.ចស លើកឡើងថា ខ្លួនបានចេញដីកា JCE "ដើម្បីនូវការជូនដំណឹងគ្រប់គ្រាន់ទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវ ដែលមិនត្រូវបានបញ្ជាក់ច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬកិច្ចព្រមព្រៀង[115]" ភាគីមិនអាចមានការជូនដំណឹងគ្រប់គ្រាន់បានទេ ប្រសិនបើមិនត្រូវបានគេជូនដំណឹងអំពីនិយមន័យនៃទម្រង់នៃការទទួលខុសត្រូវនេះទេនោះ ជាពិសេសនៅពេលដែលទម្រង់នេះ មានភាពចម្រូងចម្រាស។ នេះ វាច្បាស់ណាស់ថា ក.ស.ច.ស[116] បានប្រកាន់យកគោលជំហរខុសពី ក.ស.ព[117] ទាក់ទងទៅនឹងថាតើJCE III តម្រូវឲ្យមានការវាយតម្លៃអត្តនោម័ត ឬការវាយតម្លៃសត្យានុម័ត។ ទី២, ក.ស.ព បកស្រាយថា ប្រសិនបើ JCE អាចអនុវត្តបាន, "វាគួរតែគ្រប់គ្រងដោយ ច្បាប់និងយុត្តិសាស្ត្រ ដែលទទួលបាននៅពេលវេលាមួយដែលបញ្ហារួមមួយ បានលេចឡើងនៅចំពោះ មុខអង្គភាពយុត្តិធម៌ នៃតុលាការនេះ"។ ការអះអាងបែបនេះមិនត្រឹមត្រូវទេ។ អនុលោមតាមគោលការណ៍និត្យានុកូលភាព ច្បាប់ដែលត្រូវយកមកអនុវត្ត គឺជាច្បាប់ដែលកើតឡើងពីឆ្នាំ ១៩៧៥ ដល់១៩៧៩។

## ឆ.បញ្ហាទាក់ទងនឹងសិទ្ធិនៃការបកប្រែ

---

[115] ដីការបស់ ក.ស.ច.ស,កថាខណ្ឌ១០

[116] ដីការបស់ ក.ស.ច.ស,ក្នុងកថាខណ្ឌ១០ បានលើកឡើងពីបណ្តឹងរដ្ឋអាជ្ញា តទល់នឹង *Kvočka et al.*, IT-98-30-1/A,សាលដីកាលើបណ្តឹងឧទ្ធរណ៍, កថាខណ្ឌ៨៦ចំពោះតម្រូវការដែលថា ជនជាប់ចោទ ត្រូវតែដឹងអំពីភាពអាចប្រមើលទុកមុនបាន នូវបទឧក្រិដ្ឋបន្ថែមទៀត។

[117] សូមមើលចម្លើយតប,កថាខណ្ឌ៧០

៦៥. ការអះអាងដែលលើកឡើងនៅក្នុងផ្នែកនេះ គឺជាការឆ្លើយតបដោយផ្ទាល់ទៅនឹងការអះអាងដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន និងពាក់ព័ន្ធតែជាមួយក្រុមនេះតែប៉ុណ្ណោះនៅក្នុងកាលទេសៈនេះ។ ដូច្នេះផ្នែកនេះ នឹងមិនត្រូវបានគេដោះស្រាយនោះទេ។

### ជ. បណ្តឹងឧទ្ធរណ៍នេះ មិនមានការបង្ហាញអង្គហេតុខុសទេ

៦៦. ក្នុងកថាខណ្ឌ៨៩ ដល់៩២ នៃចម្លើយតបនេះ ក.ស.ព លើកឡើងថា មេធាវីការពារក្តី បានផ្តល់អង្គហេតុខុសថា លោក Andrew Cayley ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ បានតវ៉ាយ៉ាងខ្លាំងអំពីការទទួលខុសត្រូវJCE នៅក្នុងករណីពីរដែលគាត់ធ្លាប់ធ្វើជាមេធាវីការពារក្តី។ មេធាវីការពារក្តីមិនបានផ្តល់អង្គហេតុបែបនេះទេ។ ផ្ទុយទៅវិញ មេធាវីការពារក្តី បានលើកឡើងថា "JCE" ត្រូវបានគេតវ៉ាយ៉ាងខ្លាំង"[118]នៅក្នុងករណីពីរ ដែលក្នុងនោះលោក Cayley ធ្វើជាមេធាវីការពារក្តី។ មេធាវីការពារក្តីមិនបានលើកឡើងថា លោក Cayley ខ្លួនឯងផ្ទាល់ ធ្វើការតវ៉ាទេ ហើយបើតាម មេធាវីការពារក្តីបានដឹង លោក Cayley ថែមទាំងធ្លាប់ទាំងបានបដិសេធទៅនឹងការទាស់ទៅនឹងការទទួលខុសត្រូវដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីរបស់គាត់ និងក្រុមមេធាវីការពារក្តីដទៃទៀតថែមទៀតផង នៅក្នុងករណីទាំងពីរនេះ។ ក្រុមមេធាវីការពារក្តី គ្រាន់តែចង់បង្ហាញពីភាពមិនស៊ីសង្វាក់គ្នា ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅពេលបច្ចុប្បន្ន ទាក់ទងទៅនឹងភាពស្របច្បាប់ នៃការទទួលខុសត្រូវJCE។ ទោះជាយ៉ាងណាក៏ដោយ ក្រុមមេធាវីការពារក្តីទទួលស្គាល់ថា នៅក្នុងរឿងក្តី JCE របស់លោក *Taylor* ត្រូវបានគេទទួលយកជាទម្រង់នៃការទទួលខុសត្រូវ ហើយត្រូវបានគេតវ៉ា ក្នុងលក្ខណៈមួយដែល JCE ត្រូវបានដាក់ក្នុងការចោទប្រកាន់តែប៉ុណ្ណោះ។

## V.សេចក្តីសន្និដ្ឋាន

៦៧. ក្នុងកថខណ្ឌ៩៣ និង៩៤ ក.ស.ព ស្នើឱ្យ អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះចោលដោយសារមិនអាចទទួលយកបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ បើបណ្តឹងឧទ្ធរណ៍នេះ សមនឹងទទួលយកបានវិញនោះ សហព្រះរាជអាជ្ញា ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ សម្រេចថាទម្រង់ទាំងបីសណ្ឋាននៃ ការទទួលខុសត្រូវJCE គឺអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក។ ក.ស.ព សន្និដ្ឋានថា ការច្រានចោលនូវការទទួលខុសត្រូវមួយ ដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ និងយ៉ាងពិត

---

[118] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌ៣៦

00486694



ប្រាកដនូវអាកប្បកិរិយានៃជនត្រូវចោទ ហើយការដកចេញបែបនេះពីការបង្កើតឡើងនូវករណីយុត្តិសាស្ត្រមួយដ៏ល្អត្រឹមត្រូវនោះ វាជាការភាន់ច្រឡំមួយ។ ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីស្នើឱ្យអង្គបុរេជំនុំជម្រះទទួលយកនូវបណ្តឹងឧទ្ធរណ៍នេះ ហើយច្រានចោលនូវសំណើសុំអនុវត្តនូវទម្រង់ទាំងអស់នៃការទទួលខុសត្រូវJCE នៅចំពោះមុខ អ.វ.ត.ក។ ក្រុមមេធាវីការពារក្តីលើកឡើងទៀតថា អ.វ.ត.ក នឹងមិនច្រានចោលការប្រើប្រាស់ការទទួលខុសត្រូវ JCE តែម្នាក់ឯងនោះទេ។ តុលាការ ICC ដូចដែលបានបង្ហាញយ៉ាងទូលំទូលាយនៅក្នុងបណ្តឹងឧទ្ធរណ៍[119] ប៉ុន្តែគួរអោយចំលែកដែរដែលវាមិនត្រូវបានដាក់បញ្ចូលពីការពិភាក្សានៅក្នុងចម្លើយតបនោះ ក៏បានច្រានការប្រើប្រាស់ការទទួលខុសត្រូវ JCE ដែរ។

**អាស្រ័យហេតុនេះ** ដោយគ្រប់ហេតុផលទាំងអស់ដែលបានរៀបរាប់ជូនខាងលើ មេធាវីការពារក្តី សូមស្នើដោយក្តីគោរពដល់ អង្គបុរេជំនុំជម្រះ មេត្តា៖

ក. **ប្រកាសថា** បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានតាមវិធាន ៧៤(៣)(ក) វិធាន ៥៥(១០) និង វិធាន ៧៤(៣)(ខ) ឬ វិធាន ២១ និង

ខ. **បដិសេធចោល** ការយល់ឃើញរបស់ដីកាដែលគេប្តឹងឧទ្ធរណ៍នេះ ដែលថា ការទទួលខុសត្រូវ JCE អាចអនុវត្តបានទៅលើឧក្រិដ្ឋកម្មអន្តរជាតិដែល អវតក មានយុត្តាធិការ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកការឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៨** ខែ **មីនា** ឆ្នាំ **២០១០**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[119] សូមមើលខាងលើ, កថាខណ្ឌ៥៩ ដល់៥៨